ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# កម្មវិធីសាលាកុមារមេត្រី

# ឯកសារណែនាំ ការអប់រំបំណិនជីវិតតាមមូលដ្ឋាន



នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ

— ឆ្នាំ ២០១៨ —

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ២៦៧ **...អយក.** មបទ

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១៦

**ជម្រាបមក**
**លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

**កម្មវត្ថុ៖** ការប្រើប្រាស់ឯកសារគាំទ្រការអនុវត្តកម្មវិធីសាលាកុមារមេត្រីនៅមធ្យមសិក្សា។

តបតាមកម្មវត្ថុខាងលើ សូមលោក លោកស្រីប្រធានជ្រាបថា ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយអង្គការយូនីសេហ្វ រៀបរៀងឯកសារគាំទ្រការអនុវត្តកម្មវិធីសាលាកុមារមេត្រីនៅមធ្យមសិក្សាចំនួន៣ក្បាលរួមមាន ៖ ឯកសារណែនាំក្រុមពិនិត្យតាមដាន និងវាយតម្លៃ ថ្នាក់ក្រុង ស្រុក ខណ្ឌ ឯកសារណែនាំប្រធានក្រុមបច្ចេកទេសនិងគ្រូបង្រៀន និងឯកសារណែនាំគ្រូបង្រៀនអប់រំបំណិនជីវិតតាមមូលដ្ឋាន ដើម្បីលើកកម្ពស់គុណភាព នៃការសិក្សារបស់សិស្សតាមរយៈការពង្រឹងបច្ចេកទេសនៃការបង្រៀនរបស់គ្រូ មានការជួយជំរុញ ការជួយគាំទ្រពីផ្នែកពាក់ព័ន្ធក្នុងប្រព័ន្ធអប់រំ និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា សំដៅលើកទឹកចិត្តសាលារៀនឱ្យទៅជាសាលាកុមារមេត្រី។

អាស្រ័យហេតុនេះ សូមលោក លោកស្រីប្រធានផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដល់ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ និងគ្រឹះស្ថានមធ្យមសិក្សា និងជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាព ។

សូមលោក លោកស្រីប្រធានទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត ហង់ ជួន ណារ៉ុន**

ចម្លងជូន៖
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានអប់រំ
- នាយកដ្ឋានពាក់ព័ន្ធ

"ដើម្បីជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ
- ឯកសារ.នាមចទ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៨៧ / ២១៧ ២៥៥ / ៤២៦ ៩៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ: www.moeys.gov.kh

# មាតិកា


១. សេចក្តីផ្តើម 0៦

២. បញ្ញត្តិ និងគំរូនៃការអប់រំបំណិនជីវិត 0៨

៣. ការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន ១១

៣.១. ការអភិវឌ្ឍកម្មវិធីបំណិនជីវិតបែបពិគ្រោះយោបល់នៅកម្រិតសាលារៀន ១១
៣.២. លំនាំនៃការបង្រៀន និងរៀនបំណិនជីវិត ១២
៣.៣. ការវាយតម្លៃការបង្រៀន និងរៀនបំណិនជីវិត ១២

៤. យន្តការក្នុងការគាំទ្រ និងអនុវត្តបំណិនជីវិត ១៣

៤.១. ការណែនាំសម្រាប់ការតម្រង់ទិសថ្នាក់ខេត្ត ១៣
៤.២. ការបំប៉ន DTMT និងគ្រូបំណិនជីវិត ១៤
៤.៣. ការតម្រង់ទិសដល់សាលា និងសហគមន៍ ១៤
៤.៤. ការប្រជុំប្រចាំឆ្នាំពិនិត្យឡើងវិញពីការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ១៥

៥. លំនាំនៃការបង្រៀន និងរៀន ១៨

៦. ការវាយតម្លៃការបង្រៀន និងរៀនបំណិនជីវិត ២០

៦.១. ទិដ្ឋភាពទូទៅនៃការវាយតម្លៃ ២០
៦.២. ការវាយតម្លៃកម្មវិធីបំណិនជីវិត ២១
៦.២.១ សេចក្តីផ្តើម ២១
៦.២.២ វង្វាយតម្លៃផ្លូវការ ២២
៦.២.៣ វង្វាយតម្លៃក្រៅផ្លូវការ ២៥

៧. ការចូលរួមរបស់សហគមន៍ និងអាជ្ញាធរមូលដ្ឋាន ២៦

ឧបសម្ពន្ធ័
ដំណាក់កាលទី ១៖ ការស្វែងយល់ប្រធានបទ ២៩
ដំណាក់កាលទី ២៖ ការស្រង់ព័ត៌មានពីសហគមន៍ ៣៧
ដំណាក់កាលទី ៣៖ ការវិភាគព័ត៌មានដោយប្រើដើមឈើបញ្ហា ៤១
ដំណាក់កាលទី ៤៖ ការរៀបចំផែនការ ៤៥
ដំណាក់កាលទី ៥៖ ការអនុវត្តផែនការ ផ្សព្វផ្សាយនៅតាមសហគមន៍ ៥៦
ដំណាក់កាលទី ៦៖ ការឆ្លុះបញ្ចាំងលើសកម្មភាពផ្សព្វផ្សាយ ៥៧

# កម្មវិធីបំណិនជីវិតតាមមូលដ្ឋាន

## ១ សេចក្ដីផ្ដើម

កម្មវិធីបំណិនជីវិតត្រូវបានបញ្ចូលទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា ឆ្នាំ ២០០៥-២០០៩។ ការអប់រំបំណិនជីវិតគឺជា ការឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់សិស្ស ដែលរស់នៅក្នុងយុគសម័យសកលភាវូបនីយកម្ម។ វាតម្រូវឱ្យពួកគេមានចំណេះដឹងជុំវិញខ្លួន បំណិនជំនាញ និងឥរិយាបថសមស្រប ដើម្បីធានាថាពួកគេអាចដោះស្រាយរាល់ការប្រឈម និងតម្រូវការក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ ប្រកបដោយប្រសិទ្ធភាព។ ក្រសួងអប់រំ យុវជន និង កីឡា បានកំណត់និយមន័យបំណិនជីវិត ដែលមានចែងនៅក្នុងគោលនយោបាយបំណិនជីវិតឆ្នាំ ២០០៦ ថា៖ «ជាបំណិនបញ្ញាបុគ្គលិកលក្ខណៈ អន្តរបុគ្គល និងវិជ្ជាជីវៈ ដែលអាចជួយដល់ការធ្វើការសម្រេចចិត្ត ការធ្វើទំនាក់ទំនង ប្រកបដោយប្រសិទ្ធភាពព្រមទាំងអាចដោះស្រាយ និងគ្រប់គ្រងខ្លួនឯងបាន។ គឺជាបំណិនដែលរួមចំណែក ក្នុងការលើកស្ទួយសុខុមាលភាព និងជីវិតប្រកបដោយផលិតភាព»។ គោលនយោបាយបានកំណត់ថាបំណិនជីវិតមានពីរប្រភេទគឺ បំណិនមូលដ្ឋាន និង បំណិនអាជីព៖

### បំណិនមូលដ្ឋាន (បំណិនសង្គម)

បំណិនមូលដ្ឋាន ជាបំណិនចាំបាច់ ដែលអ្នកសិក្សាគ្រប់រូបត្រូវតែទទួលបាន ដើម្បីជាគ្រឹះដ៏រឹងមាំសម្រាប់ការរស់នៅ ហើយត្រូវបានបញ្ជ្រាបចូលតាមមុខវិជ្ជាសំខាន់ៗទាំងបួន (ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងសិក្សាសង្គម) ដែលជាកម្មវិធីសិក្សាគោលរបស់ជាតិ។ បំណិនមូលដ្ឋានចែកចេញជាពីរ ផ្នែកតូចៗទៀតគឺ បំណិនជីវិតទូទៅ និងបំណិនបុរេវិជ្ជាជីវៈ។ បំណិនជីវិតទូទៅជារួម ផ្ដោតលើខ្លឹមសារសុខភាពផ្ទាល់ខ្លួន សុវត្ថិភាព ការធ្វើផែនការជីវិតប្រចាំថ្ងៃ និងការអភិវឌ្ឍផ្នែកសីលធម៌។ បំណិនបុរេវិជ្ជា ជីវៈផ្ដោតទៅលើការត្រៀមចាប់យកអាជីពណាមួយនៅពេលអនាគត។

### បំណិនអាជីព (បំណិនភារៈខារ)

បំណិនអាជីពជាបំណិនទាំងឡាយណា ដែលផ្ដោតលើសមត្ថភាពវិជ្ជាជីវៈជាក់ស្ដែង ហើយចែកចេញជាពីរផ្នែកតូចៗ ទៀតគឺ បំណិនអាជីពងាយ និងបំណិនវិជ្ជាជីវៈ។ បំណិនអាជីពងាយបង្រៀននៅក្នុងកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ពីថ្នាក់ទី ១ ដល់ទី ១០ ហើយបំណិនវិជ្ជាជីវៈបង្រៀននៅក្នុងកម្មវិធីអប់រំវិជ្ជាជីវៈជម្រើស សម្រាប់ថ្នាក់ទី១១ និង ១២ ។

កម្មវិធីបំណិនជីវិតតាមមូលដ្ឋាន មានគោលបំណងផ្ដល់ឱកាសដល់សិស្ស ដើម្បីពង្រីកការសិក្សារបស់ពួកគេដោយផ្អែកទៅលើតម្រូវការតាមមូលដ្ឋាន និងចំណាប់អារម្មណ៍របស់បុគ្គលម្នាក់ៗ។ ទោះបីវាជាផ្នែកមួយនៃកម្មវិធីសិក្សាជាតិក៏ដោយ ក៏ក្រសួងអប់រំមិនបានកំណត់កម្មវិធីសិក្សាជាក់លាក់ សម្រាប់កម្មវិធីបំណិនជីវិតតាមមូលដ្ឋាននៅ

ឡើយ ប៉ុន្តែបានផ្តល់ម៉ោងសិក្សា ២-៥ ម៉ោងក្នុងមួយសប្តាហ៍ចំពោះកម្មវិធីនេះ។ ជាគោលការណ៍ក្រសួង តម្រូវឱ្យសាលារៀបចំកម្មវិធីបំណិនជីវិតតាមមូលដ្ឋានដោយខ្លួនឯង ដើម្បីលើកកម្ពស់ការផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តតម្រង់ទិសវិជ្ជាជីវៈ និងអភិវឌ្ឍអាជីពងាយ។ ក្នុងការអនុវត្តជាក់ស្តែង សាលាជួបការលំបាកជាច្រើន ហើយសមត្ថភាពរបស់ពួកគេនៅមានកម្រិតក្នុងការអនុវត្តគោលនយោបាយនេះ។ ការប្រឈមទាំងនេះរួមមាន៖ កង្វះគ្រូ ថវិកា គ្រូឯកទេស ការចូលរួមរបស់សហគន៍ និងសមត្ថភាពរបស់សាលានៅមានកម្រិតក្នុងការរៀបចំកម្មវិធីបំណិនជីវិតនេះ។ ប៉ុន្តែក្រសួងបានផលិតឯកសារជាច្រើនពាក់ព័ន្ធទៅនឹងការអប់រំបំណិនជីវិតបំពេញបន្ថែមទៅលើគោលនយោបាយ។

## ឯកសារទាំងនោះ អាចប្រើជាឯកសារយោងក្នុងការរៀបចំ និងអភិវឌ្ឍកម្មវិធីបំណិនជីវិតតាមមូលដ្ឋានសម្រាប់សាលារៀន មានដូចជា៖

<u>កម្មវិធីសិក្សាលម្អិតបំណិនជីវិតតាមមូលដ្ឋាន</u> របស់នាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា ដែលជាខ្លឹមសារ ឬប្រភេទមេរៀនបំណិនជីវិត ដែលសាលាអាចជ្រើសរើសមកបង្រៀន ដូចជាផ្នែកកសិកម្ម សិប្បកម្ម ខ្នាតតូចសេវាកម្ម។

<u>ការណែនាំស្តីពីការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន សម្រាប់សាលារៀន សហគមន៍ និងអង្គការក្រៅរដ្ឋាភិបាល</u>របស់នាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា បង្ហាញពីដំណើរការបង្រៀនបំណិនជីវិតតាមរយៈការកៀរគរធនធានសហគមន៍ ការសិក្សាស្រាវជ្រាវ ការដោះស្រាយបញ្ហា និងការចែករំលែកបទពិសោធ។

<u>ការតម្រង់ទិសវិជ្ជាជីវៈសម្រាប់មធ្យមសិក្សាបឋមភូមិ</u>តម្រូវឲ្យបង្កើតគណៈកម្មការតម្រង់ទិសវិជ្ជាជីវៈ តាមសាលា ដោយផ្តោតការយកចិត្តទុកដាក់ចំពោះថ្នាក់ទី ៧ (ការជ្រើសមុខរបរ) ថ្នាក់ទី ៨ (ការស្គាល់ផ្លូវសិក្សា) និងថ្នាក់ទី ៩ (ការជ្រើសរើសផ្លូវសិក្សា) របស់នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ។

<u>ឯកសារបំណិនជីវិតតាមមូលដ្ឋានរបស់គម្រោង IBEC</u> មានដូចជាប្រភេទមេរៀនបំណិនជីវិតពាក់ព័ន្ធបញ្ហាសង្គម សេដ្ឋកិច្ច ការងារ និងអាជីព។ល។

ឯកសារនេះ ប្រមូលផ្តុំនូវគំនិត ទស្សនៈ ព្រមទាំងដំណើរការអប់រំបំណិនជីវិត ដោយផ្តោតលើការអភិវឌ្ឍចំណេះដឹងក្នុងសហគមន៍ បំណិន គុណតម្លៃ និងឥរិយាបថរបស់សិស្ស។ ដើម្បីសម្រេចបានលទ្ធផលនេះ តម្រូវឱ្យមានការរំលេចបញ្ញត្តិទាំងនេះ នៅក្នុងគោលនយោបាយអប់រំបំណិនជីវិត ដែលបានអនុវត្តសាកល្បងនៅក្នុងខេត្តគោលដៅ ដែលគាំទ្រ ដោយអង្គការយូនីសេហ្វ។ ឧទាហរណ៍៖ បំណិនមូលដ្ឋាន និងបំណិនអាជីពចែកជាផ្នែករងបី ដែលនៅក្នុងគោលនយោបាយមានតែពីរប៉ុណ្ណោះ។ ក្នុងន័យនេះ វាកំណត់ពីចង្កោមបំណិនខុសៗគ្នា ដែលតម្រូវឱ្យសិស្សមានដើម្បីអាចដោះស្រាយបញ្ហា និងការប្រឈមក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ។ ឯកសារនេះផ្តោតទៅលើតម្រូវការនៃការអភិវឌ្ឍបំណិនមូលដ្ឋាន និងបំណិនអាជីពងាយនៅក្នុងកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ដែលគោលនយោបាយរបស់ក្រសួងផ្តោតតែទៅលើបំណិនអាជីពងាយតែប៉ុណ្ណោះ ដោយគិតថាបំណិនមូលដ្ឋានត្រូវបានបញ្ជ្រាបចូលទៅក្នុងមុខវិជ្ជាគោលនៃកម្មវិធីសិក្សាជាតិរួចហើយ។

## ២ បញ្ញត្តិ និងគំរូនៃការអប់រំបំណិនជីវិត

បញ្ញត្តិ និងគំរូនៃការអប់រំបំណិនជីវិតថ្មីមួយ ត្រូវបានបង្កើតឡើងដោយផ្អែកទៅលើអនុសាសន៍នៃការពិនិត្យឡើងវិញវិស័យអប់រំ និងសន្និបាតអប់រំឆ្នាំ ២០១៥។ ដ្យាក្រាមខាងក្រោមបង្ហាញពីចំបញ្ញត្តិ និងគំរូនៃការអប់រំបំណិនជីវិត៖

### បញ្ញត្តិនៃការអប់រំបំណិនជីវិតថ្មី



## គំរូនៃការអប់រំបំណិនជីវិតបីប្រភេទ




បញ្ញត្តិបំណិនជីវិតត្រូវបានយកទៅអនុវត្តទៅតាមគំរូខុសគ្នាបីគឺ៖ ទី១ ការបញ្ជ្រាបទៅក្នុងកម្មវិធីសិក្សា ទី២ កម្មវិធីបំណិនជីវិតតាមមូលដ្ឋាន និងទី៣ កម្មវិធីបំណិនជីវិតដែលអនុវត្ត ដោយដៃគូអភិវឌ្ឍន៍។ ទោះជាតាមគំរូណាក៏ដោយ សិស្សអភិវឌ្ឍបំណិនតាមរយៈការឆ្លុះបញ្ចាំង និងវិភាគលើការរៀនមេរៀនបំណិនជីវិតទាំងនោះរួមមាន៖ ចំណេះដឹងទូទៅជុំវិញសហគមន៍របស់ខ្លួន បំណិនបុរេវិជ្ជាជីវៈ គុណតម្លៃផ្ទាល់ខ្លួន ការគ្រប់គ្រងអាជីវកម្ម និងការងារ និងជំនាញបច្ចេកទេស។ គំរូទាំងបីនៃការអប់រំបំណិនជីវិត មានបង្ហាញនៅក្នុងដ្យាក្រាមខាងលើ។

ទោះសិស្សរៀនតាមគំរូណាក៏ដោយ ចុងបញ្ចប់សិស្សគួរតែអភិវឌ្ឍបានបំណិនដូចខាងក្រោម៖

**បំណិនដែលសិស្សត្រូវអភិវឌ្ឍ**

| បំណិនមូលដ្ឋាន | | បំណិនអាជីព | |
|---|---|---|---|
| ចំណេះដឹងទូទៅ | ខ្លឹមសារជាក់លាក់ ដែលជួយសិស្សសម្រេចចិត្តបានត្រឹមត្រូវ ដោយផ្អែកលើព័ត៌មានគ្រប់ជ្រុងជ្រោយដូចជា៖<br>• អំណាន និងការគណនា<br>• អនាម័យ និងជំងឺឆ្លង<br>• ការយល់ដឹងពីបរិស្ថានជុំវិញខ្លួន<br>• ដំណើរការអភិវឌ្ឍន៍ក្នុងមូលដ្ឋាន<br>• ស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ច<br>• និន្នាការពិភពលោក។ល។ | បំណិនមូលដ្ឋាន | បំណិននេះសិស្សរៀននៅក្នុងកម្មវិធីសិក្សា និងបំណិនជីវិតតាមមូលដ្ឋានដូចបានកំណត់ក្នុងដ្យាក្រាមខាងលើ៖<br>• ចំណេះដឹងទូទៅ<br>• បំណិនបុរេវិជ្ជាជីវៈ<br>• គុណតម្លៃផ្ទាល់ខ្លួន |
| បំណិនបុរេវិជ្ជាជីវៈ | ចង្កោមបំណិនមួយចំនួន ដែលជួយឱ្យជីវិត និងការងាររបស់សិស្សទទួលបានជោគជ័យដូចជា៖<br>• ការគិតបែបពិចារណា<br>• ការគិតដោយច្នៃប្រឌិត<br>• ការដោះស្រាយបញ្ហា<br>• ការសម្រេចចិត្ត<br>• ការប្រាស្រ័យទាក់ទង<br>• ការកំណត់គោលដៅ<br>• ការហ៊ានប្រថុយ<br>• ការមានហេតុផល<br>• ការងារជាក្រុម ។ល។ | បំណិនគ្រប់គ្រងអាជីវកម្ម សេដ្ឋកិច្ច និងការងារ | ចង្កោមបំណិនដែលជួយសិស្សក្នុងការងារ និងធ្វើអាជីវកម្មទទួលបានជោគជ័យ ដូចជា៖<br>• ការធ្វើផែនការនិងចាត់ចែង<br>• ការគ្រប់គ្រងពេលវេលា<br>• ការគ្រប់គ្រងថវិកា<br>• ការស្វែងរកទីផ្សារ<br>• ភាពជាសហគ្រិន<br>• ការស្វែងរកការងារ<br>• បច្ចេកទេសសម្ភាស<br>• ពិភពការងារ<br>• ការហ្វឹកហាត់ការងារ។ល។ |
| គុណតម្លៃផ្ទាល់ខ្លួន | ចង្កោមតម្លៃមួយចំនួនដែលជួយឱ្យសិស្សទទួលបាននូវសេចក្តីថ្លៃថ្នូរ និងការគោរពដូចជា៖<br>• ការឱ្យតម្លៃខ្លួនឯង<br>• ការគ្រប់គ្រងកំហឹង<br>• ភាពស្មោះត្រង់<br>• ការទទួលខុសត្រូវ<br>• ភាពយុត្តិធម៌<br>• ការមានអធ្យាស្រ័យល្អ<br>• ឥរិយាបថវិជ្ជមាន<br>• ការយល់ចិត្តគ្នា។ល។ | បំណិនបច្ចេកទេស | ចង្កោមបំណិនមួយចំនួន ដែលពាក់ព័ន្ធទៅនឹងបច្ចេកទេសក្នុងការប្រតិបត្តិអាជីពងាយដូចជា៖<br>• បច្ចេកទេសការងារទទួលភ្ញៀវ<br>• បច្ចេកទេសសំអាងការ<br>• បច្ចេកទេសចុងភៅ<br>• បច្ចេកទេសចិញ្ចឹមសត្វ<br>• បច្ចេកទេសដាំបន្លែ<br>• បច្ចេកទេសកាត់ដេរ<br>• បច្ចេកទេសជួសជុលកង់ ម៉ូតូ<br>• បច្ចេកទេសជាងកំបោរ។ល។ |

កំណត់សម្គាល់៖ បំណិនទាំងនេះមានវឌ្ឍនភាពរបស់វាពីកម្រិតមូលដ្ឋានទៅមធ្យម និងខ្ពស់។ វាតម្រូវឱ្យគ្រូតាមដានការវិវត្តរបស់សិស្សរួចកំណត់គោលដៅជាមួយគ្នា ដើម្បីអភិវឌ្ឍបំណិនដែលស្ថិតនៅកម្រិតទាប។

# ៣ ការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន

## ៣.១. ការអភិវឌ្ឍកម្មវិធីសិក្សាបែបពិគ្រោះយោបល់នៅកម្រិតសាលារៀន

ក្នុងការអភិវឌ្ឍកម្មវិធីបំណិនតាមមូលដ្ឋាន នាយកត្រូវជួបអ្នកជំនាញសហគមន៍ ដើម្បីណែនាំ និងសួរពីការចូលរួមរបស់គាត់ក្នុងកម្មវិធីបំណិនជីវិត។ បន្ទាប់មកបើកកិច្ចប្រជុំជាមួយគ្រូ សហគមន៍ និងសិស្ស ដើម្បីអភិវឌ្ឍកម្មវិធីសិក្សាបំណិនជីវិតសម្រាប់សាលារបស់ខ្លួនទៅតាមលំនាំដូចខាងក្រោម៖

- ✓ បំផុសសំណួរ ដើម្បីកំណត់រកបញ្ហាដែលប៉ះពាល់ដល់ជីវិតប្រចាំថ្ងៃការសិក្សា និងការងាររបស់សិស្សដែលត្រូវយកមកដោះស្រាយ និងរៀនសូត្រ។
- ✓ កំណត់យកអាទិភាពចំនួន ៦-៩ ដែលត្រូវរៀននៅអនុវិទ្យាល័យ។ ជាទូទៅថ្នាក់នីមួយៗអាចរៀនបានចំនួន ២-៣ ប្រធានបទចំពោះម៉ោងដែលបានបែងចែកនៅក្នុងកម្មវិធីសិក្សាថ្មី (២ ម៉ោងក្នុងមួយសប្តាហ៍)។
- ✓ អភិវឌ្ឍខ្លឹមសារកម្មវិធីទៅតាមថ្នាក់នីមួយៗ (ប្រធានបទណាត្រូវរៀនថ្នាក់ទី ៧ ៨ និង៩) ដោយប្រើតារាងនៅក្នុងទំព័រទី ១៧។
- ✓ កំណត់ធនធាននៅក្នុងសហគមន៍ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន។ ធនធានទាំងនោះមានដូចជា ជនបង្គោលឃុំសម្រាប់ស្ត្រី និងកុមារ ប៉ូលីសឃុំ អាជីវករ និងកសិករជំនាញជាដើម។

### ជាទូទៅមេរៀនបំណិនជីវិតមានពីរប្រភេទ

១) បញ្ហាសង្គមដែលមាននៅក្នុងមូលដ្ឋានដូចជា៖ ចំណាកស្រុក អំពើហិង្សាក្នុងគ្រួសារ គ្រឿងញៀន សុខភាពអនាម័យទូទៅ។ល។

២) អាជីពងាយមានដូចជា៖ ដាំបន្លែ ចិញ្ចឹមត្រី ជួសជុលកង់ សំអាងការ មន្ត្រីសុខភាពឃុំ។ល។

> ឯកសារទាំងឡាយដែលក្រសួង និងអង្គការក្រៅរដ្ឋាភិបាលបានផ្សព្វផ្សាយ អាចជាផ្នែកមួយនៃបញ្ហាសង្គម ឬអាជីពងាយ ហើយអាចប្រើជាឯកសារយោង ប្រសិនបើសាលាបានជ្រើសរើសប្រធានបទនោះយកមកបង្រៀនដល់សិស្ស។

## ៣.២. លំនាំនៃការបង្រៀន និងរៀនបំណិនជីវិត (សូមមើលលម្អិតនៅឧបសម្ព័ន្ធ)

បន្ទាប់ពីការអភិវឌ្ឍកម្មវិធីសិក្សាបំណិនជីវិត សាលាត្រូវសហការជាមួយអ្នកជំនាញសហគមន៍ ដើម្បីបង្រៀនបំណិនជីវិតទៅតាមលំនាំខាងក្រោម។ វាជាការបង្រៀននិងរៀន ដែលមានលក្ខណៈជាការសិក្សាស្រាវជ្រាវងាយៗ និងផ្ដួចផ្ដើមដោះស្រាយបញ្ហា ដែលកើតមានឡើងនៅក្នុងសហគមន៍របស់ពួកគេ ដោយចែករំលែកបទពិសោធ និងចំណេះដឹងទៅវិញទៅមក។ ទន្ទឹមនឹងនេះ សិស្សក៏អាចរៀនពីអាជីវកម្មដែលមាននៅក្នុងមូលដ្ឋាន ក្នុងរូបភាពហាត់ការទៅតាមលំនាំដូចខាងក្រោម៖

១. ស្វែងយល់ពីប្រធានបទដែលត្រូវរៀន (បញ្ហាសង្គម ឬអាជីពងាយ)

២. ស្រង់ព័ត៌មាន និងបទពិសោធពីសហគមន៍លើប្រធានបទ

៣. វិភាគព័ត៌មានដោយប្រើដើមឈើបញ្ហា (ដើម្បីរកដំណោះស្រាយ ឬផែនការអាជីវកម្ម)

៤. អភិវឌ្ឍផែនការសកម្មភាពងាយៗ ដែលសិស្សដឹកនាំដោយមានការចូលរួមពីសហគមន៍ ឬធ្វើផែនការអាជីវកម្មរបស់ខ្លួន។

៥. អនុវត្តផែនការសកម្មភាពនៅតាមសហគមន៍ ដោយមានការគាំទ្រពីអាជ្ញាធរមូលដ្ឋាន ឬចាប់ផ្ដើមអនុវត្តផែនការអាជីវកម្មរបស់ខ្លួន។

៦. ឆ្លុះបញ្ចាំង និងវាយតម្លៃលើការបង្រៀន និងរៀនលើប្រធានបទ។

## ៣.៣. ការវាយតម្លៃការបង្រៀន និងរៀនបំណិនជីវិត (សូមមើលទំព័រទី២០ ដល់២៦)

ការវាយតម្លៃសិស្សក្នុងការរៀនបំណិនជីវិតផ្ដោតលើទិដ្ឋភាពបីយ៉ាង៖

១. ការអភិវឌ្ឍចំណេះដឹងដែលជួយសិស្សឱ្យសម្រេចចិត្តបានត្រឹមត្រូវ ដោយផ្អែកលើព័ត៌មានគ្រប់ជ្រុងជ្រោយ ព្រមទាំងប្រើប្រាស់ចំណេះដឹងសម្រាប់ខ្លួនឯង គ្រួសារ និងសហគមន៍។

២. ការអភិវឌ្ឍបំណិនបុរេវិជ្ជាជីវៈ ការគ្រប់គ្រងអាជីវកម្មនិងការងារ ព្រមទាំងជំនាញបច្ចេកទេស ដែលជួយឱ្យជីវិត និងការងាររបស់សិស្សប្រកបដោយជោគជ័យ។

៣. ការអភិវឌ្ឍគុណតម្លៃផ្ទាល់ខ្លួន ដែលជួយឱ្យសិស្សទទួលបាននូវសេចក្ដីថ្លៃថ្នូរ និងការគោរពពីអ្នកដទៃ និងចូលរួមធ្វើទង្វើល្អសម្រាប់សង្គម។

ជាលទ្ធផល នៅចុងបញ្ចប់ភូមិសិក្សា សិស្សអាចអភិវឌ្ឍបានចង្កោមបំណិនជាច្រើន។ តារាងខាងក្រោមជាចង្កោមបំណិន ដែលសិស្សនៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិគួរអភិវឌ្ឍ ហើយគ្រូគួរវាយតម្លៃសិស្សដោយផ្ដោតលើចង្កោមបំណិនទាំងនោះ។

| បំណិន ដែលសិស្សគួរអភិវឌ្ឍតាមកម្រិតថ្នាក់ | | |
| --- | --- | --- |
| ថ្នាក់ទី ៧ | ថ្នាក់ទី ៨ | ថ្នាក់ទី ៩ |
| • ការគ្រប់គ្រងពេលវេលា<br>• ការប្រាស្រ័យទាក់ទង<br>• ការងារក្រុម<br>• ភាពស្មោះត្រង់<br>• ការឲ្យតម្លៃខ្លួនឯង<br>• សញ្ញាណអាជីវកម្ម ការងារ<br>• សញ្ញាណបច្ចេកទេស | • ការគិតបែបពិចារណា<br>• ការកំណត់គោលដៅ<br>• ការដោះស្រាយបញ្ហា<br>• ការយល់ចិត្តគ្នា<br>• ការទទួលខុសត្រូវ<br>• សញ្ញាណអាជីវកម្ម ការងារ<br>• សញ្ញាណបច្ចេកទេស | • ការធ្វើផែនការនិងចាត់ចែង<br>• ការមានហេតុផល<br>• ការសម្រេចចិត្ត<br>• ឥរិយាបថវិជ្ជមាន<br>• ការគ្រប់គ្រងកំហឹង<br>• សញ្ញាណអាជីវកម្ម ការងារ<br>• សញ្ញាណបច្ចេកទេស |

# ៤ យន្តការក្នុងការគាំទ្រ និងអនុវត្តបំណិនជីវិត

## ៤.១. ការណែនាំសម្រាប់ការតម្រង់ទិសថ្នាក់ខេត្ត

បង្ហាញពីកម្មវិធីបំណិនជីវិតតាមមូលដ្ឋានដែលកែសម្រួលថ្មី ដើម្បីបង្កើនការយល់ដឹងដល់មន្ត្រីថ្នាក់ខេត្ត និងគាំទ្រដល់ការអនុវត្តកម្មវិធីអប់រំបំណិនជីវិតនៅតាមមូលដ្ឋាន។ តារាងខាងក្រោមជាគំនិតមួយចំនួនក្នុងតម្រង់ទិសដល់ថ្នាក់ខេត្ត ដោយគ្រូឧទ្ទេសថ្នាក់ជាតិ៖

| ថ្នាក់ដឹកនាំមន្ទីរ | ក្រុមការងារថ្នាក់ខេត្ត | ខ្លឹមសារសំខាន់ៗ |
| --- | --- | --- |
| • ប្រធាន/អនុប្រធានមន្ទីរ<br>• ប្រធានការិ. មធ្យមសិក្សា<br>• ប្រធានការិ. អធិការកិច្ច<br>• ប្រធានការិ. យុវជន<br>• ប្រធានការិ. បឋមសិក្សា | • មន្ត្រីការិ. មធ្យមសិក្សា<br>• មន្ត្រីការិ. អធិការកិច្ច<br>• មន្ត្រីការិ. បឋមសិក្សា<br>• គ្រូឧទ្ទេសសាលា/មជ្ឈ.គរុ. | • គោលនយោបាយ បញ្ញត្តិ និង យុទ្ធសាស្ត្រអប់រំបំណិនជីវិត<br>• កម្មវិធីសិក្សាបែបពិគ្រោះយោបល់<br>• លំនាំនៃការបង្រៀននិងរៀន<br>• ការវាយតម្លៃការអប់រំបំណិនជីវិត<br>• ការបង្កើតដៃគូ និងគាំទ្រពីសហគមន៍<br>• ការគាំទ្រដល់ថ្នាក់ស្រុក និង សាលារៀន<br>• ការប្រជុំប្រចាំឆ្នាំពិនិត្យឡើងវិញ ការអប់រំបំណិនជីវិត |

## ៩.២. ការបំប៉ន DTMT និងគ្រូបំណិនជីវិត

ដោយមានការគាំទ្រពីមន្ទីរអប់រំ នាយកសាលាជ្រើសរើសគ្រូដែលមានចំណាប់អារម្មណ៍ និងមានពេលគ្រប់គ្រាន់ក្នុងការបង្រៀនបំណិនជីវិត។ គ្រូឧទ្ទេសថ្នាក់ជាតិ និងមន្ទីរអប់រំត្រូវរៀបចំបំប៉នគ្រូ និង DTMT ដែលទទួលខុសត្រូវការបង្រៀន និងរៀនរយៈពេល ៣ ថ្ងៃ ទៅតាមខ្លឹមសារដែលមានក្នុងតារាងខាងក្រោម៖

| ថ្នាក់សាលារៀន | ក្រុមការងារថ្នាក់ស្រុក | ខ្លឹមសារសំខាន់ៗ |
|---|---|---|
| • គ្រូបំណិនជីវិត<br>• នាយកសាលា | • ប្រធានការិ.អរ. ស្រុក<br>• សមាជិក DTMT | • បញ្ញត្តិ និងការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន<br>• ការអភិវឌ្ឍកម្មវិធីសិក្សាបែបពិគ្រោះយោបល់<br>• លំនាំនៃការបង្រៀន និងរៀនបំណិនជីវិត (លម្អិត៦ដំណាក់កាល)<br>• ការវាយតម្លៃសិស្ស (បំណិនដែលសិស្សអភិវឌ្ឍ)<br>• ការគាំទ្ររបស់សហគមន៍ក្នុងការអប់រំបំណិនជីវិត<br>• ការប្រជុំប្រចាំត្រីមាសពិនិត្យមើលវឌ្ឍនភាព |

## ៩.៣. ការតម្រង់ទិសដល់សាលា និងសហគមន៍

ដើម្បីឲ្យសហគមន៍ចូលរួមពេលលេញក្នុងការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋានDTMTត្រូវសហការជាមួយនាយកសាលារៀបចំការតម្រង់ទិសដល់សហគមន៍។ការតម្រង់ទិសនេះគួរផ្តោតលើខ្លឹមសារដូចខាងក្រោមព្រមទាំងកំណត់តួនាទីរបស់សហគមន៍ ធនធាន ពេលវេលា និងអ្នកជំនាញសហគមន៍។ ទន្ទឹមនឹងនេះ DTMT មានតួនាទីសម្របសម្រួលការប្រជុំប្រចាំត្រីមាស ដើម្បីពិនិត្យវឌ្ឍនភាពក្នុងការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន និងចែករំលែកបទពិសោធនៅក្នុងស្រុករបស់ខ្លួន។

| សិក្ខាកាមចូលរួម | ខ្លឹមសារសំខាន់ៗ |
|---|---|
| • នាយក/នាយករងសាលា<br>• គណៈកម្មការទ្រទ្រង់សាលា<br>• តំណាងក្រុមប្រឹក្សាឃុំសង្កាត់<br>• អ្នកជំនាញក្នុងសហគមន៍ | • បញ្ញត្តិ និងការអប់រំបំណិនជីវិត<br>• ដំណើរការអភិវឌ្ឍកម្មវិធីបំណិនជីវិតបែបពិគ្រោះយោបល់<br>• តួនាទី និងការទទួលខុសត្រូវរបស់សហគមន៍<br>• ភាពជាដៃគូរវាងសាលារៀន និងសហគមន៍ក្នុងការបង្រៀនបំណិនជីវិត (គ្រូជាអ្នកសម្របសម្រួលការរៀនរបស់សិស្ស ប៉ុន្តែសហគន៍អាចចូលរួមជាវាគ្មិនផ្តល់ឱកាសហាត់ការផ្តល់កសិដ្ឋាន ដើម្បីរៀនសូត្រ។ល។)<br>• ការប្រជុំប្រចាំត្រីមាសរវាងសាលារៀន និងសហគមន៍ ដើម្បីពិនិត្យមើលវឌ្ឍនភាពការអប់រំបំណិនជីវិត។ |

## ៤.៤. ការប្រជុំប្រចាំឆ្នាំពិនិត្យឡើងវិញពីការអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន

ដើម្បីជុំរុញការអនុវត្តបំណិនជីវិតតាមមូលដ្ឋានឲ្យមានប្រសិទ្ធភាព មន្ទីរអប់រំនីមួយៗត្រូវរៀបចំការប្រជុំប្រចាំឆ្នាំពិនិត្យមើលវឌ្ឍនភាពការអនុវត្តបំណិនជីវិតតាមមូលដ្ឋាននៅក្នុងខេត្តរបស់ខ្លួន ដោយមានការចូលរួមពីគ្រូឧទ្ទេសថ្នាក់ជាតិ។ ការប្រជុំនោះគួរផ្តោតលើ៖

១. កម្មវិធីសិក្សាបែបពិគ្រោះយោបល់ការបង្រៀនបំណិនជីវិតតាមសាលា

២. ដំណើរការនៃការបង្រៀន និងរៀន

៣. ការចូលរួមរបស់សហគមន៍ក្នុងការអប់រំបំណិនជីវិត

៤. ការវាយតម្លៃលើបំណិនដែលសិស្សបានអភិវឌ្ឍ។

## មេរៀនបំណិនជីវិត ដែលសាលាអាចជ្រើសរើសក្នុងដំណើរអភិវឌ្ឍកម្មវិធីសិក្សា

| ផ្នែករួម | ក្រុមបំណិន | ប្រភេទមេរៀនបំណិនជីវិត | ប្រធានបទ | លំនាំនៃការបង្រៀន |
|---|---|---|---|---|
| បំណិនសិក្សា ស្រាវជ្រាវ និងរកគំហើញថ្មី: ការរៀនពីបទពិសោធ ការរៀនតាមបែបសហការ និងការងារជាក្រុម។ | បំណិនមូលដ្ឋាន | បញ្ហាសង្គមដែលមាននៅតាមមូលដ្ឋាន | ✓ ការយល់ដឹងពលរដ្ឋវិទ្យា<br>✓ សុខភាពផ្លូវភេទ<br>✓ ការយល់ដឹងពីវប្បធម៌<br>✓ ការយល់ដឹងពីបរិស្ថាន<br>✓ សិល្បៈតាមមូលដ្ឋាន<br>✓ ចំណាកស្រុក<br>✓ អំពើហិង្សាក្នុងគ្រួសារ<br>✓ អនាម័យទឹកស្អាត<br>✓ ផ្សេងទៀត | ✓ ប្រើជំនាញក្នុងមូលដ្ឋាន (ចាស់ព្រឹទ្ធាចារ្យ ជនបង្គោល ឃុំ NGO<br>✓ វិទ្យុទូរទស្សន៍បណ្ណាល័យ<br>✓ ៦ ដំណាក់កាល<br>✓ ការគាំទ្រពីអាជ្ញាធរ |
| | បំណិនមូលដ្ឋាន និងអាជីពងាយ | អាជីពងាយ | ✓ កសិកម្ម<br>✓ គេហកិច្ច<br>✓ ជួសជុលកង់<br>✓ អេឡិចត្រូនិច<br>✓ ផលិតគ្រឿងសង្ហារឹម<br>✓ ជួសជុលគ្រឿងសង្ហារឹម<br>✓ កាត់សក់បុរស/នារី<br>✓ សំអាងការ<br>✓ គ្រូសហគមន៍<br>✓ ក្រុមប្រឹក្សាឃុំ<br>✓ ផ្សេងទៀត | ✓ ប្រើជំនាញក្នុងមូលដ្ឋាន (កសិករ អាជីវករ NGO)<br>✓ វិទ្យុ ទូរទស្សន៍ បណ្ណាល័យ<br>✓ ៦ ដំណាក់កាល<br>✓ ការគាំទ្រពីអាជ្ញាធរ<br>ក្នុងការរៀនពីបំណិនអាជីពនីមួយៗ សិស្សអាចស្វែងយល់ពីអាជីវករនូវទំនាក់ទំនងជាមួយអតិថិជន ការគ្រប់គ្រង អាជីវកម្ម និងបច្ចេកទេស។ |

ចំពោះសាលា ដែលមិនអាចបង្កើតកម្មវិធីសិក្សាបំណិនសម្រាប់សាលារបស់ខ្លួនបាន សាលាអាចពិចារណាជ្រើសរើសមេរៀនដែលមាននៅក្នុងឯកសារ ដែលក្រសួងចែកជូនដូចខាងក្រោម៖

១. អនាគតខ្ញុំ

២. ការជ្រើសរើសអនាគតរបស់អ្នក

៣. ពិភពការងារ

៤. ជំនាញទីផ្សារខ្ញុំ

៥. ការគ្រប់គ្រងប្រាក់

៦. ការសន្សំ និងចំណាយ

## គំរូរៀបចំចាត់ចែងកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន (ឆ្នាំសិក្សា........)

(ប.ក.ក-ប្រធានក្រុមប្រឹក្សាកុមារ ជ.ស.ក-ជនបង្គោលស្ត្រី និងកុមារ និង អ.ជ.ស-អ្នកជំនាញសហគមន៍)

| ឈ្មោះសាលា: | | ខេត្ត: | ស្រុក: | |
|---|---|---|---|---|
| **ថ្នាក់ទី៧** | | | | |
| ចំនួនថ្នាក់សរុប: | | ចំនួនសិស្សសរុប: | ស្រី: | ប្រុស: |
| ប្រភេទកម្មវិធី | ចំនួនថ្នាក់ | បំណិនត្រូវអភិវឌ្ឍ | ធនធាន | ពេលវេលាគិតជាសប្តាហ៍ |
| បញ្ហាសង្គមផ្តោតលើការយល់ដឹងពីហេតុការណ៍ បំណិនទូទៅ និងគុណតម្លៃដែលមាននៅក្នុងសហគមន៍ | | • ការគ្រប់គ្រងពេលវេលា<br>• ការប្រាស្រ័យទាក់ទង<br>• ការងារក្រុម<br>• ភាពស្មោះត្រង់<br>• ការឲ្យតម្លៃខ្លួនឯង<br>• សញ្ញាណអាជីវកម្ម ការងារ<br>• សញ្ញាណបច្ចេកទេស | ក្រុមប្រឹក្សាឃុំ<br>ប៉ូលីស<br>អង្គការ<br>ប.ក.ក។ល។ | |
| អាជីពងាយផ្តោតលើបំណិនបច្ចេកទេស អាជីវកម្ម និងការងារ និងបំណិនទូទៅដែលជាការចែករំលែកចំណេះដឹងនៅក្នុងសហគមន៍ | | | អ.ជ.ស<br>អង្គការ<br>ផ្នែកឯកជន។ល។ | |
| **ថ្នាក់ទី៨** | | | | |
| ចំនួនថ្នាក់សរុប: | | ចំនួនសិស្សសរុប: | ស្រី: | ប្រុស: |
| ប្រភេទកម្មវិធី | ចំនួនថ្នាក់ | បំណិនត្រូវអភិវឌ្ឍ | ធនធាន | ពេលវេលាគិតជាសប្តាហ៍ |
| បញ្ហាសង្គមផ្តោតលើការយល់ដឹងពីហេតុការណ៍ បំណិនទូទៅ និងគុណតម្លៃដែលមាននៅក្នុងសហគមន៍ | | • ការគិតបែបពិចារណា<br>• ការកំណត់គោលដៅ<br>• ការដោះស្រាយបញ្ហា<br>• ការយល់ចិត្តគ្នា<br>• ការទទួលខុសត្រូវ<br>• សញ្ញាណអាជីវកម្ម ការងារ<br>• សញ្ញាណបច្ចេកទេស | ក្រុមប្រឹក្សាឃុំ<br>ប៉ូលីស<br>អង្គការ<br>ប.ក.ក។ល។ | |
| អាជីពងាយផ្តោតលើបំណិនបច្ចេកទេស អាជីវកម្ម និងការងារ និងបំណិនទូទៅដែលជាការចែករំលែកចំណេះដឹងនៅក្នុងសហគមន៍ | | | អ.ជ.ស<br>អង្គការ<br>ផ្នែកឯកជន។ល។ | |
| **ថ្នាក់ទី៩** | | | | |
| ចំនួនថ្នាក់សរុប: | | ចំនួនសិស្សសរុប: | ស្រី: | ប្រុស: |
| ប្រភេទកម្មវិធី | ចំនួនថ្នាក់ | បំណិនត្រូវអភិវឌ្ឍ | ធនធាន | ពេលវេលាគិតជាសប្តាហ៍ |
| បញ្ហាសង្គមផ្តោតលើការយល់ដឹងពីហេតុការណ៍ បំណិនទូទៅ និងគុណតម្លៃដែលមាននៅក្នុងសហគមន៍ | | • ការធ្វើផែនការនិងចាត់ចែង<br>• ការមានហេតុផល<br>• ការសម្រេចចិត្ត<br>• ឥរិយាបថវិជ្ជមាន<br>• ការគ្រប់គ្រងកំហឹង<br>• សញ្ញាណអាជីវកម្មការងារ<br>• សញ្ញាណបច្ចេកទេស | ក្រុមប្រឹក្សាឃុំ<br>ប៉ូលីស<br>អង្គការ<br>ប.ក.ក<br>ជ.ស.ក<br>។ល។ | |
| អាជីពងាយផ្តោតលើបំណិនបច្ចេកទេស អាជីវកម្ម និងការងារ និងបំណិនទូទៅដែលជាការចែករំលែកចំណេះដឹងនៅក្នុងសហគមន៍ | | | អ.ជ.ស<br>អង្គការ<br>ផ្នែកឯកជន។ល។ | |
| យោបល់: | | | | |

# ៥ លំនាំនៃការបង្រៀន និងរៀន

**គម្រោងអភិវឌ្ឍមេរៀនបំណិនជីវិតតាមលំនាំដំណាក់កាលទាំង ៦**

| ឈ្មោះដំណាក់កាល | ប្រភេទសកម្មភាព | ចំណេះដឹង និងបំណិន ដែលបានអភិវឌ្ឍ | ធនធាន/សម្ភារ ចាំបាច់ | រយៈពេល |
|---|---|---|---|---|
| ១. ការស្វែងយល់ប្រធានបទ<br>គោលបំណង: កំណត់បាននូវអ្វី ដែលសិស្សចេះស្រាប់ និងមធ្យោបាយនានា ដើម្បីបង្កើនចំណេះដឹងរបស់សិស្សចំពោះប្រធានបទដែលបានជ្រើសរើស។ | • បំផុសសំណួរលើចំណេះដឹងមានស្រាប់<br>• អញ្ជើញអ្នកជំនាញមកធ្វើបទឧទ្ទេស (អ្នកមានចំណេះដឹងបទពិសោធស្រប តាមប្រធានបទ)<br>• ការអានឯកសារ (នៅបណ្ណាល័យ/សហគមន៍)<br>• ការប្រើករណីសិក្សា | • ជំនាញស្រាវជ្រាវ<br>• ជំនាញទំនាក់ទំនង<br>• ជំនាញរៀបចំចាត់ចែង<br>• ជំនាញនៃការបង្ហាញ<br>• យល់ដឹងច្បាស់ពីប្រធានបទ<br>• ម្ចាស់ការលើខ្លួនឯង<br>• សមត្ថភាពស្តាប់-អាន | • ធនធានមនុស្ស<br>• ឯកសារពាក់ព័ន្ធប្រធានបទ | ២ ម៉ោង |
| ២. ការស្រង់ព័ត៌មានពីសហគមន៍<br>គោលបំណង: បង្កើតឧបករណ៍ និងចុះប្រមូលព័ត៌មានពីសហគមន៍ ដែលអាចឱ្យសិស្សវាយតម្លៃការយល់ដឹង និងឥរិយាបថរបស់ពួកគេលើប្រធានបទដែលបានជ្រើសរើស។ | • បង្កើតកម្រងសំណួរ<br>• ការត្រៀមសម្ភាស<br>• ការសម្ភាសន៍ជាក់ស្តែង<br>• ការធ្វើរបាយការណ៍ | • ជំនាញស្រាវជ្រាវ<br>• ជំនាញទំនាក់ទំនង<br>• ជំនាញអន្តរបុគ្គល<br>• យល់ដឹងជុំវិញប្រធានបទ<br>• ម្ចាស់ការលើខ្លួនឯង<br>• ទំនុកចិត្តលើខ្លួនឯង<br>• សមត្ថភាពសរសេរ | • សៀវភៅ<br>• សិស្ស ប៊ិក ខ្មៅដៃ | ៨ ម៉ោង |
| ៣. ការវិភាគព័ត៌មានដោយប្រើដើមឈើបញ្ហា<br>គោលបំណង: ប្រើប្រាស់ព័ត៌មានដែលប្រមូលបាន ដើម្បីវិភាគបញ្ហាសំខាន់ៗ ដូចជាមូលហេតុ ផលវិបាក និងដំណោះស្រាយចំពោះបញ្ហានោះដោយប្រើដំណើរការវិភាគដើមឈើបញ្ហា។ | • បង្ហាញពីលទ្ធផលស្រាវជ្រាវ<br>• វិភាគដើមឈើបញ្ហា<br>• កំណត់យកដំណោះស្រាយ និងសង្ខេបខ្លឹមសារចងក្រងជាមេរៀនបំណិនជីវិត | • សមត្ថភាពនិយាយ<br>• ជំនាញក្នុងការវិភាគ<br>• ជំនាញការគិតដោយវិភាគ<br>• ជំនាញក្នុងការបង្ហាញ<br>• ទំនុកចិត្តលើខ្លួនឯង<br>• ការអប់រំខ្លួនឯង<br>• ឥរិយាបថវិជ្ជមានក្នុងការដោះស្រាយបញ្ហា | • ក្រដាសផ្ទាំងធំ<br>• ប៊ិចហ្វឹត<br>• ប័ណ្ណតូចៗ<br>• កន្ត្រៃ<br>• ស្កុត | ២ ម៉ោង |

| | | | | |
|---|---|---|---|---|
| ៤. ការអភិវឌ្ឍផែនការសកម្មភាពផ្សព្វផ្សាយ<br>គោលបំណង: កំណត់ដំណោះស្រាយដែលអាចអនុវត្តជាក់ស្តែង (មួយ ឬ ច្រើន) ដើម្បីដោះស្រាយបញ្ហា និងកសាងផែនការសម្រាប់អនុវត្ត។ | • ការជ្រើសរើសយកដំណោះស្រាយ<br>• រៀបចំផែនការសកម្មភាពផ្សព្វផ្សាយដល់សហគមន៍ (រួមមាន ល្បែង សរសេររឿង សម្តែងតួ។ល។)<br>• បង្ហាញផែនការ និងហ្វឹកហាត់<br>• ការរៀបចំអនុវត្តផែនការ | • ជំនាញធ្វើការសម្រេចចិត្ត<br>• ជំនាញក្នុងការធ្វើចំណាត់ថ្នាក់<br>• ជំនាញធ្វើការងារជាក្រុម<br>• ចំណេះដឹងបានមកពីការចូលរួមធ្វើផែនការ<br>• ទំនុកចិត្តលើខ្លួនឯង<br>• ឥរិយាបថវិជ្ជមានក្នុងការដោះស្រាយបញ្ហា | • ក្រដាសផ្ទាំងធំ<br>• ប៊ិចហ្វឺត<br>• ប័ណ្ណតូចៗ<br>• កន្ត្រៃ<br>• ស្កុត | ២ ម៉ោង |
| ៥. ការអនុវត្តផែនការនៅតាមសហគមន៍<br>គោលបំណង: សិស្សមានសមត្ថភាព អនុវត្តតាមដំណោះស្រាយដែលគេជ្រើសរើសជាទម្រង់ សកម្មភាពផ្សព្វផ្សាយ និងចូលរួមដើម្បីដោះស្រាយបញ្ហាដែលមាននៅតាមមូលដ្ឋាន។ | • ការផ្តល់ការណែនាំ<br>• ការអនុវត្តជាក់ស្តែងតាមសកម្មភាពមូលដ្ឋាន<br>• ការផ្តល់ព័ត៌មានត្រឡប់ និងការថ្លែងអំណរគុណ | • ជំនាញទំនាក់ទំនង<br>• ជំនាញអន្តរបុគ្គល<br>• ជំនាញរៀបចំចាត់ចែង<br>• ចំណេះដឹងតាមរយៈ: ការចូលរួមអនុវត្តផែនការ<br>• ចំណេះដឹងពីឥរិយាបថរបស់សហគមន៍<br>• ទំនុកចិត្តលើខ្លួនឯង<br>• ឥរិយាបថវិជ្ជមានផ្តោះទៅរកការដោះស្រាយបញ្ហាក្នុងសហគមន៍ | • ផ្អែកលើសកម្មភាពតាមមូលដ្ឋាន | ២ ម៉ោង |
| ៦. ការឆ្លុះបញ្ចាំង និងវាយតម្លៃ<br>គោលបំណង: លើកទឹកចិត្តសិស្ស ដើម្បីឆ្លុះបញ្ចាំង និងរៀនពីបទពិសោធក្នុងការអនុវត្តសកម្មភាពផ្សព្វផ្សាយនៅតាមមូលដ្ឋាន។ | • ឆ្លុះបញ្ចាំងលើសកម្មភាពតាមមូលដ្ឋាន<br>• ការសរសេររបាយការណ៍ | • ជំនាញក្នុងការវិភាគ<br>• ជំនាញគិតដោយវិភាគ<br>• ទំនុកចិត្តខ្លួនឯង<br>• ម្ចាស់ការខ្លួនឯង<br>• ការយល់ដឹងខ្លួនឯង<br>• ឥរិយាបថវិជ្ជមានក្នុងការដោះស្រាយបញ្ហាក្នុងសហគមន៍ | • សៀវភៅសិស្ស និងប៊ិច ខ្មៅដៃ | ២ ម៉ោង |

# ៦ ការវាយតម្លៃការបង្រៀន និងរៀនកម្មវិធីអប់រំបំណិនជីវិត

## ៦.១. ទិដ្ឋភាពទូទៅនៃការវាយតម្លៃ

ការវាយតម្លៃមានសារៈសំខាន់ទាំងសម្រាប់ការបង្រៀន និងការរៀន។ មនុស្សគ្រប់រូបបារម្ភពីការវាយតម្លៃរាប់បញ្ចូលទាំងសិស្ស គ្រូបង្រៀន ឪពុកម្តាយ អ្នកគ្រប់គ្រង និងអធិការ។ ដូចនេះ ពួកគេត្រូវតែយល់ឱ្យបានច្បាស់ពីហេតុផលនៃការវាយតម្លៃ អ្វីដែលត្រូវវាយតម្លៃ លក្ខណៈវិនិច្ឆ័យ សម្រាប់ទទួលបានជោគជ័យ និងវិធីដែលប្រើក្នុងការវាយតម្លៃ។ ត្រូវចាំថាគោលបំណងនៃការបង្រៀន និងការវាយតម្លៃ គឺដើម្បីនាំសិស្សទៅកាន់ភាពជោគជ័យមិនមែនដើម្បីស្តីបន្ទោសឡើយ។ ទាំងសិស្ស និងគ្រូត្រូវតែសកម្មក្នុងការវាយតម្លៃពីភាពរីកចម្រើនរបស់សិស្ស ដែលជាផ្នែកមួយនៃការអភិវឌ្ឍបំណិនក្នុងការគិតឱ្យបានល្អិតល្អន់ និងអភិវឌ្ឍបំណិននៃការវាយតម្លៃដោយខ្លួនឯង។ គ្រូត្រូវតែបារម្ភផងដែរពីការវាយតម្លៃគុណភាពកម្មវិធីសិក្សា។ រង្វាយតម្លៃគឺជាការប្រមូល និងវិភាគព័ត៌មានអំពីលទ្ធផលនៃការសិក្សារបស់សិស្ស។ វាបញ្ជាក់ពីអ្វីដែលសិស្សបានចេះ យល់ អាចធ្វើបាន និងអារម្មណ៍របស់ពួកគេនៅដំណាក់កាលផ្សេងៗក្នុងលំនាំនៃការរៀន។ តាមរយៈការវាយតម្លៃអំពីការរីកចម្រើននៃការសិក្សារបស់សិស្សជាប្រចាំ និងមានលក្ខណៈជាប្រព័ន្ធ គ្រូអាចស្វែងយល់ពីអ្វីដែលសិស្សបានរៀន និងធ្វើការសម្រេចចិត្តបានត្រឹមត្រូវពីការបង្រៀនរបស់គាត់។

ជាទូទៅការវាយតម្លៃមានពីរប្រភេទ៖

### ក. ការវាយតម្លៃតាមដំណាក់

ការវាយតម្លៃតាមដំណាក់ពាក់ព័ន្ធទៅនឹងដំណើរការរៀនសូត្រប្រចាំថ្ងៃ ហើយវាជួយគ្រូ និងសិស្សឱ្យកំណត់បានពីអ្វីដែលបានរៀននិងចេះ ដើម្បីធ្វើផែនការបង្រៀន និងរៀននៅពេលបន្ទាប់ទៀត។ ការវាយតម្លៃតាមដំណាក់ និងការបង្រៀនមានទំនាក់ទំនងនឹងគ្នា គ្មានមួយណាអាចធ្វើទៅបានតែឯងនោះទេ។ ការវាយតម្លៃបែបនេះ ជាការពិនិត្យតាមដានលើការរីកចម្រើននៃការសិក្សាក្នុងគោលបំណងធ្វើឱ្យគ្រូ និងសិស្សដឹងពីភាពរីកចម្រើនទាក់ទងនឹងការបង្រៀន និងរៀនដើម្បីធ្វើយ៉ាងណាផ្លាស់ប្តូរវិធីបង្រៀន និងរៀន។ វាជាការផ្តល់ឱកាសឱ្យគ្រូកែតម្រូវល្បឿននៃការបង្រៀន និងកម្រិតនៃការរៀនរបស់សិស្ស។ រង្វាយតម្លៃតាមដំណាក់ អាចជាការសង្កេតប្រចាំថ្ងៃ ជជែកពិភាក្សាជាក្រុម សួរសំណួរ បំពេញការងាររបស់សិស្ស និងការអង្កេតរបស់គ្រូលើសកម្មភាពប្រែប្រួលរបស់សិស្សម្នាក់ៗ នៅចុងបញ្ចប់ ដំណាក់កាលនីមួយៗនៃប្រធានបទ។

### ខ. ការវាយតម្លៃសរុប

រង្វាយតម្លៃសរុបធ្វើឡើងនៅចុងបញ្ចប់នៃខ្លឹមសារមេរៀនថ្មី ឬម៉ូឌុលថ្មី។ ការវាយតម្លៃសរុបនេះ ជួយឱ្យគ្រូ និងសិស្សកំណត់បានថា តើការបង្រៀន និងរៀនរបស់គេសម្រេចបានតាមវត្ថុបំណងជាក់លាក់នៃមេរៀន ឬក៏អត់ និងការរីកចម្រើនជារួមរបស់សិស្ស។ ម្យ៉ាងទៀតវាជួយប្រាប់ពីប្រសិទ្ធភាពនៃការបង្រៀន និងរៀន។ រង្វាយតម្លៃសរុបត្រូវបានប្រើ៖

- ដើម្បីជាការទទួលខុសត្រូវក្នុងការគ្រប់គ្រងថ្នាក់រៀន ការបង្រៀន និងរៀន
- ដើម្បីឱ្យសិស្សដឹងថាពួកគេសម្រេចបានតាមវត្ថុបំណងដែលបានកំណត់
- ដើម្បីវាយតម្លៃការបង្រៀន
- ដើម្បីឱ្យគ្រូបានដឹងពីចំណុចខ្លាំង និងចំណុចខ្វះខាតសម្រាប់ពិចារណាធ្វើផែនការបង្រៀន និងកែលម្អការបង្រៀននៅពេលអនាគត។

## គ. តារាងប្រៀបធៀបវាយតម្លៃតាមដំណាក់ និងវាយតម្លៃសរុប

| | អ្វី? | ហេតុអ្វី? | ដូចម្តេច? |
|---|---|---|---|
| វាយតម្លៃតាមដំណាក់ | ការវាយតម្លៃការរៀនមានលក្ខណៈបន្ថែម ផ្តែកទៅលើការឆ្លើយតប និងព័ត៌មានត្រឡប់ ក្នុងអំឡុងពេលរៀន។ | • ដើម្បីវិនិច្ឆ័យពីការរៀនរបស់សិស្ស។<br>• ដើម្បីដឹកនាំសិស្សឱ្យរីកចម្រើន។<br>• ផ្តល់ការលើកទឹកចិត្តដល់សិស្ស។<br>• លើកកម្ពស់ការបង្រៀន និងរៀន។<br>• វាយតម្លៃប្រសិទ្ធភាពខ្លឹមសារ វិធី លំនាំ និងល្បឿននៃការបង្រៀន។ | • សង្កេតជាប្រចាំ។<br>• ឯកសារ និងប្រវត្តិរបស់សិស្សម្នាក់ៗ។<br>• សង្កេតស៊ីជម្រៅ និងជាក់លាក់។<br>• តាមដានពីសកម្មភាពសិស្ស។<br>• ទំនាក់ទំនងជាមួយសិស្ស។ |
| វាយតម្លៃសរុប | • វាយតម្លៃពីកម្រិតប្រតិបត្តិនៅចុងបញ្ចប់នៃរយៈពេលមួយច្បាស់លាស់។ ឧទាហរណ៍ចុងបញ្ចប់ឆមាស។<br>• ផ្តែកទៅលើវត្ថុបំណង ឬស្តង់ដារគំរូ ដែលបានកំណត់។ | • ដើម្បីកំណត់កម្រិតជោគជ័យក្នុងការសម្រេចវត្ថុបំណង ។<br>• ដើម្បីវិនិច្ឆ័យនូវអ្វី ដែលសិស្សបានរៀន។<br>• ដើម្បីវាយតម្លៃពីប្រសិទ្ធភាពនៃកម្មវិធីសិក្សា ។ | • ប្រៀបធៀបកិច្ចការដែលបានបញ្ចប់ទៅនឹងគោលដៅ ដែលបានគ្រោង ។ |

# ៦.២. វាយតម្លៃកម្មវិធីបំណិនជីវិត

## ៦.២.១. សេចក្តីផ្តើម

ការវាយតម្លៃបំណិនជីវិត ផ្តោតលើការរីកចម្រើនរបស់កុមារក្នុងការអភិវឌ្ឍចំណេះដឹងជុំវិញខ្លួន បំណិនទូទៅ គុណតម្លៃផ្ទាល់ខ្លួន អាជីវកម្ម និងការងារ និងបច្ចេកទេស នៅក្នុងអំឡុងនៃការរៀនកម្មវិធីបំណិនជីវិត លើចំណុចសំខាន់ៗ ដូចខាងក្រោម៖

- ចំណេះដឹងទទួលបាន និងការប្រើប្រាស់ចំណេះដឹងសម្រាប់ខ្លួនឯង គ្រួសារ និងសហគមន៍។
- ការប្រតិបត្តិគឺសំដៅទៅលើការប្រមូលព័ត៌មានពីសហគមន៍ ការរៀបចំផែនការផ្សព្វផ្សាយ ឬផែនការអាជីវកម្ម ការអនុវត្តផែនការ ការឆ្លុះបញ្ចាំង និងវាយតម្លៃ។
- បំណិនទូទៅ និងគុណតម្លៃ ដែលសិស្សបានអភិវឌ្ឍ តាមរយៈការសិក្សាមេរៀនបំណិនជីវិតមានលក្ខណៈអនុវត្តជាក់ស្តែង ហើយឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគេ។
- អាជីវកម្ម ការងារ និងបច្ចេកទេស ដែលសិស្សបានអភិវឌ្ឍតាមរយៈហាត់ការ និងសិក្សាពីជំនាញជាក់លាក់ពីឯកសារពិគ្រោះយោបល់ និងគ្រូ។

## ៦.២.២. រង្វាយតម្លៃផ្លូវការ

ជាការវាយតម្លៃ ដែលតម្រូវឱ្យមានការកត់ត្រាលើការសិក្សារបស់សិស្សម្នាក់ៗចំពោះម៉ូឌុល ឬ មេរៀនទាំងមូល ដោយផ្តោតទៅលើការយល់ដឹងលើខ្លឹមសារមេរៀន និងការប្រើប្រាស់ចំណេះដឹងសម្រាប់ខ្លួនឯង គ្រួសារ និងសហគមន៍។ ការវាយតម្លៃក៏ត្រូវកំណត់រកឱ្យឃើញការប្រែប្រួលឥរិយាបថ បំណិន និងគុណតម្លៃផ្ទាល់ខ្លួន អាជីវកម្ម និងការងារ និងបច្ចេកទេស ដែលសិស្សបានអភិវឌ្ឍ និងសមត្ថភាពប្រើប្រាស់បំណិនទាំងនោះសម្រាប់ការសិក្សា និងការរស់នៅរបស់ពួកគេ។ រង្វាយតម្លៃផ្លូវការនេះ ផ្តោតលើកិច្ចការសំខាន់បីគឺ កិច្ចការទី ១ តេស្តចំណេះដឹង កិច្ចការទី ២ តេស្តប្រតិបត្តិ និងកិច្ចការទី ៣ សមិទ្ធផលសិក្សា។

### ក. លក្ខណៈវិនិច្ឆ័យ និងលក្ខខណ្ឌសម្រាប់វាយតម្លៃ

កិច្ចការទី១-តេស្តចំណេះដឹង៖ ជាតេស្តសរសេរបញ្ចប់ម៉ូឌុល ឬមេរៀន ដើម្បីពិនិត្យលើកម្រិតយល់ដឹងរបស់សិស្សលើខ្លឹមសារមេរៀន។ តេស្តសរសេរនេះផ្តោតលើ៖

| លក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃ | លក្ខខណ្ឌនៃវាយតម្លៃ |
|---|---|
| • គំនិតសំខាន់ៗដែលមាននៅក្នុងខ្លឹមសារមេរៀន។<br>• ការប្រើប្រាស់ចំណេះដឹង ដែលទទួលបានសម្រាប់ខ្លួនឯង។<br>• ការប្រើប្រាស់ចំណេះដឹង ដែលទទួលបានសម្រាប់គ្រួសារ និងសហគមន៍។ | • ការងារជាបុគ្គល<br>• មិនអនុញ្ញាតឱ្យពិភាក្សា និងចម្លងគ្នា |

កិច្ចការទី២-ការងារប្រតិបត្តិ៖ ផ្តល់ឱកាសឱ្យសិស្សអនុវត្តសកម្មភាពតាមរយៈការងារក្រុម ការងារក្នុងសហគមន៍ ការធ្វើបទបង្ហាញ ការសម្តែងតួជាដើម។ គ្រូក៏អាចពិនិត្យមើលសកម្មភាព និងឥរិយាបថរបស់សិស្សនៅក្នុងភូមិ និងសាលារៀនផងដែរ។ ការវាយតម្លៃនេះផ្តោតលើ៖

| លក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃ | លក្ខខណ្ឌនៃវាយតម្លៃ |
|---|---|
| បំណិន<br>• ការប្រាស្រ័យទាក់ទង<br>• ការដោះស្រាយបញ្ហា<br>• ការសម្រេចចិត្ត<br>• ការធ្វើផែនការនិងចាត់ចែង<br>• ការគ្រប់គ្រងពេលវេលា<br>• ការគិតបែបពិចារណា។ល។<br>អាជីវកម្ម និងការងារ<br>• ពិភពការងារ<br>• សញ្ញាណអាជីវកម្ម<br>• សញ្ញាណបច្ចេកទេស<br>គុណតម្លៃ<br>• ការឱ្យតម្លៃលើខ្លួនឯង<br>• ភាពស្មោះត្រង់<br>• ឥរិយាបថវិជ្ជមាន<br>• ការគ្រប់គ្រងកំហឹង<br>• ការទទួលខុសត្រូវ។ល។ | • ការស្តាប់ដោយយកចិត្តទុកដាក់ និងឆ្លើយតបដោយសមរម្យ<br>• ការរាប់អានគ្នាការចេះជួយគ្នា ឬភាពគ្មានទំនាស់<br>• ការគិតតាមបែបបំបែកគំនិត និងបណ្តុំគំនិត<br>• ការកំណត់រកវិធីផ្សេង ដើម្បីចៀសពីបញ្ហា<br>• ការជ្រើសរើសដោយផ្អែកលើព័ត៌មាន និងភស្តុតាងគ្រប់គ្រាន់<br>• ការរៀបចំផែនការច្បាស់លាស់<br>• ភាពប្រាកដប្រជា និងអាចធ្វើអ្វីមួយដោយខ្លួនឯង<br>• ការគិតវិជ្ជមាន និងចេះលើកទឹកចិត្តខ្លួនឯង<br>• ការទទួលស្គាល់ការពិត និងការកែលម្អ<br>• បើកចិត្តនិងគំនិតឱ្យបានទូលាយព្រមទាំងទទួលយកការរិះគន់ |

កិច្ចការទី៣-សមិទ្ធផលសិក្សា៖ សាលាអាចរៀបចំពិព័ណស្នាដៃសិស្ស ដើម្បីបង្ហាញសមិទ្ធផលសិក្សា រៀងរាល់ឆមាស ឬឆ្នាំទៅតាមលទ្ធភាពជាក់ស្តែង។ សិស្សអាចត្រៀមជារូបថត សមិទ្ធផល ឬការសម្តែងតួ ដើម្បីបង្ហាញដល់សហគមន៍ចំពោះដំណើរការ និងសមិទ្ធផល ដែលគេសម្រេចបានតាមរយៈការរៀនបំណិនជីវិត។ ការវាយតម្លៃក្រុមផ្តោតលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- ការរៀបចំចាត់ចែងពិព័ណស្នាដៃរបស់ក្រុមសិស្ស
- ការតាំងបង្ហាញសមិទ្ធផលរបស់ក្រុមសិស្ស
- ការធ្វើបទបង្ហាញ ឬការសម្តែងតួរបស់ក្រុមសិស្ស
- ការធ្វើការងារក្រុមរបស់សិស្ស

### ខ. របៀបប្រើប្រាស់ប័ណ្ណវាយតម្លៃផ្លូវការ

កិច្ចការទី១-តេស្តសរសេរ៖ ជាការធ្វើតេស្តលើចំណេះដឹងដូចមុខវិជ្ជាផ្សេងទៀត ដើម្បីយកពិន្ទុដាក់ក្នុងប័ណ្ណវាយតម្លៃការសិក្សារបស់សិស្សម្នាក់ៗ។ គ្រូអាចមើលគំរូខាងក្រោមដើម្បីធ្វើតេស្តសរសេរ និងកែកិច្ចការសិស្ស។ បន្ទាប់មកបម្លែងពិន្ទុទៅជារូបតំណាង៖ ពិន្ទុ ០-៤ ទៅជា ☹ ៥-៧ ទៅជា 😐 ៨-១០ ទៅជា ☺ ដើម្បីបញ្ចូលទៅក្នុងទម្រង់ប័ណ្ណវាយតម្លៃ (ឧបសម្ព័ន្ធ១.ក)។ ខាងក្រោមជាគំរូតេស្តសរសេរសម្រាប់មេរៀនបំណិនជីវិត ផ្នែកសង្គម (អំពើហិង្សាក្នុងគ្រួសារ)។ គ្រូអាចរៀបចំតេស្ត សម្រាប់មេរៀនបំណិនជីវិតអាជីពងាយ ដោយផ្តោតទៅលើបំណិនបច្ចេកទេស និងការគ្រប់គ្រងអាជីវកម្ម។

១. ចំណេះដឹងដែលទទួលបាន (១០ពិន្ទុ)

ក.តើមូលហេតុអ្វី ដែលបណ្ដាលឱ្យកើតមានអំពើហិង្សាក្នុងគ្រួសារ? (៣ពិន្ទុ)

.......................................................................................................................................................

ខ. តើការកើតមានអំពើហិង្សាក្នុងគ្រួសារបង្កឱ្យមានផលប៉ះពាល់អ្វីខ្លះ? (៣ពិន្ទុ)

.......................................................................................................................................................

គ. តើប្អូនគួរធ្វើយ៉ាងដូចម្ដេច ដើម្បីការពារកុំឱ្យកើតមានអំពើហិង្សាក្នុងគ្រួសារ? (៤ពិន្ទុ)

.......................................................................................................................................................

២. ការប្រើប្រាស់ចំណេះដឹងដែលទទួលបានសម្រាប់ខ្លួនឯង។ (១០ពិន្ទុ)

ឃ. តើប្អូនត្រូវធ្វើដូចម្ដេច ដើម្បីការពារខ្លួនអ្នកឱ្យចៀសផុតពីអំពើហិង្សាក្នុងគ្រួសារ?

.......................................................................................................................................................

៣. ការប្រើប្រាស់ចំណេះដឹងដែលទទួលបានសម្រាប់គ្រួសារ និងសហគមន៍ (១០ពិន្ទុ)

ង. តើប្អូនត្រូវធ្វើដូចម្ដេចដើម្បីការពារគ្រួសារ និងសហគមន៍របស់អ្នកឱ្យចៀសផុតពីអំពើហិង្សាក្នុងគ្រួសារ?

.......................................................................................................................................................

កិច្ចការទី២-ការងារប្រតិបត្តិ៖ ជាការបង្ហាញ ឬការប្រតិបត្តិផ្ទាល់របស់សិស្សក្នុងរូបភាពបុគ្គល ក្រុម ឬការងារគម្រោង។ តាមរយៈសកម្មភាពនេះ យើងអាចមើលឃើញសិស្សអភិវឌ្ឍបំណិន និងគុណតម្លៃរបស់គេ ដែលនឹងត្រូវកត់ត្រាក្នុងប័ណ្ណវាយតម្លៃ (ឧបសម្ព័ន្ធ១.ក)។ សិស្សប្រើប័ណ្ណវាយតម្លៃ ដើម្បីធ្វើស្វ័យវាយតម្លៃដោយប្រើខ្មៅដៃ ហើយគ្រូក៏ប្រើទម្រង់នេះ ដើម្បីវាយតម្លៃសិស្សម្នាក់ៗផងដែរ។

គ្រូណែនាំសិស្សពីការរៀនមេរៀនបំណិនជីវិត និងបំណិនដែលគេត្រូវអភិវឌ្ឍ រួចហើយចែកទម្រង់វាយតម្លៃខាងលើឱ្យសិស្សនៅដើមឆ្នាំសិក្សា។ សិស្សចាប់ផ្ដើមបំពេញទម្រង់ដោយប្រើខ្មៅដៃ រួចឆ្លុះបញ្ចាំងជាប្រចាំបន្ទាប់ពីរៀនមេរៀននីមួយៗ រហូតដល់ចុងឆ្នាំសិក្សា។

- សិស្សម្នាក់ៗធ្វើស្វ័យវាយតម្លៃរៀងៗខ្លួន(ឧបសម្ព័ន្ធ១.ក)ដោយឆ្លុះបញ្ចាំងលើសកម្មភាពដែលខ្លួនបានអនុវត្តដោយមិនត្រូវពិភាក្សា ឬមើលគ្នាឡើយ។ សិស្សអាចកែប្រែស្ថានភាពរបស់គេពីមិនពេញចិត្ត (☹) ទៅទទួលយកបាន (😐) ឬ ទៅពេញចិត្ត (☺) ទៅតាមវឌ្ឍនភាពរបស់ខ្លួន។
- គ្រូប្រមូលប័ណ្ណដែលសិស្សវាយតម្លៃខ្លួនឯង ដើម្បីយកមកប្រៀបធៀបជាមួយប័ណ្ណវាយតម្លៃរបស់ខ្លួន។ ក្នុងករណីដែលសិស្ស និងគ្រូមានលទ្ធផលខុសគ្នា គេត្រូវរកពេលដើម្បីពិភាក្សា។ ក្នុងអំឡុងពិភាក្សាសិស្ស និងគ្រូត្រូវយកអំណះអំណាង ដើម្បីបញ្ជាក់រហូតទទួលបានការព្រមព្រៀងមួយពីការដាក់ពិន្ទុ។ គ្រូអាចលើកជាឧទាហរណ៍ តាមរយៈការអង្កេតរបស់ខ្លួនទៅលើសិស្សនេះ ឬឱ្យសិស្សផ្ដល់ហេតុផលចំពោះការដាក់ពិន្ទុរបស់គេដើម្បីឲ្យសិស្សទទួលស្គាល់ការពិតពីសមិទ្ធផលរបស់គេជៀសវាងវាយតម្លៃខ្លួនទាប ឬហួសពីការពិត។ ការពិភាក្សាជាមួយសិស្សម្នាក់ៗមានរយៈពេលពី ១០ ទៅ ១៥នាទី។
- បន្ទាប់ពីពិភាក្សាជាមួយសិស្សរួច គេត្រូវកែលម្អនៅលើប័ណ្ណវាយតម្លៃរបស់គេរៀងៗខ្លួន ហើយគ្រូត្រូវស្រង់លទ្ធផលសរុបរបស់សិស្សដាក់ក្នុងតារាងវាយតម្លៃសង្ខេបរួម (ឧបសម្ព័ន្ធ១.គ ឬ ឃ) ។
- គ្រូគួររក្សាប័ណ្ណវាយតម្លៃការសិក្សា និងប័ណ្ណវាយតម្លៃរួម នៅក្នុងឯកម្រងស្នាដៃរបស់សិស្សម្នាក់ៗ។

កិច្ចការទី៣-សមិទ្ធផលសិក្សា៖ ផ្ដោតទាំងការវាយតម្លៃផ្លូវការ និងក្រៅផ្លូវការ។ ចំពោះការវាយតម្លៃផ្លូវការមានលំនាំដូចកិច្ចការទី២ ដោយប្រើតារាងវាយតម្លៃ ឧបសម្ព័ន្ធ១.ខ ហើយការវាយតម្លៃក្រៅផ្លូវការ (សូមមើលការវាយតម្លៃក្រៅផ្លូវការលម្អិតដូចខាងក្រោម)។

## ៦.២.៣. វាយតម្លៃក្រៅផ្លូវការ

ជាការវាយតម្លៃមានលក្ខណៈជាការសង្កេតរបស់គ្រូ ទៅលើសកម្មភាពរៀនសូត្ររបស់សិស្សប្រចាំថ្ងៃ ឬការឆ្លុះបញ្ចាំងលើសកម្មភាពរៀនដោយសិស្សខ្លួនឯង។ ការវាយតម្លៃផ្ដោតលើចំណេះដឹង និងការប្រើប្រាស់ចំណេះដឹងសម្រាប់ខ្លួនឯង គ្រួសារ និងសហគមន៍ ការប្រែប្រួលឥរិយាបថ បំណិន គុណតម្លៃផ្ទាល់ខ្លួន ដែលសិស្សបានអភិវឌ្ឍ និងសមត្ថភាពប្រើប្រាស់បំណិនទាំងនោះ សម្រាប់ការសិក្សា និងការរស់នៅរបស់គេម្នាក់ៗ។ ការវាយតម្លៃក្រៅផ្លូវការមិនត្រូវបានកត់ត្រាសម្រាប់វាយតម្លៃជាប់ធ្លាក់នោះទេ តែវាជួយធ្វើឱ្យការវាយតម្លៃផ្លូវការមានលក្ខណៈត្រឹមត្រូវ។

ស្វ័យវាយតម្លៃ៖ ការឆ្លុះបញ្ចាំងខ្លួនឯងគឺជាបំណិនជីវិតមួយចាំបាច់ និងមានសារៈសំខាន់ក្នុងការរៀនអំពីរបៀបនៃការរៀន។ ការធ្វើបែបនេះគឺជួយពួកគេឱ្យមានទំនួលខុសត្រូវលើការសិក្សារបស់គេ។ ម៉្យាងទៀតវាជាការផ្ដល់ឱកាសដល់សិស្សដើម្បីពិនិត្យវាយតម្លៃកិច្ចការផ្ទាល់ និងភាពរីកចម្រើនដែលពួកគេបានធ្វើ ហើយអាចកំណត់បានពីចំណុចល្អ និងចំណុចខ្វះខាតដែលពួកគេត្រូវកែលម្អ។ ស្វ័យវាយតម្លៃនេះមានលក្ខណៈក្រៅផ្លូវការដោយផ្ដោតលើការឆ្លុះបញ្ចាំងខ្លួនឯងលើចំណេះដឹង និងបំណិនដែលខ្លួនទទួលបានដូចជា បំណិនអន្តរបុគ្គល ការប្រាស្រ័យទាក់ទង ការគិតល្អិតល្អន់ ការដោះស្រាយបញ្ហា ការសម្រេចចិត្ត ការកំណត់គោលដៅ ទំនុកចិត្តលើខ្លួនឯង ការឱ្យតម្លៃលើខ្លួនឯង ការទទួលខុសត្រូវ និង ឥរិយាបថវិជ្ជមាន។

វាយតម្លៃដោយមិត្តភក្តិ៖ គ្រូអាចរៀបចំឱ្យសិស្សវាយតម្លៃគ្នាទៅវិញទៅមក ដែលសមស្របទៅនឹងសមត្ថភាព និងវ័យរបស់សិស្ស។ ពេលខ្លះសិស្សអាចចូលរួមក្នុងការអភិវឌ្ឍលក្ខណៈវិនិច្ឆ័យ ដើម្បីវាយតម្លៃទៅតាមភាពជាក់ស្ដែង។ សិស្សរៀនកំណត់ចំណុចខ្លាំង និងចំណុចដែលត្រូវកែលម្អ ព្រមទាំងផ្ដល់យោបល់ទៅលើការងាររបស់មិត្តភក្តិ ប្រកបដោយលក្ខណៈវិជ្ជមាន និងមានប្រយោជន៍។

វាយតម្លៃការងារក្រុម៖ មានវិធីជាច្រើន ដើម្បីជួយសិស្សឱ្យគិតអំពីរបៀប ដែលពួកគេធ្វើការងារជាមួយគ្នានៅក្នុងក្រុម។ វិធីមួយដែលប្រសើរ គឺការប្រើប្រាស់ទម្រង់វាយតម្លៃ ដែលអនុញ្ញាតឱ្យសិស្សសរសេរ និងឆ្លុះបញ្ចាំងពីបទពិសោធរបស់ពួកគេនៅក្នុងក្រុម។ សំណួរបីប្រភេទដែលត្រូវសួរ៖ ទី១ សំណួរអាចផ្ដោតទៅលើការប្រើប្រាស់បំណិនសហការជាក់លាក់មួយចំនួន ទី២ សំណួរអាចជំរុញឱ្យមានការលើកទឹកចិត្តដល់ការអនុវត្តបំណិនសហការ និងទី៣ សំណួរអាចផ្ដល់ឱកាសដល់សិស្ស ដើម្បីកំណត់គោលដៅសម្រាប់អនាគត។ ប៉ុន្តែពេលខ្លះគ្រូអាចសួរសំណួរផ្ទាល់មាត់ដើម្បីទទួលបានចម្លើយភ្លាមៗ។

វាយតម្លៃបុគ្គលម្នាក់ៗនៅក្នុងក្រុម៖ ជាលក្ខណៈវាយតម្លៃមួយ ដែលតម្រូវឱ្យសមាជិកក្រុមម្នាក់ៗធ្វើដើម្បីឆ្លុះបញ្ចាំងអន្តរកម្ម ការចូលរួម ការផ្ដល់ឱកាសឱ្យគ្នា ការជំរុញ ការលើកទឹកចិត្តសមាជិក ដទៃទៀតនៅក្នុងក្រុម ការផ្ដល់គំនិត និងព័ត៌មានដែលមានទៅឱ្យសមាជិកផ្សេងទៀតក្នុងគោលបំណងលើកកម្ពស់ កែលម្អ និងអភិវឌ្ឍសមត្ថភាពសមាជិកក្រុម ។

វាយតម្លៃតាមរយៈការសង្កេត និងជួបពិភាក្សា៖ ជាការវាយតម្លៃដែលកើតមានឡើង តាមរយៈការសង្កេតរបស់គ្រូលើបំណិនទូទៅ និងគុណភាពផ្ទាល់ខ្លួនរបស់សិស្សម្នាក់ៗ ដែលគេបានអភិវឌ្ឍតាំងពីពេលចាប់ផ្ដើមរៀនបំណិនជីវិតរហូតដល់ចប់មេរៀនទាំងមូល ដើម្បីធ្វើការប្រៀបធៀបពីភាពខុសគ្នា រវាងការវាយតម្លៃដែលសង្កេតដោយគ្រូ និងស្វ័យវាយតម្លៃខ្លួនឯងដែលធ្វើឡើងដោយសិស្សខ្លួនឯង។ ការវាយតម្លៃនេះតម្រូវឱ្យគ្រូ និងសិស្សជួបពិភាក្សាគ្នាពិនិត្យលើ

លទ្ធផលវាយតម្លៃរបស់គេ ក្នុងករណីមានភាពខុសគ្នាខ្លាំង។ ការវាយតម្លៃនេះមិនផ្តោតលើការខុសត្រូវប៉ុន្មានទេ គឺគ្រាន់តែពិភាក្សារកមូលហេតុនៃការដាក់ពិន្ទុខុសគ្នាប៉ុណ្ណោះ ដើម្បីធ្វើឱ្យការវាយតម្លៃនេះមានលក្ខណៈសមស្រប។

រង្វាយតម្លៃនៅចុងបញ្ចប់ដំណាក់កាលនីមួយៗ៖ ជាការតាមដានការរីកចម្រើនរបស់សិស្សជាប្រចាំពីសកម្មភាពមួយទៅសកម្មភាពមួយ។ ការវាយតម្លៃតាមដំណាក់ធ្វើឡើង ដោយគ្រូនៅពេលបង្រៀនចប់ដំណាក់កាលនីមួយៗ ដើម្បីត្រួតពិនិត្យលើការយល់ដឹងខ្លឹមសារមេរៀនបំណិន ដែលបានអភិវឌ្ឍ ការប្រែប្រួលឥរិយាបថក្នុងបំណងធ្វើយ៉ាងណាលើកកម្ពស់ប្រសិទ្ធភាពនៃការបង្រៀន និងរៀនថ្នាក់បំណិនជីវិតក្នុងដំណាក់កាលនីមួយៗ។

ក្រៅពីការសង្កេតសកម្មភាពប្រចាំថ្ងៃរបស់សិស្ស គ្រូអាចប្រើប័ណ្ណវាយតម្លៃ សម្រាប់ការវាយតម្លៃក្រៅផ្លូវការនៅចុងបញ្ចប់នៃដំណាក់កាលនីមួយៗនៃមេរៀនជាលក្ខណៈបុគ្គល និងក្រុម ដោយប្រើប័ណ្ណវាយតម្លៃគំរូដូចជា៖ ១. ការវាយតម្លៃពីឥរិយាបថរបស់សមាជិកនៅក្នុងក្រុម ២. ការវាយតម្លៃការងារក្រុមពីចំណុចចូលចិត្ត និងចំណុចកែលម្អ ៣. ការគិតអំពីក្រុមរបស់ខ្ញុំ ៤.តារាងត្រួតពិនិត្យក្រុម (ឧបសម្ព័ន្ធទី២) ទៅតាមស្ថានភាពជាក់ស្តែង និងតម្រូវការក្នុងការទទួលព័ត៌មាន ពីការរីកចម្រើនលើគ្រប់ផ្នែកទាំងអស់របស់សិស្ស។

### ក. លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ

- ពិនិត្យមើលពីឥរិយាបថរបស់គេចំពោះសមាជិកម្នាក់ៗនៅក្នុងក្រុម
- ពិនិត្យមើលពីចំណូលចិត្ត និងចំណុចត្រូវកែលម្អសម្រាប់ការងារក្រុម
- ពិនិត្យមើលពីកម្រិតនៃការចូលរួមរបស់គេឬការចូលរួមរបស់សមាជិកដទៃទៀតចំពោះការងារក្រុម និងហេតុការណ៍ផ្សេងៗដែលកើតមាននៅក្នុងក្រុម។

### ខ. របៀបប្រើប្រាស់ប័ណ្ណវាយតម្លៃក្រៅផ្លូវការ

- គ្រូត្រូវជ្រើសរើសយកទម្រង់ប័ណ្ណណាមួយក្នុងចំណោមទម្រង់ប័ណ្ណវាយតម្លៃក្រៅផ្លូវការទាំង៤ (ឧបសម្ព័ន្ធទី២ ) ចែកឱ្យសិស្សម្នាក់ៗបំពេញរៀងៗខ្លួន ដោយមិនឱ្យពិភាក្សាគ្នាឬមើលគ្នាឡើយ ចំពោះទម្រង់ក-គ។ ដោយឡែកសម្រាប់ទម្រង់ ឃ សិស្សពិភាក្សាជាក្រុមធ្វើការវាយតម្លៃការងារក្រុមរបស់ពួកគេរួមគ្នា។
- គ្រូត្រូវប្រមូលប័ណ្ណទាំងនោះយកមកអានស្វែងយល់ និងស្រង់ចំណុចសំខាន់ៗសម្រាប់រៀបចំកែលម្អ និងជួយសិស្សក្នុងការអភិវឌ្ឍការងារក្រុមឱ្យកាន់តែប្រសើរ។

## ៧ ការចូលរួមរបស់សហគមន៍ និងអាជ្ញាធរមូលដ្ឋាន

កម្មវិធីបំណិនជីវិតតាមមូលដ្ឋានគឺជា ការអប់រំមួយប្រភេទ ដែលបំពេញបន្ថែមទៅលើកម្មវិធីជាតិ ហើយឆ្លើយតបទៅនឹងតម្រូវការរបស់សិស្ស។ កម្មវិធីនេះបង្កើតឡើងដោយសាលារៀន និងសហគមន៍ ដោយអនុឡោមតាមក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស។ ដើម្បីទទួលបានជោគជ័យ នាយកសាលាត្រូវរៀបចំការតម្រង់ទិសកម្មវិធីបំណិនជីវិតតាមមូលដ្ឋានដល់ភាគីពាក់ព័ន្ធ ដូចជាមន្ត្រីជំនាញ កសិករ និងអាជីវករគំរូ អង្គការក្រៅរដ្ឋាភិបាល និងអ្នកជំនាញផ្សេងទៀតនៅក្នុងសហគមន៍ ព្រមទាំងអាជ្ញាធរមូលដ្ឋាន។

## ហេតុអ្វីបានជាតម្រូវឱ្យមានអ្នកជំនាញមូលដ្ឋានចូលរួមក្នុងកម្មវិធីបំណិនជីវិត?

### ១

សាលារៀនជាផ្នែកមួយរបស់សហគមន៍។ ដូចនេះ បើការអប់រំមានការចូលរួមពីសហគមន៍ និងគាំទ្រពីអាជ្ញាធរមូលដ្ឋាន វានឹងធ្វើឱ្យការអប់រំនោះទទួលបានជោគជ័យ។ ជាលទ្ធផល វាក៏រួមចំណែកធ្វើឱ្យសហគមន៍ និងអាជ្ញាធរមូលដ្ឋានទទួលបានជោគជ័យ។

### ២

កម្មវិធីបំណិនជីវិតតាមមូលដ្ឋានឆ្លើយតបទៅបញ្ហាប្រឈម និងតម្រូវការដែលមានក្នុងមូលដ្ឋាន ហើយសិស្សត្រូវតែមានសមត្ថភាព និងបំណិនដើម្បីឆ្លើយតប។ បញ្ហាប្រឈម និងតម្រូវការទាំងនោះអាចជាប្រធានបទ (គំរូសង្គម និងគំរូអាជីព) ដើម្បីឱ្យសិស្សស្វែងយល់ អភិវឌ្ឍចំណេះដឹង រាល់បញ្ហាជុំវិញខ្លួន រួមគ្នាដោះស្រាយបញ្ហា បង្កើតឱកាសថ្មី និងត្រៀមខ្លួនចូលទៅក្នុងទីផ្សារការងារ។

### ៣

នៅក្នុងសហគមន៍មានធនធានជាច្រើន ដែលធនធាន និងជំនាញទាំងនោះមិនបានប្រើប្រាស់ឱ្យអស់លទ្ធភាព និងមានប្រសិទ្ធភាព ព្រមទាំងពង្រឹងសាមគ្គីភាព និងការចែករំលែកបទពិសោធនៅក្នុងសហគមន៍។ ធនធានទាំងនោះមានដូចជា ជនបង្គោលឃុំសម្រាប់ស្ត្រី និងកុមារ ចាស់ព្រឹទ្ធាចារ្យ កសិករគំរូ ប៉ូលីស អ្នកជោគជ័យ ឬបរាជ័យក្នុងជីវិត មន្ត្រីសុខភាពឃុំ មន្ត្រីកសិកម្ម មន្ត្រីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងមន្ត្រីអង្គការក្រៅរដ្ឋាភិបាល។ល។ អ្នកទាំងអស់នេះអាចចែករំលែកបទពិសោធ និងចំណេះដឹងរបស់ពួកគេ ដល់សិស្សនៅក្នុងកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន។

### ៤

ក្រសួងអប់រំ យុវជន និងកីឡាមិនអាចបណ្តុះបណ្តាលគ្រូឱ្យឆ្លើយតបទៅតាមតម្រូវការ តាមមូលដ្ឋាននីមួយៗឡើយ។ ក្រសួងអាចបណ្តុះបណ្តាលគ្រូពីដំណើរការបង្រៀន និងរៀនបំណិនជីវិត ហើយសហការជាមួយអ្នកជំនាញតាមមូលដ្ឋាន ដើម្បីផ្តល់ការអប់រំបំណិនជីវិតដល់សិស្សទៅតាមប្រធានបទ ដែលមានជាក់ស្តែងនៅក្នុងសហគមន៍។

# ឧបសម្ព័ន្ធ

# ដំណាក់កាលទី១៖ ការស្វែងយល់ប្រធានបទ

## I. សេចក្តីផ្តើម

ដោយសារកម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋានផ្តោតទៅលើតម្រូវការនិងចំណាប់ចំណូលចិត្តរបស់សិស្សនៅតាមសហគមន៍របស់គេ គ្រូត្រូវដឹងថាសិស្សមានចំណេះដឹងច្រើនពាក់ព័ន្ធទៅនឹងប្រធានបទដែលត្រូវរៀន។ លើសពីនេះទៀតមន្រ្តីសង្គមកិច្ច សុខាភិបាល អាជីវករ... នៅក្នុងសហគមន៍ជាធនធាន ដែលគ្រូអាចប្រើប្រាស់ក្នុងការកសាងចំណេះដឹង និងស្វែងយល់ពីប្រធានបទ។

## II. គោលបំណង

សិស្សកំណត់បាននូវអ្វីដែលគេចេះស្រាប់ និងមធ្យោបាយផ្សេងៗក្នុងការបង្កើនចំណេះដឹងរបស់ខ្លួនចំពោះប្រធានបទដែលបានជ្រើសរើស។

## III. បំណិនសំខាន់ៗដែលត្រូវអភិវឌ្ឍ

បំណិនស្រាវជ្រាវ បំណិនទំនាក់ទំនង បំណិនអន្តរបុគ្គល ការរៀបចំចាត់ចែងលើប្រធានបទឱ្យកាន់តែស៊ីជម្រៅ ការឱ្យតម្លៃខ្លួនឯងនិងសហគមន៍ និងការទទួលខុសត្រូវ។

## IV. ល្បិចបង្រៀន

គ្រូមិនគ្រាន់តែយកសកម្មភាពទាំងអស់ទៅបង្រៀននោះទេ។ គ្រូត្រូវដឹងច្បាស់ថាតើត្រូវរៀបចំសកម្មភាពណាខ្លះដើម្បីឱ្យសិស្សយល់ច្បាស់ពីប្រធានបទ។

### សកម្មភាពទី១៖ ការបំផុសគំនិត



## សេចក្តីផ្តើម

ការបំផុសគំនិតគឺជាវិធីសាស្ត្រដើម្បីប្រមូលគំនិតឱ្យបានច្រើន ពាក់ព័ន្ធទៅនឹងប្រធានបទជាក់ស្តែង។ គ្រូឱ្យសិស្សបញ្ចេញគំនិតរបស់គេ មិនថាគំនិតនោះប្លែកចាកឆ្ងាយពីប្រធានបទ ឬយល់ឃើញថាគំនិតនោះមិនអាចទទួលយកបានក៏ដោយ។ ល្បិចបង្រៀននេះ គឺដើម្បីប្រមូលគំនិតឱ្យបានច្រើនក្នុងរយៈពេលដ៏ខ្លីមួយ និងផ្តល់ឱ្យគ្រូនូវចំណាប់អារម្មណ៍ភ្លាមៗថា តើកុមារប៉ុន្មាននាក់ដែលយល់ដឹងពាក់ព័ន្ធទៅនឹងប្រធានបទ។ វិធីនេះគេប្រើដើម្បីបំផុសគំនិតចំពោះអ្វីដែលសិស្សពុំទាន់ដឹង និងអ្វីដែលសិស្សបានដឹងអំពីប្រធានបទ។ ម៉្យាងវិញទៀតយើងអាចនិយាយថាគឺជាការធ្វើសំយោគគំនិតអំពីអ្វីដែលកុមារចង់ដឹង។

## វិធានក្នុងការបំផុសគំនិត៖

- ការបំផុសគំនិតលើប្រធានបទ ត្រូវឱ្យកុមារទាំងអស់បានចូលរួមដោយផ្តោតការយកចិត្តទុកដាក់ពិសេសចំពោះកុមារនៅខាងក្រោយឬកុមារដែលស្ងៀមស្ងាត់ ។
- លើកទឹកចិត្តសិស្សឱ្យនិយាយនូវអ្វីដែលគេគិត ដើម្បីចែករំលែកគំនិតទាំងនោះជាមួយសិស្សដទៃទៀតក្នុងថ្នាក់។
- មិនត្រូវរិះគន់ សើចចំអកដល់គំនិត ឬបញ្ឈប់គំនិតរបស់កុមារឡើយ។
- កត់ត្រារាល់គំនិតទាំងអស់ ដែលបានលើកឡើង និងមិនត្រូវពិភាក្សា ឬវាយតម្លៃគំនិតដែលបានបង្កើតឡើង ប៉ុន្តែត្រូវស្តាប់គ្នាទៅវិញទៅមក។
- បន្ទាប់ពីប្រមូលគំនិតចប់អ្នកអាចពិភាក្សា ដាក់គំនិតជាក្រុម ឬលុបគំនិតមួយចំនួនចោលទៅតាមតម្រូវការនៃសកម្មភាព ។

## វិធីប្រតិបត្តិដើម្បីអនុវត្តការបំផុសគំនិត៖

វិធីច្រើនដូចខាងក្រោម អ្នកអាចយកទៅធ្វើការបំផុសគំនិត៖

- សរសេរសំណួរ «តើយើងដឹងអ្វីខ្លះអំពីឈ្មោះប្រធានបទ?» ជាអក្សរធំលើក្តារខៀន។ គូសរង្វង់មូលលើវា ហើយគូសសញ្ញាព្រួញខ្លះៗចេញពីរង្វង់នោះ។ សួរសិស្សថា តើគេដឹងអ្វីខ្លះអំពីប្រធានបទ។ នៅពេលដែលគេផ្តល់គំនិតអ្វីមួយ សរសេរវាជុំវិញប្រធានបទ(រង្វង់)នោះហើយបន្ទាប់មកបានគំនិតមែកធាងជាច្រើន។
- ឬសរសេរ «តើយើងដឹងអ្វីខ្លះអំពីឈ្មោះប្រធានបទ?» ជាអក្សរធំលើក្តារខៀន។ ទុកពេលឱ្យសិស្ស ២-៣នាទីដើម្បីកត់ត្រាគំនិតដោយខ្លួនឯង។ ក្រោយមកប្រមូលគំនិតរបស់គេដាក់លើក្តារខៀន។
- ឬធ្វើដូចខាងលើ ប៉ុន្តែកុមារត្រូវធ្វើការងារជាក្រុមតូចៗ។
- សកម្មភាពបំផុសគំនិតនេះ អាចធ្វើនៅលើក្រដាសផ្ទាំងធំ ដែលអាចប្រើប្រាស់នៅមេរៀនបន្ទាប់ទៀត ដោយប្រើជាឯកសារយោង ឬបំពេញបន្ថែមនូវគំនិតថ្មីនៅលើក្រដាសផ្ទាំងធំនោះ។

## សកម្មភាពទី២៖ ការអញ្ជើញអ្នកមានបទពិសោធមកផ្តល់បទឧទ្ទេស

### សេចក្តីផ្តើម

ការអញ្ជើញអ្នកមានបទពិសោធមកឧទ្ទេស បង្ហាញសិស្សពីប្រធានបទជាក់លាក់មួយ អាចធ្វើឱ្យសិស្សទទួលបានព័ត៌មានបន្ថែមដែលគួរឱ្យចាប់អារម្មណ៍ និងមានអន្តរកម្មល្អប្រសើរ។ ការអញ្ជើញអ្នកមានបទពិសោធមកនិយាយធ្វើឱ្យសិស្សអភិវឌ្ឍបំណិនក្នុងការសួរ ស្តាប់ និងឆ្លើយតបចំពោះព័ត៌មានតាម លក្ខណៈជាក់ស្តែង។ វាគ្មិនក៏អាចដើរតួជាគំរូមួយបានដែរ ជាពិសេស នៅពេលដែលវាគ្មិនជាមិត្តភក្តិរបស់គេត្រូវបានអញ្ជើញឱ្យបង្ហាញនូវយោបល់ និងបទពិសោធរបស់គេទៅលើប្រធានបទជាក់លាក់មួយ ។

### វិធានក្នុងការអញ្ជើញ៖

- ត្រូវមានទំនាក់ទំនងភ្ញៀវជាមុន កំណត់កាលវិភាគជាមួយភ្ញៀវឱ្យបានច្បាស់លាស់ និងគំនិតសំខាន់ៗដែលគួរនិយាយជាដើម។
- ត្រូវអញ្ជើញភ្ញៀវជាមុន ដើម្បីដឹងថាតើគាត់អាចចូលរួមបានឬទេ។
- មិនត្រូវបង្ខំភ្ញៀវឱ្យចូលរួមនិយាយលើប្រធានបទ ដែលគេយល់ថាគេមិនមានទំនុកចិត្តក្នុងការ និយាយ ឬមិនត្រូវបង្ខំគេឱ្យនិយាយនូវរឿងរ៉ាវ ដែលពាក់ព័ន្ធផ្លូវចិត្ត ដូចជាអំពើហិង្សាក្នុងគ្រួសារជាដើម។ ត្រូវព្យាយាមអញ្ជើញភ្ញៀវណា ដែលអ្នកគិតថាគាត់អាចធ្វើឱ្យកុមារចាប់អារម្មណ៍និង អាចលើកទឹកចិត្តកុមារបានប្រសិន។ បើភ្ញៀវនិយាយតែម្នាក់ឯងទៅកាន់សិស្សនោះនឹងធ្វើឱ្យសិស្សធុញ ឬមិនចាប់អារម្មណ៍ចំពោះប្រធានបទ ហើយអាចធ្វើឱ្យវត្ថុបំណងនោះមិនអាចសម្រេចបាន ព្រមទាំងធ្វើឱ្យប៉ះពាល់ដល់មេរៀនទាំងមូលទៀតផង។
- សួរសិស្សថាតើអ្នកស្គាល់ភ្ញៀវ ឬវាគ្មិនណាម្នាក់ ដែលអ្នកចង់អញ្ជើញឱ្យមកបង្ហាញអំពីប្រធានបទនេះទេ។ គ្រូក៏អាចផ្តល់ជម្រើសឱ្យពួកគេក្នុងការជ្រើសរើសភ្ញៀវ ឬវាគ្មិនផងដែរ។
- ត្រូវប្រាកដថាបានផ្តល់ព័ត៌មានដល់នាយកសាលា និងទទួលការអនុញ្ញាតរួចហើយ។
- ស្នើសុំឱ្យមេឃុំសង្កាត់ ឬមេភូមិឱ្យជួយអញ្ជើញភ្ញៀវ។
- ត្រូវប្រាកដថាផ្តល់ព័ត៌មានអំពីប្រធានបទដល់ភ្ញៀវ និងប្រាប់ពីកាលបរិច្ឆេទ ព្រមទាំងអ្នកស្តាប់ (មុខសញ្ញាសិស្ស) និងវត្ថុបំណងនៃសកម្មភាព ដើម្បីឱ្យគាត់អាចត្រៀមលក្ខណៈបានល្អ។
- រំលឹកភ្ញៀវពីកាលបរិច្ឆេទដែលជិតមកដល់ ដើម្បីកុំឱ្យកុមារអន់ចិត្តក្នុងករណីភ្ញៀវដែលមិនបានមក ឬប្រសិនជាគេភ្លេច។
- ដឹងឱ្យច្បាស់នូវតម្រូវការដែលពាក់ព័ន្ធក្នុងការអញ្ជើញភ្ញៀវ។ ភ្ញៀវខ្លះគេប្រហែលជាទាមទារ សោហ៊ុយក្នុងការធ្វើដំណើរ ប្រសិនជាគាត់នៅតំបន់ឆ្ងាយ ហើយប្រហែលជាពុំសូវមានពេលវេលាច្រើនទៀតផង។
- ត្រូវឱ្យកុមារអរគុណចំពោះភ្ញៀវ ហើយចាត់ចែងឱ្យកុមារសរសេរជាលិខិតថ្លែងអំណរគុណ និងចែករំលែកនូវអ្វីដែលគេបានរៀនជាមួយភ្ញៀវ។ ភ្ញៀវដែលបានមកធ្វើបទឧទ្ទេសលើកនេះ អាចនឹងអញ្ជើញត្រឡប់មកជាថ្មីម្តងទៀតនៅជំហានទី៥ (ការអនុវត្តផែនការនៅតាមសហគមន៍) ។

## វិធីប្រតិបត្តិដើម្បីអនុវត្តការផ្តល់បទឧទ្ទេសៈ

វិធីច្រើនដែលគេអាចយកទៅអនុវត្តក្នុងពេលឧទ្ទេសៈ

- ប្រាប់កុមារអំពីភ្ញៀវដែលនឹងមកជួបពួកគេពី (ឈ្មោះអាយុ ភេទ ប្រវត្តិរូប បទពិសោធ និងមូលហេតុដែលអ្នកជ្រើសរើសគាត់មកធ្វើបទឧទ្ទេស)។
- ឱ្យកុមារគិតរកសំណួរមុនពេលចាប់ផ្តើមមេរៀន ដែលគេចង់សួរទៅកាន់ភ្ញៀវដែលបង្ហាញអំពីប្រធានបទ។
- ឱ្យកុមារអានអត្ថបទអំពីប្រធានបទ ដើម្បីបង្កើតសំណួរដែលគេចង់សួរភ្ញៀវ ។
- បន្ទាប់ពីភ្ញៀវចាកចេញទៅគ្រូអាចឱ្យសិស្សពិភាក្សាសំណួរចម្លើយ និងពិភាក្សាពីអ្វីដែលគេបានរៀនសូត្រពីភ្ញៀវទាំងខ្លឹមសារ និងបំណិនលើការបង្ហាញ ។

## តើនរណាអាចធ្វើជាវាគ្មិនសម្រាប់កុមារ?

- អ្នកមានជំនាញលើប្រធានបទអាចជាមន្ត្រីរាជរដ្ឋាភិបាល ឬក្រុមការងារឃុំសង្កាត់ដែលធ្វើការលើបញ្ហាសុខភាព បញ្ហាសង្គម នាយកគ្រូបង្រៀន ព្រះសង្ឃ។ល។
- បុគ្គលិកអង្គការដែលយល់អំពីការងារអប់រំ និងប្រធានបទដែលពាក់ព័ន្ធ។
- សមាជិកសហគមន៍ដែលមានបទពិសោធ និងបញ្ហាផ្ទាល់ខ្លួនដែលពាក់ព័ន្ធទៅនឹងប្រធានបទ (បញ្ហាពាក់ព័ន្ធទៅនឹងអនាម័យ និងសុខភាព ការបោះឆ្នោតឃុំសង្កាត់។ល។)
- កុមារក្នុងសហគមន៍ ដែលមានបទពិសោធទាក់ទងទៅនឹងប្រធានបទ (ចំណាកស្រុកទៅធ្វើការនៅភ្នំពេញក្នុងរោងចក្រកាត់ដេរ កុមារ/យុវជនដែលបោះបង់ចោលសាលា យុវជនដែលកំពុងធ្វើការងារជាដើម។)

# សកម្មភាពទី៣៖ គម្រោងស្រាវជ្រាវងាយៗ

## សេចក្តីផ្តើម

ការស្រាវជ្រាវងាយៗ គឺជាសកម្មភាពទាំងឡាយណា ដែលមានគោលបំណងប្រមូលព័ត៌មានសំខាន់ៗ អំពីប្រធានបទ ដែលគេអាចប្រើប្រាស់នៅពេលក្រោយបាន។ ការស្រាវជ្រាវងាយៗ គឺជាសកម្មភាពខ្លីៗ ហើយសាមញ្ញ ដែលមិនចាំបាច់ចំណាយពេលច្រើនធ្វើផែនការ ធ្វើការវិភាគវែងឆ្ងាយ និងមិនមានភាពសាំញ៉ាំ។ ការអនុវត្តសកម្មភាពស្រាវជ្រាវងាយៗទាំងនេះ ផ្តល់ឱកាសដល់កុមារក្នុងការទទួលយកបទពិសោធក្នុងការស្រាវជ្រាវប្រមូលព័ត៌មាន ដែលមានស្រាប់ និងអភិវឌ្ឍការយល់ដឹងពីប្រភពធនធានផ្សេងៗនៃព័ត៌មានក្នុងសហគមន៍។

## វិធាននៃសកម្មភាពស្រាវជ្រាវងាយៗក្នុងសហគមន៍៖

- ត្រូវត្រៀមប្រភពព័ត៌មានជាស្រេច ហើយឱ្យកុមារទាំងអស់បានដឹងពីប្រភពព័ត៌មានទាំងនោះ។
- ត្រូវប្រាកដថា កុមារមានជំនឿចិត្តក្នុងការអនុវត្តសកម្មភាពស្រាវជ្រាវងាយៗនេះ។
- មិនត្រូវធ្វើឱ្យកុមារមានសម្ពាធក្នុងការអនុវត្តសកម្មភាពស្រាវជ្រាវឡើយ ឬមិនត្រូវបង្ខំសិស្សធ្វើឱ្យសិស្សខឹងឡើយ ប្រសិនជាកុមារមិនអាចប្រមូលទិន្នន័យ ដែលអាចជឿជាក់បាន។
- មិនត្រូវឱ្យសិស្សរៀបចំសំណួរច្រើនពេកទេ (អតិបរិមាចំនួន ៦សំណួរ គឺគ្រប់គ្រាន់ )។

- ផ្តល់ឱកាស ឱ្យសិស្សហ្វឹកហាត់ធ្វើការអនុវត្តសកម្មភាពស្រាវជ្រាវជាមួយមិត្តភក្តិក្នុងថ្នាក់រៀនរបស់គេ រៀបចំសិស្សឱ្យមានសុជីវធម៌ក្នុងការនិយាយទៅកាន់អ្នកផ្តល់ព័ត៌មាន និងត្រូវពន្យល់ពីគោល បំណងនៃការធ្វើសម្ភាស និងការស្រាវជ្រាវរបស់គេ។
- ជូនពរឱ្យសិស្សមានសំណាងល្អមុនពេលចុះស្រាវជ្រាវ និងទទួលបាននូវបទពិសោធល្អ ព្រមទាំងទទួលបាននូវភាពសប្បាយរីករាយក្នុងការងារនេះ។
- លើកទឹកចិត្តសិស្សឱ្យព្យាយាមធ្វើឡើងវិញ ប្រសិនបើការធ្វើលើកទី១ មិនបានទទួលជោគជ័យ ដោយពន្យល់ថាការងារនេះនឹងបានប្រសើរនៅពេលក្រោយ។
- មិនត្រូវឱ្យសិស្សអានលទ្ធផលដែលទទួលបាន បន្ទាប់ពីការស្រាវជ្រាវម្តងម្នាក់ៗនៅក្នុងថ្នាក់រៀនឡើយ ព្រោះវានាំឱ្យខាតពេលវេលា សិស្សធុញទ្រាន់ និងធ្វើឱ្យបាត់បង់ឱកាសរបស់គេក្នុងការប្រើប្រាស់ព័ត៌មាន ដែលគេបានប្រមូល។

## វិធីប្រតិបត្តិដើម្បីអនុវត្តសកម្មភាពស្រាវជ្រាវងាយៗ៖

ការរៀបចំសកម្មភាពស្រាវជ្រាវងាយៗដូចជា៖

- បំផុសគំនិតរកប្រភពអ្នកផ្តល់ព័ត៌មានលើប្រធានបទជាក់លាក់មួយ (អ្នកភូមិ កុមារ មន្ត្រីរាជរដ្ឋាភិបាល ឯកសារក្នុងបណ្ណាល័យ វិទ្យុ ទូរទស្សន៍។ល។)។
- សួរសិស្សថាតើពួកគេចង់រកប្រភេទព័ត៌មានបែបណា?
- ឱ្យសិស្សកំណត់នូវប្រភពព័ត៌មាន ដែលល្អបំផុតសម្រាប់ប្រធានបទដែលបានជ្រើសរើស ហើយវាជាវិធីមួយងាយបំផុតក្នុងការអនុវត្ត ដើម្បីស្វែងរកព័ត៌មានដែលគេត្រូវការ។
- នៅពេលសិស្សសម្រេចយកប្រភេទព័ត៌មាន ដែលគេចង់បាន និងប្រភពដែលល្អបំផុត សិស្សអាចចាប់ផ្តើមធ្វើផែនការសកម្មភាពស្រាវជ្រាវ។
- ជាដំបូង ឱ្យសិស្សអភិវឌ្ឍកម្រងសំណួរ ដោយផ្អែកលើអ្វីដែលគេបានរកឃើញ។
- ត្រូវចងចាំថាគួរតែមានសំណួរយ៉ាងច្រើនបំផុតចំនួន៦សំណួរសម្រាប់សិស្សម្នាក់ៗ។សិស្សម្នាក់ៗអាចប្រមូលព័ត៌មានខុសៗគ្នាលើប្រធានបទជាក់លាក់មួយ។
- បន្ទាប់មកទៀត ឱ្យសិស្សធ្វើតារាងវាយឈ្មោះពីប្រភពព័ត៌មាន ដែលរកបានសម្រាប់សំណួរនីមួយៗ។ ពេលខ្លះវាពិតជាសំខាន់ណាស់ក្នុងការដែលមានប្រភពព័ត៌មានមួយ ចំនួនដាក់ក្នុងតារាង ដើម្បីឱ្យសិស្សអាចមានជម្រើសនៅពេលប្រមូលទិន្នន័យ (សូមមើលគំរូតារាងឈ្មោះ ប្រភពប្រមូលទិន្នន័យ)។
- ត្រូវប្រកាសដល់សិស្សទាំងអស់ថាវាមិនមែនជាការសំខាន់ ក្នុងការប្រមូលព័ត៌មានឱ្យបានច្រើនតាម ដែលអាចធ្វើទៅបានលើប្រធានបទនោះទេ។ ប៉ុន្តែវាជាការប្រសើរណាស់បើយើងមាន ព័ត៌មានតិចតែមានគុណភាពគ្រប់គ្រាន់ល្អ។
- ឱ្យសិស្សហ្វឹកហាត់សួរសំណួរនៅក្នុងថ្នាក់រៀន មុនពេលគេចេញទៅសហគមន៍។ វាកាន់តែប្រសើរទៅទៀត ប្រសិនបើមានគំរូឱ្យសិស្សធ្វើដោយជ្រើសរើសនរណាម្នាក់នៅក្នុងសាលា ឬនៅក្នុងសហគមន៍។

## ការប្រើប្រាស់ព័ត៌មាន

នៅពេលដែលសិស្សប្រមូលព័ត៌មានបានហើយមានវិធីជាច្រើនដើម្បីជួយឱ្យពួកគេចេះប្រើប្រាស់ហើយអាចបង្ហាញព័ត៌មាននោះត្រឡប់វិញបាន។ វិធីទាំងនេះមានដូចជា ៖

- ឱ្យគេធ្វើការងារជាក្រុម ហើយឱ្យគេផ្លាស់ប្តូរព័ត៌មានដែលប្រមូលបាន។
- បន្ទាប់មកទៀត សមាជិកតាមក្រុមនឹងអាចសរសេរប្រភេទព័ត៌មានខុសៗគ្នាដែលគេប្រមូលបានហើយបង្ហាញទៅកាន់សិស្សដទៃទៀត។
- វិធីបង្ហាញព័ត៌មានដែលប្រមូលបានមួយទៀត គឺឱ្យសិស្សជ្រើសរើសផ្នែកមួយនៃព័ត៌មានក្នុងការ ស្រាវជ្រាវរបស់គេ។ សកម្មភាពនេះអាចជ្រើសរើសបានតាមវិធីជាច្រើន។ ឧទាហរណ៍ផ្នែកខ្លះ នៃព័ត៌មានដែលគេគិតថាមានសារៈសំខាន់បំផុតសម្រាប់ពួកគេ និងផ្នែកខ្លះនៃព័ត៌មាន ដែលគេគិតថាពុំសូវមានប្រយោជន៍សម្រាប់គេ និងផ្នែកដែលគេមិនដែលធ្លាប់បានដឹងពីមុនសោះ ។ល។
- នៅពេលដែលគេជ្រើសរើសផ្នែកព័ត៌មានរួចហើយ គេអាចសរសេរវានៅលើប័ណ្ណដាក់នៅលើជញ្ជាំង ក្រោយមកទៀតគេទៅមើលជម្រើសព័ត៌មានរបស់សិស្សផ្សេងៗទៀត។
- បន្ទាប់មកសិស្សអាចប្រើប្រាស់ព័ត៌មាននេះក្នុងដំណាក់កាលផ្សេងទៀតនៃកម្មវិធី។

## គំរូតារាងឈ្មោះប្រភពប្រមូលទិន្នន័យ សម្រាប់សកម្មភាពស្រាវជ្រាវងាយៗ

| សំណួរ | | ប្រភពព័ត៌មាន | | ការឆ្លើយតប/សម្គាល់ |
|---|---|---|---|---|
| | | មនុស្ស | ឯកសារ/ទីកន្លែង | |
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| ៤ | | | | |
| ៥ | | | | |
| ៦ | | | | |

## សកម្មភាពទី៤៖ ការប្រើប្រាស់ករណីសិក្សា

ករណីសិក្សាគឺជាខ្សែរឿងទាំងឡាយណាដែលមានព័ត៌មានលើប្រធានបទ ជាស្ថានភាពឬជា ព្រឹត្តិការណ៍ ហើយជាទូទៅផ្សារភ្ជាប់ទៅនឹងការរៀងនិទានរបស់នរណាម្នាក់។ វាអាចឆ្លើយផ្ទាល់ទៅនឹង សំណួរ ឬបង្ហាញដោយផ្ទាល់នូវអ្វីដែលអ្នកអានចង់ដឹង។ វាក៏ផ្តល់ព័ត៌មានដល់អ្នកអាន ដើម្បីកំណត់លក្ខណៈ និងដំណោះស្រាយផ្សេងៗចំពោះស្ថានភាព និងបញ្ហាដែលគេជួបប្រទះនៅក្នុងសហគមន៍របស់គេផ្ទាល់។ ករណីសិក្សា គឺជាឧបករណ៍ដ៏មានប្រយោជន៍ ពីព្រោះវាផ្តល់នូវបរិបទពិតរបស់ជីវិត ដែលគេអាចវិភាគស្វែងយល់ពីព័ត៌មានបានច្រើនលើប្រធានបទ ស្ថានភាព ឬព្រឹត្តិការណ៍មួយដែលកើតមានក្នុងជីវិតរបស់មនុស្សម្នាក់ៗ។

### ល័ក្ខខ័ណ្ឌនៃការបង្កើតករណីសិក្សា

- ត្រូវប្រាកដថាករណីសិក្សាមិនវែងហួសហេតុពេក។
- ត្រូវប្រាកដថា ករណីសិក្សាសរសេរមានខ្លឹមសារ និងឃ្លាប្រយោគងាយអានងាយយល់ ។
- ត្រូវប្រាកដថាអ្នកជ្រើសរើសករណីសិក្សា ដែលពាក់ព័ន្ធនឹងប្រធានបទ។
- ត្រូវប្រាកដថា សំណួរដែលប្រើប្រាស់ក្នុងករណីសិក្សាអាចឱ្យសិស្សអភិវឌ្ឍចំណេះដឹង និងសមត្ថភាពរបស់គេក្នុងការធ្វើអនុមានញែកដោយផ្អែកលើព័ត៌មាននៅក្នុងអត្ថបទ។
- ផ្លាស់ប្តូរវិធីសាស្ត្រ ដែលអ្នកប្រើប្រាស់ករណីសិក្សាជាមួយសិស្សរបស់អ្នក ជាពិសេសប្តូរព័ត៌មានសម្រាប់ក្រុម ហើយត្រូវមានគំនិតច្នៃប្រឌិត។

### វិធីប្រតិបត្តិក្នុងការប្រើប្រាស់ករណីសិក្សា

វិធីផ្សេងៗដែលអ្នកអាចយកទៅប្រើប្រាស់សម្រាប់ធ្វើករណីសិក្សាមាន៖

- នៅពេលដែលអ្នកជ្រើសរើសករណីសិក្សា ដែលពាក់ព័ន្ធទៅនឹងអ្វីដែលអ្នកចង់ឱ្យសិស្សរៀន ចូរចាប់ផ្តើមគិតពីសំណួរដែលអ្នកចង់ឱ្យគេឆ្លើយ ដោយប្រើប្រាស់ករណីសិក្សា។ (សូមអានទំព័របន្ទាប់)
- អ្នកអាចឱ្យសិស្សធ្វើការងារជាដៃគូ ជាក្រុម ឬជាបុគ្គល អានករណីសិក្សាហើយឆ្លើយសំណួរ ។
- អ្នកអាចឱ្យករណីសិក្សាផ្សេងៗគ្នាទៅក្រុម ឬបុគ្គលម្នាក់ៗ បន្ទាប់មកឱ្យគេផ្តុំគ្នាជាក្រុមធំ ដើម្បីចែករំលែកបទពិសោធដែលគេបានទទួលពីករណីសិក្សា។

ឧទាហរណ៍នៃការបង្កើតក្រុម៖

១. អ្នកអាចចែកទៅឱ្យក្រុមសិស្ស៤នាក់នូវករណីសិក្សាខុសគ្នាចំនួន២។ សិស្ស២នាក់ធ្វើការងាររួមគ្នា ដើម្បីឆ្លើយកម្រងសំណួរ ហើយក្រុមផ្សេងទៀតធ្វើការងារទៅលើកម្រងសំណួរដដែល ប៉ុន្តែជាមួយករណីសិក្សាខុសគ្នា។ នៅពេលបញ្ចប់សកម្មភាពពួកគេអាចចែករំលែកចម្លើយគ្នា។

២. អ្នកអាចឱ្យករណីសិក្សាដូចគ្នាទៅដល់សិស្សក្នុងក្រុម ប៉ុន្តែមានសំណួរខុសៗគ្នា។ នៅចុងបញ្ចប់ សមាជិកក្នុងក្រុមចែករំលែកព័ត៌មានទាំងនេះជាមួយគ្នា។

៣. អ្នកអាចណែនាំករណីសិក្សាដល់សិស្ស (តួអង្គទីតាំង និងលក្ខណៈទូទៅនៃករណីសិក្សា) បន្ទាប់មកទៀត អ្នកអាចសួរសិស្សពីតួអង្គសំខាន់ៗ ខ្លឹមសារសំខាន់ៗក្នុងករណីសិក្សាដែលទាក់ទងនឹងប្រធានបទ។ ឱ្យសិស្សអានករណីសិក្សា ហើយសួរសំណួរពិនិត្យមើលថាតើគេទទួលបានចម្លើយប៉ុន្មាន។

### ការអភិវឌ្ឍនិងការសួរសំណួរ៖

វាជាការសំខាន់ណាស់ បើគ្រូសួរសំណួរដើម្បី៖

- ត្រួតពិនិត្យការយល់ដឹង។
- ជំរុញការចូលរួមជាមួយសិស្ស។
- ឱ្យសិស្សប្រតិបត្តិ។

ប្រភេទសំណួរ

- សំណួរបិទ/សំណួរបើក៖ ឧទាហរណ៍-តើប្អូនបារម្ភអំពីការទៅរកការងារធ្វើនៅភ្នំពេញដែរឬទេ?
- សំណួរប្រៀបធៀប៖ ឧទាហរណ៍-តើកុមារីនៅក្នុងរឿងសម្រេចចិត្តទៅធ្វើការនៅភ្នំពេញដោយខ្លួនឯង ឬដោយមានការជំរុញពីឪពុកម្ដាយគេ?
- សំណួរទស្សន៍ទាយ៖ ឧទាហរណ៍-ប្រសិនបើ................តើមានអ្វីនឹងកើតឡើង.............? ប្រសិនបើ នាងបន្តរៀនឱ្យបានចប់ចុងចប់ដើម តើនាងនឹងក្លាយជាមនុស្សប្រសើរបែបណានាពេលអនាគត?
- សំណួរដែលចាប់ផ្ដើមឡើងដោយពាក្យហេតុអ្វី? ឯណា? នរណា? ពេលណា? របស់នរណា? របៀបណា? ឧទាហរណ៍៖ ហេតុអ្វីបានជាអ្នកគិតថាកុមារីនៅក្នុងរឿងសម្រេចចិត្តទៅភ្នំពេញ?

## V. ការឆ្លុះបញ្ចាំងលើបំណិនដែលបានអភិវឌ្ឍ

ជាប្រការសំខាន់ណាស់ក្នុងការចំណាយពេលជាមួយសិស្ស ដើម្បីឆ្លុះបញ្ចាំងលើដំណាក់កាលនេះ។ វាជួយអោយសិស្សធ្វើការកត់សម្គាល់លើបទពិសោធ និងអារម្មណ៍របស់គេ ដែលបានចូលរួមគ្រប់សកម្មភាពទាំងអស់នៅក្នុងដំណាក់កាលនេះ ជាពិសេសកត់សម្គាល់លើបំណិនដែលគេបានអភិវឌ្ឍ។ គ្រូអាចសួរសំណួរងាយៗដូចខាងក្រោមដើម្បីឆ្លុះបញ្ចាំង៖

១. តើការសិក្សានៅពេលនេះប្រព្រឹត្តទៅយ៉ាងដូចម្ដេចដែរ?

២. តើប្អូនពេញចិត្តនឹងអន្តរកម្មជាមួយមិត្តរួមថ្នាក់របស់ប្អូនឬទេ? ហេតុអ្វី?

៣.ក្រៅពីខ្លឹមសារមេរៀន តើបំណិនអ្វីខ្លះដែលប្អូនបានអភិវឌ្ឍ? ចូររៀបរាប់ពីដំណើរការនៃការអភិវឌ្ឍបំណិននោះ។

៤. ថ្ងៃក្រោយ តើប្អូនចង់ធ្វើយ៉ាងដូចម្ដេច ដើម្បីអភិវឌ្ឍបំណិនដែលប្អូនគិតថាមិនទាន់ស្ទាត់ជំនាញ?

# ដំណាក់កាលទី២៖ ការស្រង់ព័ត៌មានពីសហគមន៍

## I. សេចក្តីផ្តើម

ស្វែងយល់អំពីអ្វីដែលសហគមន៍យល់ដឹងលើប្រធានបទ គឺជាលំហាត់មួយដ៏មានប្រយោជន៍ សម្រាប់សិស្សដែលគេអាចផ្សារភ្ជាប់នូវអ្វីដែលគេបានពិភាក្សាអំពីប្រធានបទក្នុងថ្នាក់រៀនលើស្ថានភាពពិតនៃជីវិតរបស់គេ។ វាក៏ជាការផ្តល់ឱកាសដល់សិស្ស ដើម្បីប្រមូលព័ត៌មានសំខាន់ៗពីសហគមន៍ និងឱ្យគេមានទម្លាប់ធ្វើការងារជាមួយសហគមន៍ ដើម្បីជួយដោះស្រាយបញ្ហាងាយៗក្នុងមូលដ្ឋាន។

## II. គោលបំណង

បង្កើតឧបករណ៍ និងចុះប្រមូលព័ត៌មានពីសហគមន៍ហ្វឹកហាត់ក្នុងការសួរសំណួរ ដែលអាចឱ្យសិស្សវាយតម្លៃការយល់ដឹង និងឥរិយាបថរបស់ពួកគេលើប្រធានបទដែលបានជ្រើសរើស។

## III. បំណិនជីវិតសំខាន់ៗដែលនឹងអភិវឌ្ឍ

បំណិនស្រាវជ្រាវ បំណិនទំនាក់ទំនង បំណិនអន្តរបុគ្គល ការរៀបចំចាត់ចែងលើប្រធានបទឱ្យកាន់តែស៊ីជម្រៅ ការឱ្យតម្លៃខ្លួនឯងនិងសហគមន៍ និងការទទួលខុសត្រូវ។

## IV. ល្បិចបង្រៀន

### សកម្មភាពទី១៖ ការបង្កើតកម្រងសំណួរ

#### សេចក្តីណែនាំ

ជាប្រការចាំបាច់ណាស់ក្នុងការរៀបចំសិស្សមុនពេលគេទៅសហគមន៍ដើម្បីប្រមូលព័ត៌មានស្តីពីការយល់ដឹងរបស់គេលើប្រធានបទ។ ការកសាងកម្រងសំណួរនឹងជួយសិស្សឱ្យយល់កាន់តែច្បាស់អំពីអ្វីដែលត្រូវសួរក្នុងសហគមន៍។

#### ល្បិចបង្រៀន៖

- រំលឹកឡើងវិញនូវអ្វីដែលបានពិភាក្សាក្នុងជំហានទី១ដោយដាក់ពណ៌ចំណាំលើព័ត៌មាន និងគំនិតសំខាន់ៗ។ អភិវឌ្ឍផែនទីគំនិតលើប្រធានបទ និងសំយោគសំណួរឱ្យបានច្រើនតាមចំនួន ដែលអាចធ្វើបានដែលឆ្លុះបញ្ចាំងលើផែនទីគំនិតដោយរាប់បញ្ចូលទាំងរឿងរ៉ាវសំខាន់ៗជុំវិញប្រធានបទ ដែលអ្នកបានសង្កេតឃើញក្នុងសហគមន៍ និងអ្វីដែលអ្នកចង់ដឹងបន្ថែមពីសហគមន៍។
- ធ្វើយ៉ាងណាឱ្យសិស្សយល់ច្បាស់ពីគោលបំណងនៃការបង្កើតកម្រងសំណួរដោយផ្តោតលើមូលហេតុផលប៉ះពាល់ដំណោះស្រាយ ផែនការសម្រាប់ជីវិត...។
- ដាក់សំណួរដែលទើបតែបង្កើតទៅតាមក្រុមគំនិត និងជ្រើសរើសសំណួរសំខាន់ៗយ៉ាងច្រើនចំនួន១០ ដើម្បីប្រើប្រាស់ពេលធ្វើសម្ភាស។ សិស្សមិនចាំបាច់ទន្ទេញសំណួរឱ្យចាំឡើយ គឺគេគ្រាន់តែចាំពីគំនិតសំខាន់ៗដែលត្រូវសួរនិងសួរសំណួរបន្តបន្ទាប់នៅពេលដែលគេចង់ដឹងបន្ថែម។

- គ្រូធ្វើយ៉ាងណាឱ្យសិស្សចេះបត់បែនតវិយាបថជាក់ស្តែងនៅពេលចុះធ្វើសម្ភាស។
- សកម្មភាពនេះអាចធ្វើបានដោយថ្នាក់ទាំងមូល ឬដោយក្រុមតូចៗ។ បើធ្វើដោយក្រុមតូច ក្រុមនីមួយៗត្រូវបង្ហាញកម្រងសំណួររបស់ពួកគេទៅដល់ថ្នាក់ទាំងមូល ហើយដឹកនាំការពិភាក្សា ដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់ថាពួកគេក្តោបយកព័ត៌មានចាំបាច់សម្រាប់ដំណាក់កាលបន្ទាប់។
- សិស្សម្នាក់ៗមានកម្រងសំណួរដែលសរសេរលើសៀវភៅរបស់គេ។
- គ្រូត្រូវរៀបចំផែនការលម្អិតជូននាយកសាលា ឬក្រុមការងារ ដើម្បីពួកគាត់ផ្តល់ព័ត៌មានដល់សហគមន៍នៅពេលបញ្ចប់សកម្មភាពទី ២ស្តីពីការត្រៀមធ្វើសម្ភាស។

## គំរូកម្រងសំណួរ

១. តើលោកពូអ្នកមីងដឹងពីរឿងរ៉ាវដែលទាក់ទងទៅនឹង.................................?
២. តើធ្លាប់មានរឿងនេះកើតនៅក្នុងសហគមន៍លោកពូ-អ្នកមីងដែរឬទេ?
៣. តើលោកពូ-អ្នកមីងដឹងទេថា តើមូលហេតុអ្វីដែលនាំឱ្យមានរឿងរ៉ាវនោះកើតឡើង?
៤. តើលោកពូ-អ្នកមីងដឹងទេថារឿងនោះវានឹងមានផលវិបាកអ្វីខ្លះ?
៥. តើលោកពូ-អ្នកមីងគិតថារឿងនោះនាំឱ្យប៉ះពាល់អ្វីខ្លះដល់ជីវិត និងគ្រួសាររបស់ពួកគេ?
៦. តើពួកគាត់/លោកពូ-អ្នកមីងធ្វើដូចម្តេច ដើម្បីដោះស្រាយរឿងរ៉ាវនេះកន្លងមក?
៧. តើពេលកើតមានរឿងរ៉ាវនោះមាននរណាម្នាក់ជួយធ្វើអន្តរាគមន៍ដែរឬទេ?
៨. តើលោកពូ-អ្នកមីងចង់ឃើញបញ្ហាបែបនេះកើតមាននៅក្នុងសហគមន៍របស់លោកពូ-អ្នកមីងដែរឬទេ?
៩. តើលោកពូ-អ្នកមីងគិតថាយើងអាចរួមគ្នាដោះស្រាយបញ្ហាទាំងនោះបានដែរឬទេ? ហេតុអ្វី?
១០.តើលោកពូ-អ្នកមីងគិតថាគួរមានដំណោះស្រាយដូចម្តេចខ្លះ?

## សកម្មភាពទី២៖ ការត្រៀមធ្វើសម្ភាសសេចក្តីណែនាំ

ការត្រៀមសម្ភាសអាចជួយសិស្សធ្វើផែនការរៀបចំសម្ភារៈ និងការចាត់ចែងទាំងឡាយ ដែលចាំបាច់មុនពេលសម្ភាសន៍។ វានឹងជួយឱ្យសិស្សយល់កាន់តែច្បាស់នូវអ្វីដែលគេនឹងត្រូវធ្វើនៅក្នុងសហគមន៍ដូចជាហេតុអ្វី? ធ្វើអ្វី? នរណាធ្វើ? នៅពេលណា? ធ្វើដោយរបៀបណា?។ល។

### ល្បិចបង្រៀន៖

- កំណត់គោលបំណងនៃការធ្វើសម្ភាសដើម្បីឱ្យសិស្សអាចពន្យល់សហគមន៍ពីគោលបំណងដែលគេត្រូវជួប។
- អភិវឌ្ឍតារាងតាមដាននូវអ្វីដែលសិស្សត្រូវធ្វើដោយរាប់ទាំងកម្រងសំណួរការផ្តល់ព័ត៌មានដល់អ្នក ដែលត្រូវសម្ភាស ការហ្វឹកហាត់ដោយប្រើកម្រងសំណួរ កំណត់ចំនួន និងមុខសញ្ញាដែលយើងធ្វើសម្ភាស កំណត់កាលបរិច្ឆេទនិងទីកន្លែងដែលត្រូវសម្ភាស។
- បង្ហាញផែនការសម្ភាសដល់នាយកសាលា ឬក្រុមការងារ ដើម្បីឱ្យពួកគេជួយគាំទ្រ។
- ចែករំលែកការទទួលខុសត្រូវសមាជិកក្នុងក្រុម៖ តើនរណាជាអ្នកណែនាំក្រុមទៅកាន់អ្នកដែលត្រូវសម្ភាស? នរណាជាអ្នកសួរសំណួរ? នរណាជាអ្នកកត់ត្រា?។ល។ រួចទុកពេលវេលាឱ្យសិស្សហ្វឹកហាត់សម្ភាស។

## សកម្មភាពទី៣៖ សម្ភាសន៍ជាក់ស្តែង

សកម្មភាពនេះអនុវត្តឡើងនៅក្នុងសហគមន៍ដោយជួយជំរុញការធ្វើអន្តរកម្មរវាងសាលា និងសហគមន៍ព្រមទាំងធ្វើឱ្យសហគមន៍យល់ច្បាស់អំពីរឿងរ៉ាវដែលនឹងអាចមានឥទ្ធិពលទៅលើជីវិតរបស់ពួកគាត់។ វាក៏ផ្តល់ឱកាសឱ្យសិស្សអភិវឌ្ឍបំណិនទំនាក់ទំនងអន្តរបុគ្គល និងទទួលបានកាន់តែច្រើននូវទំនុកចិត្តលើខ្លួនឯងការគោរពខ្លួនឯង និងចំណេះដឹងអំពីសហគមន៍។

### ល្បិចបង្រៀន

- ស្វាគមន៍ចំពោះអ្នកដែលត្រូវសម្ភាសន៍ ហើយពន្យល់ពីគោលបំណងនៃសម្ភាសន៍។
- ណែនាំសមាជិកក្រុមដល់អ្នកដែលត្រូវសម្ភាសន៍ហើយអរគុណដល់គាត់ដែលបានចំណាយពេលវេលាសម្រាប់សម្ភាសន៍នេះ។
- ចាប់ផ្តើមសម្ភាសដោយសមាជិកក្រុមនីមួយៗត្រូវប្រកាន់តួនាទីនិងការទទួលខុសត្រូវរបស់ខ្លួនតាមកម្មវិធីដែលបានរៀបចំទុកកាលពីសកម្មភាពលើកមុន។
- នៅចុងបញ្ចប់អរគុណដល់អ្នកដែលត្រូវសម្ភាសន៍សារជាថ្មីហើយជម្រាបពួកគាត់ថាយើងខ្ញុំសង្ឃឹមថានឹងបានសហការជាមួយលោកពូ-អ្នកមីង ដើម្បីដោះស្រាយបញ្ហានេះនៅពេលអនាគត។

## សកម្មភាពទី៤៖ ការធ្វើរបាយការណ៍

បន្ទាប់ពីធ្វើសម្ភាសរួចហើយ ក្រុមនីមួយៗត្រូវរៀបចំនូវអ្វីដែលគេបានរកឃើញ ដើម្បីបង្ហាញដល់ថ្នាក់ទាំងមូលដោយកត់សម្គាល់នូវចំណុចសំខាន់ៗដែលរកឃើញ។ ក្រុមនីមួយៗ ក៏ត្រូវរៀបចំរបាយការណ៍ផងដែរពីបទពិសោធ និងការប្រឈមទាំងឡាយ ដែលគេជួបប្រទះនៅពេលចុះសម្ភាស ព្រមទាំងកំណត់បាននូវអ្វីដែលគេត្រូវការជំនួយបន្ថែមនៅពេលដែលគេចុះធ្វើសម្ភាស។

### ល្បិចបង្រៀន

- សកម្មភាពនេះអាចធ្វើជាច់ដោយឡែកពីគ្នានៅក្រៅថ្នាក់រៀន ដោយក្រុមផ្ទាល់ខ្លួនរបស់គេ ឬធ្វើក្នុងថ្នាក់រៀនដោយមានជំនួយពីគ្រូប្រចាំថ្នាក់។
- ក្រុមនីមួយៗដឹកនាំការពិភាក្សាលើលទ្ធផលសម្ភាសន៍ ហើយសរសេរនៅលើក្រដាសព្រាង។
- រៀបចំលទ្ធផលសម្ភាសន៍នោះធ្វើយ៉ាងណាអាចបង្ហាញបានស្រួលនៅក្នុងថ្នាក់រៀនទៅតាមគំរូដូចខាងក្រោម។
- សរសេរលទ្ធផលនេះលើក្រដាសផ្ទាំងធំ សម្រាប់ការបង្ហាញ។

## គំរូនៃការបង្ហាញលទ្ធផល

គោលបំណង៖ ........................................................

ក្រុមគោលដៅ៖ ........................................................

វិធីសាស្ត្រ៖ ........................................................

លទ្ធផល៖

១. ចំណេះដឹង៖ គិតទាំងព័ត៌មានទូទៅ មូលហេតុផលវិបាក។ល។

២. ការអនុវត្ត៖ គិតទាំងឥទ្ធិពលលើសហគមន៍វិធីសាស្ត្រក្នុងការបញ្ចៀសបញ្ហាសកម្មភាពអនុវត្ត...

៣. ឥរិយាបថ៖ គិតទាំងការផ្តោតលើបញ្ហាឆន្ទៈដោះស្រាយបញ្ហា។ល។

បទពិសោធដែលបានរៀន៖

១. ការលំបាក ឬបញ្ហាប្រឈម។

៣. ការកែលម្អសម្រាប់អនាគត។

## V. ការឆ្លុះបញ្ចាំងលើបំណិនដែលបានអភិវឌ្ឍ

ជាប្រការសំខាន់ណាស់ក្នុងការចំណាយពេលជាមួយសិស្ស ដើម្បីឆ្លុះបញ្ចាំងលើដំណាក់កាលនេះ។ វាជួយអោយសិស្សធ្វើការកត់សម្គាល់លើបទពិសោធ និងអារម្មណ៍របស់គេ ដែលបានចូលរួមគ្រប់សកម្មភាពទាំងអស់នៅក្នុងដំណាក់កាលនេះ ជាពិសេសកត់សម្គាល់លើបំណិនដែលគេបានអភិវឌ្ឍ។ គ្រូអាចសួរសំណួរងាយៗដូចខាងក្រោមដើម្បីឆ្លុះបញ្ចាំង៖

១. តើការសិក្សានៅពេលនេះប្រព្រឹត្តទៅយ៉ាងដូចម្តេចដែរ?

២. តើប្អូនពេញចិត្តនឹងអន្តរកម្មជាមួយមិត្តរួមថ្នាក់របស់ប្អូនឬទេ? ហេតុអ្វី?

៣. ក្រៅពីខ្លឹមសារមេរៀន តើបំណិនអ្វីខ្លះដែលប្អូនបានអភិវឌ្ឍ? ចូររៀបរាប់ពីដំណើរការនៃការអភិវឌ្ឍបំណិននោះ។

៤. ថ្ងៃក្រោយ តើប្អូនចង់ធ្វើយ៉ាងដូចម្តេច ដើម្បីអភិវឌ្ឍបំណិនដែលប្អូនគិតថាមិនទាន់ស្ទាត់ជំនាញ?

# ដំណាក់កាលទី៣៖ ការវិភាគព័ត៌មានដោយប្រើដើមឈើបញ្ហា

## I. សេចក្ដីផ្ដើម

វិភាគលទ្ធផលព័ត៌មានគឺជាជំហានបន្ដពីការប្រមូលព័ត៌មានក្នុងសហគមន៍នៃដំណាក់កាលទី២។ ដំណាក់កាលនេះពាក់ព័ន្ធក្នុងការវិភាគព័ត៌មាន និងការកំណត់ដំណោះស្រាយលើដើមឈើបញ្ហា។ វាជំរុញសិស្សឱ្យចេះគិតដោយវិភាគ និងការរែកញែក បំណិនដោះស្រាយបញ្ហា ព្រមទាំងមានឥរិយាបថវិជ្ជមានក្នុងការដោះស្រាយបញ្ហាក្នុងសហគមន៍របស់ពួកគេ។

## II. គោលបំណង

សិស្សអាចប្រើប្រាស់ព័ត៌មានដែលប្រមូលបាន ដើម្បីវិភាគបញ្ហាសំខាន់ៗ ដូចជាមូលហេតុផលវិបាក និងដំណោះស្រាយចំពោះបញ្ហានោះ ដោយប្រើការវិភាគដើមឈើបញ្ហា។

## III. បំណិនសំខាន់ៗដែលនឹងអភិវឌ្ឍ

បំណិនវិភាគ បំណិនគិតដោយល្អិតល្អន់បំណិនដោះស្រាយបញ្ហា បំណិនក្នុងការបង្ហាញទំនុកចិត្តលើខ្លួនឯងការឱ្យតម្លៃខ្លួនឯងឥរិយាបថវិជ្ជមានក្នុងការដោះស្រាយបញ្ហាសហគមន៍...។

## IV. ល្បិចបង្រៀន

### សកម្មភាពទី១៖ ការបង្ហាញលទ្ធផលព័ត៌មាន ដែលប្រមូលបានសេចក្ដីណែនាំ

ការបង្ហាញលទ្ធផលព័ត៌មាន ដែលបានប្រមូលទៅកាន់ថ្នាក់ទាំងមូល វាជួយឱ្យសិស្សបំពេញព័ត៌មានបានពេញលេញអំពីរឿងរ៉ាវដែលមាននៅក្នុងសហគមន៍។ ធ្វើដូចនេះ គេអាចវិភាគដោយល្អិតល្អន់ និងអាចរកឃើញនូវដំណោះស្រាយជាក់ស្ដែងចំពោះបញ្ហា។

### ល្បិចបង្រៀន៖

- ឱ្យក្រុមនីមួយៗបិទរបាយការណ៍ក្រដាសផ្ទាំងធំរបស់គេ ដែលបានរៀបចំនៅក្នុងដំណាក់កាលទី២ ហើយត្រូវប្រាកដថាក្រុមនីមួយៗបានត្រៀមលក្ខណៈគ្រប់គ្រាន់សម្រាប់ការបង្ហាញ។
- អញ្ជើញក្រុមនីមួយៗឡើងបង្ហាញលទ្ធផលព័ត៌មានប្រមូលបានពីសហគមន៍ (មិនមែនជាគំនិតបន្ថែមរបស់ក្រុមទេ) ហើយសមាជិកក្រុមដទៃទៀតសួរសំណួរ ឬធ្វើការបកស្រាយឱ្យច្បាស់ប្រសិនជាចាំបាច់។
- ចាត់តាំងសមាជិកម្នាក់នៅឈរចាំក្បែរក្រដាសផ្ទាំងធំ (ប៉ុស្ទ័រ) របស់ខ្លួន ដើម្បីបកស្រាយរាល់ចម្ងល់ផ្សេងៗ បើចាំបាច់ហើយសមាជិកផ្សេងទៀតដើរអានរបាយការណ៍របស់ក្រុមដទៃទៀត។
- បូកសរុបដោយកំណត់នូវលទ្ធផលសំខាន់ៗ និងសរសេរនៅលើក្រដាសផ្ទាំងធំឱ្យបានរួចជាស្រេច សម្រាប់ការវិភាគដើមឈើបញ្ហា។

## សកម្មភាពទី២៖ ការវិភាគដើមឈើបញ្ហា

ការវិភាគដើមឈើបញ្ហាជួយសិស្សឱ្យចេះប្រើប្រាស់ព័ត៌មានដែលប្រមូលបានពីសហគមន៍។ នេះគឺជាវិធីមួយនៃការរៀបបញ្ចូលព័ត៌មានទៅតាមក្រុម ដូចជាហេតុនិងផលនៃបញ្ហា ហើយធ្វើការវិភាគដើម្បីទាញបាននូវដំណោះស្រាយមួយចំនួន សម្រាប់សកម្មភាពបន្តនៅជំណាក់កាលក្រោយទៀត។

## ល្បិចបង្រៀន៖

- ដាក់ក្រដាសផ្ទាំងធំនៃព័ត៌មានសំខាន់ៗដែលបានរៀបចំក្នុងសកម្មភាពមុន។
- អាចធ្វើទៅបានដោយក្រុមតូចៗឬថ្នាក់ទាំងមូលដោយបញ្ជូននូវអ្វីដែលជាព័ត៌មានសំខាន់ៗក្នុងក្រដាសផ្ទាំងធំនៃការវិភាគដើមឈើបញ្ហាដូចបង្ហាញខាងក្រោម។
- ដឹកនាំការវិភាគដើមឈើបញ្ហា និងធ្វើឱ្យមានសហសម្ព័ន្ធភាពគ្នារវាងហេតុនិងផល ឱ្យកាន់តែស៊ីជម្រៅដោយសួរសំណួរ ហេតុអ្វី? .....តើយើងគួរធ្វើដូចម្តេច......ប្រសិនបើ....?
- បន្ទាប់មកកំណត់ពណ៌ចំណាំនូវគំនិតសំខាន់ៗ ដើម្បីលើកឡើងជាដំណោះស្រាយនៅជំហានបន្ទាប់។
- រក្សាក្រដាសផ្ទាំងធំនេះ សម្រាប់ប្រើប្រាស់ក្នុងសកម្មភាពបន្ទាប់ទៀត។

## គំរូនៃការវិភាគដើមឈើបញ្ហាអំពីចំណាកស្រុក



## គំរូនៃការវិភាគបញ្ហាទូទៅ






## សកម្មភាពទី៣៖ ការកំណត់ដំណោះស្រាយចំពោះបញ្ហា

ដោយផ្អែកលើការវិភាគដើមឈើបញ្ហា សិស្សអាចកំណត់ដំណោះស្រាយបញ្ហាបានច្រើន។ សកម្មភាពនេះ ផ្តល់ឱកាសឱ្យសិស្សក្នុងការបង្កើតភាពច្នៃប្រឌិត និងការកែប្រែថ្មីចំពោះបញ្ហា ដែលគេអាចសាកល្បងដោះស្រាយវាបាននៅក្នុងសហគមន៍របស់គេ។ នេះជាផ្នែកមួយនៃការរៀនសូត្ររបស់សិស្ស ដែលជំរុញឱ្យសមាជិកសហគមន៍រួមចំណែកក្នុងការដោះស្រាយបញ្ហាផ្ទាល់ខ្លួនរបស់គេ។

## ល្បិចបង្រៀន៖

- គ្រូដាក់ក្រដាសផ្ទាំងធំនៃការវិភាគដើមឈើបញ្ហានៅលើក្តារខៀន ហើយគេត្រូវពឹងផ្អែកលើក្រដាសផ្ទាំងធំនោះនៅពេលដែលគេបូកសរុបយកដំណោះស្រាយផ្សេងៗ។
- ដឹកនាំការពិភាក្សាឬឱ្យសិស្សក្នុងក្រុមនីមួយៗពិភាក្សា និងក្រឡេកមើលហេតុនិងផលប៉ះពាល់ ហើយស្វែងរកនូវដំណោះស្រាយដែលគេអាចធ្វើបាន ដើម្បីដោះស្រាយបញ្ហា។
- គេអាចគិតរកដំណោះស្រាយឱ្យបានច្រើនតាមតែអាចធ្វើទៅបានដោយមិនថាតូច ឬធំ ឬមានធនធានទេ។
- ធ្វើបញ្ជីដំណោះស្រាយដែលអាចធ្វើទៅបាននៅលើក្រដាសផ្ទាំងធំ ហើយទុកវាឱ្យបានល្អ សម្រាប់សកម្មភាពលើកក្រោយទៀត។

## V. ការឆ្លុះបញ្ចាំងលើបំណិនដែលបានអភិវឌ្ឍ

ជាប្រការសំខាន់ណាស់ក្នុងការចំណាយពេលជាមួយសិស្ស ដើម្បីឆ្លុះបញ្ចាំងលើដំណាក់កាលនេះ។ វាជួយអោយសិស្សធ្វើការកត់សម្គាល់លើបទពិសោធ និងអារម្មណ៍របស់គេ ដែលបានចូលរួមគ្រប់សកម្មភាពទាំងអស់នៅក្នុងដំណាក់កាលនេះ ជាពិសេសកត់សម្គាល់លើបំណិន ដែលគេបានអភិវឌ្ឍ។ គ្រូអាចសួរសំណួរងាយៗដូចខាងក្រោមដើម្បីឆ្លុះបញ្ចាំង៖

១. តើការសិក្សានៅពេលនេះប្រព្រឹត្តទៅយ៉ាងដូចម្តេចដែរ?

២. តើប្អូនពេញចិត្តនឹងអន្តរកម្មជាមួយមិត្តរួមថ្នាក់របស់ប្អូនឬទេ? ហេតុអ្វី?

៣. ក្រៅពីខ្លឹមសារមេរៀន តើបំណិនអ្វីខ្លះដែលប្អូនបានអភិវឌ្ឍ? ចូររៀបរាប់ពីដំណើរការនៃការអភិវឌ្ឍបំណិននោះ។

៤. ថ្ងៃក្រោយ តើប្អូនចង់ធ្វើយ៉ាងដូចម្តេច ដើម្បីអភិវឌ្ឍបំណិនដែលប្អូនគិតថាមិនទាន់ស្ទាត់ជំនាញ?

# ដំណាក់កាលទី៤៖ ការរៀបចំផែនការផ្សព្វផ្សាយ

## I. សេចក្តីផ្តើម

ការអភិវឌ្ឍផែនការសកម្មភាព គឺជាដំណាក់កាលមួយ ដែលផ្តល់ឱកាសឱ្យសិស្សនូវអ្វីដែលគេចង់ធ្វើនៅក្នុងសហគមន៍ដោយផ្អែកលើការវិភាគបញ្ហាដែលគេប្រមូលបានពីសហគមន៍។ដំណាក់កាលនេះនឹងជំរុញឱ្យសហគមន៍យល់កាន់តែច្រើនចំពោះបញ្ហា និងជួយរួមចំណែកដោះស្រាយបញ្ហាដែលប៉ះពាល់ដល់ជីវិតរបស់គេ។

## II. គោលបំណង

សិស្សមានសមត្ថភាពកំណត់ដំណោះស្រាយ ដែលអាចអនុវត្តជាក់ស្តែង (មួយឬច្រើន) ដើម្បីដោះស្រាយបញ្ហា និងកសាងផែនការសម្រាប់អនុវត្ត។

## III. បំណិនសំខាន់ៗដែលនឹងអភិវឌ្ឍ

បំណិនក្នុងការសម្រេចចិត្ត បំណិនក្នុងការចាត់អាទិភាពបញ្ហា បំណិនធ្វើផែនការ បំណិនការងារក្រុម ទំនុកចិត្តលើខ្លួនឯង និងឥរិយាបថវិជ្ជមានក្នុងការដោះស្រាយបញ្ហាជាដើម។

### សកម្មភាពភាពទី១៖ ការជ្រើសរើសដំណោះស្រាយសម្រាប់ការផ្សព្វផ្សាយ

នៅក្នុងដំណាក់កាលទី៣ "ការវិភាគដើមឈើបញ្ហា" សិស្សបានបង្កើតបញ្ជីដំណោះស្រាយបញ្ហារួចមកហើយ។ ដំណោះស្រាយទាំងអស់មិនសុទ្ធតែអាចយកប្រើប្រាស់តាមតែយើងអាចគិតបាននោះទេពីព្រោះវាអាស្រ័យលើធនធានដែលមាន។ ដូចនេះត្រូវជ្រើសរើសយកដំណោះស្រាយណាដែលអាចអនុវត្តបានទៅតាមធនធាន។

## ល្បិចបង្រៀន

សកម្មភាពនេះ អាចធ្វើជាក្រុមតូចៗ ឬក្នុងថ្នាក់ទាំងមូលអាស្រ័យលើគ្រូ។ ត្រូវប្រមូលដំណោះស្រាយដែលបានកំណត់នៅក្នុងសកម្មភាពលើកមុន ហើយសរសេរវានៅលើតារាងខាងក្រោម បន្ទាប់មកដឹកនាំក្រុមពិភាក្សាក្នុងក្រុមតូចៗ ឬនៅក្នុងថ្នាក់ទាំងមូលអាស្រ័យទៅលើសំណួរដែលបានណែនាំ។ បើយើងចង់រៀបចំសកម្មភាពនេះជាក្រុមតូចនោះត្រូវឱ្យក្រុមទាំងអស់ឡើងបង្ហាញត្រឡប់ ហើយពិភាក្សាអំពីដំណោះស្រាយក្នុងថ្នាក់ទាំងមូល។ នៅចុងបញ្ចប់នៃការបង្ហាញនេះយើងជ្រើសរើសយកដំណោះស្រាយ ដែលល្អបំផុតសម្រាប់ថ្នាក់ទាំងមូល ឬក្រុមតូចៗដើម្បីអនុវត្តពេលធ្វើសកម្មភាពផ្សព្វផ្សាយក្នុងទម្រង់ជាការសម្តែងតួ ការធ្វើយុទ្ធនាការផ្សព្វផ្សាយ ការអប់រំមិត្តការជជែកជាសាធារណៈ។ល។

| ដំណោះស្រាយ | ធនធានចាំបាច់ | ធនធានដែលមាន | ភាពអាចធ្វើបាន | ការទទួលខុសត្រូវ |
|---|---|---|---|---|
| ១....<br>២....<br>៣...<br>៤....<br>៥....<br>៦.... | ប្រសិនជាយើងអនុវត្តដំណោះស្រាយនេះ តើយើងត្រូវការធនធានអ្វីខ្លះ? ដូចជា៖ ធនធានមនុស្ស-សម្ភារ និងហិរញ្ញវត្ថុ ជាដើម។ | តើយើងអាចស្វែងរកធនធានទាំងអស់នេះបានដោយងាយដែរឬទេ? | បើយើងឱ្យពិន្ទុ៥ ដោយផ្អែកលើការវិនិច្ឆ័យ។ (ពិន្ទុ៥គឺជាពិន្ទុខ្ពស់បំផុតដែលចាត់ទុកថាជាដំណោះស្រាយល្អដើម្បីយកទៅអនុវត្តហើយពិន្ទុ១ជា ពិន្ទុដែលទាបបំផុតបង្ហាញថាវាពុំមែនជាដំណោះស្រាយដែលអាចអនុវត្តបានឡើយ)។ | តើយើងចង់អនុវត្តវាយ៉ាងដូចម្តេច? តើអ្នកចង់អនុវត្តវាជាក្រុមតូច ឬក្នុងថ្នាក់ទាំងមូល ដូចនេះអ្នកអាចកំណត់ថាតើដំណោះស្រាយចំនួនប៉ុន្មាន ដែលគួរជ្រើសរើសសម្រាប់សកម្មភាពបន្ទាប់។ |

## សកម្មភាពទី២៖ ការរៀបចំផែនការសកម្មភាពសម្រាប់ផ្សព្វផ្សាយ

ការធ្វើផែនការសកម្មភាព គឺជាឯកសារមួយដែលណែនាំអំពីការអនុវត្តឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធ។ វាអាចជួយឆ្លើយទៅនឹងសំណួរថាហេតុអ្វី? ពេលណា? កន្លែងណា? របៀបណា? និងនរណា? សំណួរទាំងអស់នេះនឹងជួយសិស្សឱ្យងាយស្រួលក្នុងការរៀបចំការអនុវត្តរបស់គេ។

## ល្បិចបង្រៀន

ហេតុអ្វីបានជាធ្វើសកម្មភាពផ្សព្វផ្សាយ? គោលបំណងទូទៅនៃសកម្មភាពផ្សព្វផ្សាយ គឺដើម្បីលើកកម្ពស់ការយល់ដឹងក្នុងចំណោមសមាជិកសហគមន៍លើបញ្ហា ដែលសិស្សបានកំណត់ ដែលជាលទ្ធផលនៃការសិក្សាបំណិនជីវិត និងសកម្មភាពស្រាវជ្រាវតូចៗជាមួយក្រុមគោលដៅ។ ជាលទ្ធផល យើងសង្ឃឹមថាអ្នកភូមិនឹងផ្តោតការយកចិត្តទុកដាក់ចំពោះបញ្ហា និងជួយដោះស្រាយបញ្ហាក្នុងសហគមន៍ និងធ្វើឱ្យសហគមន៍ចេះរួបរួមសាមគ្គីគ្នា។

តើសហគមន៍គួរដឹងអ្វីខ្លះ? លទ្ធផលនៃការវិភាគដើមឈើបញ្ហា ជួយអោយយើងអាចវាយតម្លៃពីឫសគល់នៃបញ្ហាដែលធ្វើឱ្យមានផលអវិជ្ជមានលើសហគមន៍ និងអាចរកដំណោះស្រាយសមរម្យមួយចំពោះបញ្ហា ដែលសហគមន៍គួរយល់ដឹង។

តើយើងអាចធ្វើសកម្មភាពនៅពេលណា? សកម្មភាពនេះអាចធ្វើបាននៅចុងបញ្ចប់ប្រធានបទនីមួយៗ ឬនៅពេលមានព្រឹត្តិការណ៍មួយចំនួន ដូចជាទិវាកុមារអន្តរជាតិទិវាពលកម្មអន្តរជាតិ ថ្ងៃបុណ្យសិទ្ធិនារី ថ្ងៃបុណ្យចូលឆ្នាំ ឬថ្ងៃសម្រាកផ្សេងៗទៀត។ល។

តើគេអាចធ្វើសកម្មភាពនេះនៅកន្លែងណា?នៅក្នុងសាលារៀននៅសួនសាធារណៈនៅក្នុងវត្តនៅក្នុងភូមិ។ល។

តើគេអាចធ្វើសកម្មភាពនេះយ៉ាងដូចម្តេច? ប្រភេទនៃសកម្មភាព ដែលអ្នកចង់ធ្វើនរណាអាចជួយធ្វើផែនការ និងអាចអនុវត្តសកម្មភាពបានធនធានដែលត្រូវការ។ល។

តើនរណាជាក្រុមគោលដៅ? ជនរងគ្រោះអាជ្ញាធរមូលដ្ឋាន និងអ្នកនយោបាយ ដើម្បីឱ្យគេផ្តោតការយកចិត្តទុកដាក់ចំពោះបញ្ហា និងមានទំនាក់ទំនងល្អជាមួយបុគ្គល ដែលគួរឱ្យគោរពនៅក្នុងសហគមន៍ ដើម្បីទទួលបានការជួយគាំទ្រពីពួកគាត់។ល។

តើត្រូវអញ្ជើញភ្ញៀវតាមវិធីណា ដើម្បីឱ្យគាត់ចូលរួមបានច្រើន? គ្រូណែនាំឱ្យ សិស្សសរសេរលិខិតអញ្ជើញដោយមានបោះត្រាពីនាយកសាលា។ បន្ទាប់មកឱ្យសិស្សទៅអញ្ជើញដោយផ្ទាល់ (បើមានគ្រូ ឬលោកនាយកទៅជាមួយជាការប្រសើរ)។

## គំរូសកម្មភាពផ្សព្វផ្សាយតាមសហគមន៍

### ការសម្តែងតួ

ការសម្តែងតួជាសកម្មភាពមួយ ដែលអាចធ្វើបានទាំងក្នុងនិងក្រៅថ្នាក់រៀន ដើម្បីពង្រឹងនូវអ្វីដែលសិស្សបានរៀន ដោយធ្វើឱ្យការរៀនសូត្រកាន់តែមានន័យហើយសប្បាយរីករាយ។ វាពាក់ព័ន្ធជាមួយនឹងការរៀបចំការសម្តែង និងការឆ្លុះបញ្ចាំងនៅចុងបញ្ចប់នៃការសម្តែងតួ។



### ១. ការរៀបចំ

- ប្រមូលគ្គីបារម្ភរួម និងផលប៉ះពាល់ដែលទាក់ទងទៅនឹងប្រធានបទ ដែលបានវិភាគនៅជំណាក់កាលទី៣។
- សរសេរពីចំណាប់អារម្មណ៍លើបញ្ហានិងឃ្លាដែលអ្នកសម្តែងត្រូវនិយាយ។
- សម្ភារៈដែលចាំបាច់ក្នុងការសម្តែង ដើម្បីធ្វើឱ្យកាន់តែចាប់អារម្មណ៍ រួមទាំងរូបភាព និងស្លាកសញ្ញា។
- តើម្នាក់ៗមានតួនាទីជាអ្វីក្នុងចំណោមអ្នកសម្តែងតួ រួចហ្វឹកហាត់សម្តែងឱ្យបានល្អ។

### ២. ការសម្តែង

- ស្វាគមន៍ទស្សនិកជននិងបង្ហាញពីគោលបំណងនៃការសម្តែង។
- សម្តែងតាមតួអង្គជាក់ស្តែង។
- សួរសំណួរទៅកាន់ទស្សនិកជន ឬសុំយោបល់ពីទស្សនិកជនចំពោះការសម្តែង។
- អរគុណចំពោះទស្សនិកជន។

### ៣. ការឆ្លុះបញ្ចាំង

- តើការសម្តែងនិយាយអំពីអ្វី?
- តើអ្នកគិតថាតួអង្គ ”ក” ដូចម្តេចដែរ?
- ប្រសិនអ្នកជាតួអង្គ ”ក” តើអ្នកគួរធ្វើដូចម្តេចវិញ?

## យុទ្ធនាការផ្សព្វផ្សាយ

យុទ្ធនាការផ្សព្វផ្សាយ គឺជាសកម្មភាពដែលមានការចូលរួមពីសហគមន៍ជាច្រើន។ សកម្មភាពនេះត្រូវការធនធាន ការធ្វើផែនការ និងការរៀបចំដោយប្រុងប្រយ័ត្ន។ សកម្មភាពនេះអាចរៀបចំធ្វើបាន១ ឬ២ដងក្នុងមួយឆ្នាំ។ វានឹងទាក់ទាញការចាប់អារម្មណ៍ពីប្រជាជនច្រើនមុខសញ្ញាក្នុងសហគមន៍ រួមទាំងប្រជាជនសាមញ្ញ អាជ្ញាធរក្នុងតំបន់ អ្នកនយោបាយ និងអ្នកជំនួញ។ល។



## ១. ការរៀបចំ

- គោលបំណងនៃការធ្វើយុទ្ធនាការផ្សព្វផ្សាយ អ្នករៀបចំត្រូវតែស្វែងយល់ឱ្យបានច្បាស់។ បង្កើតគណៈកម្មការរៀបចំដែលជាអ្នកទទួលខុសត្រូវលើអ្វីៗ ដែលត្រូវធ្វើក្នុងការរៀបចំយុទ្ធនាការផ្សព្វផ្សាយ (តែងតាំងប្រធានដឹកនាំដែលអាចបញ្ជាក់ថាអ្វីៗ បានត្រៀមលក្ខណៈរួចជាស្រេចមុនធ្វើយុទ្ធនាការផ្សព្វផ្សាយ ដោយចាត់តាំងមនុស្ស ដើម្បីទទួលខុសត្រូវក្នុងការសុំច្បាប់អនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន អញ្ជើញអ្នកនយោបាយ និងថ្នាក់ដឹកនាំផ្តល់ព័ត៌មានដល់សហគមន៍ពីការផ្សព្វផ្សាយ ជូលឧត្បោសនស័ព្ទ ភេសជ្ជ:...) ។
- បង្កើតគណៈកម្មការអភិវឌ្ឍខ្លឹមសារ ដែលជាក្រុមទទួលខុសត្រូវសម្រាប់ការធ្វើយុទ្ធនាការ ហើយពិភាក្សារួមគ្នាលើខ្លឹមសារ និងអត្ថន័យ ដែលយើងចង់ស្រែកជ័យឃោសទៅកាន់សហគមន៍ ថាតើយើងចង់ផ្ញើសារឱ្យនរណា តើយើងចង់ធ្វើយុទ្ធនាការផ្សព្វផ្សាយនៅកន្លែងណា តើយើងធ្វើវានៅពេលណា (បង្កើតរបៀបវារៈរួមទាំងពេលវេលា និងទីកន្លែង) និងថាតើយើងចង់រៀបចំយុទ្ធនាការដោយរបៀបណា។ល។
- គណៈកម្មការរៀបចំ និងគណៈកម្មការអភិវឌ្ឍខ្លឹមសារត្រូវជួបគ្នាមុនថ្ងៃធ្វើយុទ្ធនាការផ្សព្វផ្សាយ ហើយពិភាក្សាថាតើពួកគេចង់ធ្វើវាយ៉ាងដូចម្តេច។

## ២. ការអនុវត្ត

- ធ្វើសេចក្តីប្រកាស និងសេចក្តីណែនាំចំពោះអ្នកចូលរួមស្តីពីការធ្វើយុទ្ធនាការណែនាំពីទិសដៅរយៈពេល និងទីកន្លែង ដែលត្រូវបញ្ចប់យុទ្ធនាការផ្តល់ភេសជ្ជៈតាមផ្លូវពេលដង្ហែ។ល។
- ផ្តើមយុទ្ធនាការដោយគ្រប់គ្នាគោរពតាមតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន។
- អរគុណចំពោះអ្នកចូលរួមក្នុងយុទ្ធនាការផ្សព្វផ្សាយ ហើយសង្ឃឹមថាពួកគេនឹងបានចូលរួមនៅពេលក្រោយទៀត។

## ៣. ការឆ្លុះបញ្ចាំង

- គណៈកម្មការរៀបចំ និងគណៈកម្មការអភិវឌ្ឍខ្លឹមសារត្រូវជួបគ្នា ដើម្បីឆ្លុះបញ្ចាំង ថាតើដំណើរការនៃការធ្វើយុទ្ធនាការប្រព្រឹត្តទៅយ៉ាងដូចម្តេច? តើយើងបានរៀនបទពិសោធអ្វីខ្លះ? តើលើកក្រោយយើងអាចធ្វើវាយ៉ាងដូចម្តេច? ។ល។
- រៀបចំ និងសរសេររបាយការណ៍ពីសកម្មភាពទាំងអស់នេះទុកជាឯកសារសម្រាប់ប្រើនៅពេលក្រោយ។
- សរសេរលិខិតថ្លែងអំណរគុណចំពោះអ្នកដែលជួយធ្វើយុទ្ធនាការនេះឱ្យបានចប់ចុងចប់ដើម និងការចូលរួមសហការនៅពេលក្រោយទៀត។

## មិត្តអប់រំមិត្ត

ការអប់រំមិត្តជាទម្រង់មួយនៃសកម្មភាពផ្សព្វផ្សាយ ចំពោះមិត្តម្នាក់ទល់ម្នាក់ ឬម្នាក់ជាមួយក្រុមតូច ឬក្រុមតូចជាមួយនឹងក្រុមធំ។ល។ គេអាចធ្វើសកម្មភាពនេះបានក្នុងចំណោមសិស្ស និងក្នុងចំណោមយុវជនដែលមិនចូលសាលារៀនផងដែរ ដើម្បីផ្តល់ព័ត៌មានដល់គេជានិច្ចនូវអ្វីដែលអាចប៉ះពាល់ដល់ពួកគេ។



### ១. ការរៀបចំ

- រៀបចំសម្ភារៈអប់រំដែលពាក់ព័ន្ធទៅនឹងប្រធានបទសម្រាប់សកម្មភាពដោយមានសៀវភៅរឿងចម្រៀងពាក្យស្លោក ប័ណ្ណពាក្យ ក្រដាសផ្ទាំងធំ។ល។
- រៀបចំផែនការសកម្មភាព សម្រាប់សកម្មភាពអប់រំមិត្ត តើអ្វីត្រូវធ្វើមុនគេ អ្វីត្រូវធ្វើបន្ទាប់.... ។
- កំណត់មិត្តដែលត្រូវអប់រំ ហើយបន្ទាប់មកត្រូវទាក់ទងជាមួយគេឱ្យបានមុន។

### ២. ការអនុវត្ត

- ណែនាំខ្លួនចំពោះមិត្តដែលត្រូវអប់រំ និងគោលបំណងនៃសកម្មភាព ។
- ធ្វើឱ្យមិត្តដែលត្រូវអប់រំចាប់អារម្មណ៍នឹងប្រធានបទ ដោយលើកឡើងនូវសារៈសំខាន់និងផលប៉ះពាល់លើពួកគេ។
- បង្ហាញប្រធានបទនិងពិភាក្សាឱ្យបានស៊ីជម្រៅលើប្រធានបទតាមរយៈសំណួរ ហេតុអ្វី? អ្វីនឹងកើតឡើងប្រសិនបើ..........? ។ល។
- ធ្វើសេចក្តីសង្ខេបនៅចុងបញ្ចប់ និងធ្វើសេចក្តីសន្និដ្ឋាន តើព័ត៌មាននេះជះឥទ្ធិពលយ៉ាងដូចម្តេចខ្លះចំពោះជីវិតគេ។
- អរគុណចំពោះមិត្ត ដែលបានរៀនជាមួយយើងអំពីប្រធានបទ និងសង្ឃឹមថានឹងបានជួបគ្នាទៀតនៅពេលក្រោយ។

### ៣. ការឆ្លុះបញ្ចាំង

- ឆ្លុះបញ្ចាំងថាតើសកម្មភាពបានប្រព្រឹត្តទៅយ៉ាងដូចម្ដេច? តើយើងបានរៀនបទពិសោធអ្វីខ្លះ?។ល។
- ត្រូវគិតថាតើសកម្មភាពនេះអាចកែលម្អយ៉ាងណាទៀតនៅពេលក្រោយ?

## វេទិកាសាធារណៈ

វេទិកាសាធារណៈជាសកម្មភាពមួយដែលផ្ដល់ឱកាសដល់មនុស្សដែលមានបទពិសោធនិងទស្សនៈខុសៗគ្នាដើម្បីចែករំលែកគំនិត និងយោបល់លើប្រធានបទជាក់លាក់មួយ។ អ្នករៀបចំសកម្មភាព អាចមានសំណួរណែនាំនិងព័ត៌មានទាន់ហេតុការណ៍ ដែលគេបានចំណាយពេលក្នុងការសិក្សាលើប្រធានបទនោះ។



### ១. ការរៀបចំ

- អភិវឌ្ឍផែនទីគំនិត ឬពិនិត្យលើការចងក្រងប្រធានបទនិងរៀបចំឱ្យបានលម្អិត។
- កំណត់ទីកន្លែងសម្រាប់ធ្វើវេទិកា និងរៀបចំលិខិតអញ្ជើញ ។
- កំណត់មុខសញ្ញាវាគ្មិនដែលត្រូវអញ្ជើញចូលរួមក្នុងវេទិកា និងផ្ដល់ព័ត៌មានដល់គេអំពីប្រធានបទ ដែលនឹងត្រូវពិភាក្សានិងចែករំលែក ដើម្បីគេអាចត្រៀមលក្ខណៈបានល្អក្នុងការជជែកពិភាក្សា។
- ធ្វើសេចក្ដីប្រកាសជាសាធារណៈដើម្បីឱ្យសហគមន៍អាចចូលរួមក្នុងវេទិកានេះ។

### ២. ការអនុវត្ត

- ស្វាគមន៍អ្នកចូលរួម និងភ្ញៀវកិត្តិយស ។
- ណែនាំប្រធានបទ និងគោលបំណងនៃវេទិកាពិភាក្សា។
- បើកវេទិកាពិភាក្សាជាសាធារណៈ និងអញ្ជើញវាគ្មិនបញ្ចេញគំនិត។
- បើកវេទិកាសំណួរ-ចម្លើយ។
- បូកសរុបនិង អរគុណចំពោះអ្នកចូលរួម។

### ៣. ការឆ្លុះបញ្ចាំង

- ឆ្លុះបញ្ចាំងថាតើសកម្មភាពបានប្រព្រឹត្តទៅយ៉ាងដូចម្តេច? តើយើងបានរៀនបទពិសោធអ្វីខ្លះ?។ល។
- ត្រូវគិតថាតើសកម្មភាពនេះអាចកែលម្អយ៉ាងណាទៀតនៅពេលក្រោយ។

## ការជជែកដេញដោល (ក្រុមគាំទ្រឬក្រុមបដិសេធ)

ការជជែកដេញដោល គឺជាទម្រង់នៃសកម្មភាពមួយទៀតស្រដៀងគ្នាទៅនឹងវេទិការសាធារណៈដែរ ប៉ុន្តែវាជំរុញឱ្យមានការពិភាក្សាទៅលើប្រធានបទមួយ ដែលមានទស្សនៈពីរផ្ទុយគ្នាស្រឡះ ដែលលើកឡើងដោយក្រុមគាំទ្រផ្សេងៗគ្នា។ ឧទាហរណ៍មានក្រុមចំនួនពីរនឹងជជែកលើប្រធានបទដែលទាក់ទង នឹងការអប់រំកុមារី ហើយក្រុមនីមួយៗត្រូវគាំទ្រគំនិតផ្ទាល់ខ្លួនរបស់គេ។ ក្រុមមួយអាចគាំទ្រលើគំនិត"ស្ត្រីមិនចាំបាច់រៀនជ្រៅជ្រះទេព្រោះ.....″ ក្រុមមួយទៀតគាំទ្រគំនិត " ស្ត្រីត្រូវតែរៀនឱ្យបានជ្រៅជ្រះ...″ ។

### ១. ការរៀបចំ

- រៀបចំក្រុមចំនួនពីរដើម្បីធ្វើការងារលើប្រធានបទជាមួយនឹងគំនិតពីរដែលខុសគ្នា។
- កំណត់ទីកន្លែងសម្រាប់ជជែកដេញដោល និងធ្វើសេចក្តីប្រកាសជាសាធារណៈ។
- កំណត់អ្នកដែលត្រូវអញ្ជើញចូលរួមក្នុងការជជែកដេញដោល និងផ្តល់ព័ត៌មានដល់គេអំពីប្រធានបទ ដែលនឹងត្រូវជជែក ដើម្បីគេអាចរៀបចំវាបានប្រសើរ។

### ២. ការអនុវត្ត

- ស្វាគមន៍អ្នកចូលរួម និងភ្ញៀវកិត្តិយស។
- ណែនាំប្រធានបទនិងគោលបំណងនៃការជជែកពិភាក្សា។
- សួរអ្នកចូលរួមតើគំនិតមួយណាដែលគេគាំទ្រ(ដើម្បីពិនិត្យមើលការវិវត្តនៃការគិតរបស់គេនៅចុងបញ្ចប់នៃវេទិកា) ហើយចាប់ផ្តើមការជជែក។
- នៅចុងបញ្ចប់នៃការជជែកសួរអ្នកចូលរួមថា តើគេអាចផ្លាស់ប្តូរគំនិតរបស់គេទៅគាំទ្រគំនិតមួយទៀតដែរឬទេ? ហើយសួរហេតុអ្វី?
- បូកសរុបនិង អរគុណចំពោះអ្នកចូលរួម។

### ៣. ការឆ្លុះបញ្ចាំង

- ឆ្លុះបញ្ចាំងថាតើសកម្មភាពបានប្រព្រឹត្តទៅយ៉ាងដូចម្តេច? តើយើងបានរៀនបទពិសោធអ្វីខ្លះ?។ល។
- ត្រូវគិតថាតើសកម្មភាពនេះអាចកែលម្អយ៉ាងណាទៀតនៅពេលក្រោយ។

## ទិវាបង្ហាញ (ពិព័រណ៍ស្នាដៃ)

ទិវាបង្ហាញជាសកម្មភាពមួយ ដែលរៀបចំឡើងដោយនាយក គ្រូ សិស្ស ដើម្បីផ្តល់ឱកាសឱ្យសិស្សបង្ហាញស្នាដៃ និងអ្វីដែលគេបានរៀនទៅដល់សហគមន៍។ ទិវាបង្ហាញនេះជា សកម្មភាពលើកទឹកចិត្តដល់សិស្សក្នុងការរៀនសូត្រ និងជំរុញឱ្យមានការគាំទ្រ និងចូលរួមពីសហគមន៍កាន់តែច្រើនថែមទៀត ជាពិសេសអាជ្ញាធរមូលដ្ឋាន ដើម្បីឱ្យពួកគេចូលរួមបំពេញការងារមួយចំនួន ដែលជាតម្រូវការ និងការចង់បានរបស់សិស្ស។ ម្យ៉ាងទៀតសកម្មភាពបង្ហាញនេះ វាជាការលើកកម្ពស់សមត្ថភាពសិស្សក្នុងការប្រើប្រាស់ចែករំលែកចំណេះដឹង និងបទពិសោធសម្រាប់ដោះស្រាយបញ្ហាងាយៗដែលកើតមាននៅក្នុងសហគមន៍។



### ១. ប្រភេទស្នាដៃ

- ការសរសេរពាក្យស្លោក ការសរសេរកំណាព្យ ចម្រៀង គំនូរ ករណីសិក្សា ការសម្តែងតួ។ល។

### ២. ការរៀបចំ

- កំណត់ពីគោលបំណង ខ្លឹមសារ សម្ភារៈ សកម្មភាពនិងវិធីសាស្ត្របង្ហាញ។
- កំណត់មុខសញ្ញា ដែលត្រូវអញ្ជើញចូលរួមក្នុងទិវាបង្ហាញ និងផ្តល់ព័ត៌មានដល់អាជ្ញាធរមូលដ្ឋាន ដើម្បីសុំការអនុញ្ញាត និងចូលរួមគាំទ្រ។
- កំណត់កាលបរិច្ឆេទ ទីកន្លែងសម្រាប់ធ្វើទិវាបង្ហាញ និងរៀបចំលិខិតអញ្ជើញ។
- ផ្សព្វផ្សាយព័ត៌មានជាសាធារណៈ ដើម្បីឱ្យសហគមន៍អាចចូលរួមក្នុងវេទិកានេះ។

### ៣. ការអនុវត្ត

- ស្វាគមន៍អ្នកចូលរួម និងភ្ញៀវកិត្តិយស
- ណែនាំគោលបំណង និងខ្លឹមសារនៃទិវាបង្ហាញ
- បើកកម្មវិធីនិងអញ្ជើញគណៈអធិបតីឡើងថ្លែងសុន្ទរកថា
- សកម្មភាពបង្ហាញរបស់ក្រុមសិស្ស
- វេទិកាសំណួរចម្លើយរវាងក្រុមសិស្ស និងអ្នកចូលរួម
- ចំណាប់អារម្មណ៍និងអនុសាសន៍របស់គណៈអធិបតី
- បូកសរុបនិងអរគុណចំពោះអ្នកចូលរួម។

### ៤. ការឆ្លុះបញ្ចាំង

- ឆ្លុះបញ្ចាំងថាតើសកម្មភាពបានប្រព្រឹត្តទៅយ៉ាងដូចម្តេច? តើយើងបានរៀនបទពិសោធអ្វីខ្លះ? ។ល។
- ត្រូវគិតថាតើសកម្មភាពនេះអាចកែលម្អយ៉ាងដូចម្តេចនៅពេលក្រោយ។

> កម្មវិធីបំណិនជីវិតតាមមូលដ្ឋានឆ្លើយតបទៅបញ្ហាប្រឈម និងតម្រូវការដែលមានក្នុងមូលដ្ឋាន ហើយសិស្សត្រូវតែមានសមត្ថភាព និងបំណិនដើម្បីឆ្លើយតប។ បញ្ហាប្រឈម និងតម្រូវការទាំងនោះអាចជាប្រធានបទ (គំរូសង្គម និងគំរូអាជីព) ដើម្បីឱ្យសិស្សស្វែងយល់អភិវឌ្ឍចំណេះដឹងរាល់បញ្ហាជុំវិញខ្លួន រួមគ្នាដោះស្រាយបញ្ហា បង្កើតឱកាសថ្មី និងត្រៀមខ្លួនចូលទៅក្នុងទីផ្សារការងារ។

## សកម្មភាពទី៣៖ បង្ហាញផែនការ និងការហ្វឹកហាត់

ការបង្ហាញផែនការផ្តល់ឱកាសឱ្យសិស្សពីក្រុមផ្សេងៗគ្នា ដើម្បីចែករំលែក និងពិភាក្សាផែនការផ្ទាល់ខ្លួនរបស់គេ ដើម្បីទទួលអនុសាសន៍ពីគ្នាទៅវិញទៅមក។ សកម្មភាពនេះជំរុញការគិតដោយវិភាគល្អិតល្អន់លើដំណោះស្រាយបញ្ហា និងជំនាញធ្វើផែនការ។

## ល្បិចបង្រៀន

- បន្ទាប់ពីក្រុមបានបញ្ចប់ផែនការសកម្មភាពរបស់គេ (អាចជាគំរូសកម្មភាពខាងលើ) គេត្រូវបង្ហាញទៅក្រុមផ្សេងទៀត ដើម្បីផ្តល់អនុសាសន៍ និងសំណូមពរ។
- គ្រូត្រូវជំរុញលើកទឹកចិត្តឱ្យក្រុមផ្សេងទៀតសួរសំណួរដោយបញ្ជាក់ ថាតើផែនការនោះជាក់លាក់និងសម្រេចបានទេ។ សំណួរគួរផ្តោតជុំវិញ៖
- តើអនុវត្តផែនការដូចម្តេច? អ្នកណាខ្លះពាក់ព័ន្ធនៅក្នុងសកម្មភាព? តើធ្វើយ៉ាងណា ដើម្បីឱ្យគេចូលរួមក្នុងសកម្មភាព?

- តើមានធនធានអ្វីខ្លះ? (ធនធានសម្ភារៈ និងធនធានមនុស្សដែលចាំបាច់សម្រាប់សកម្មភាព)។
  ១. តើនរណាទទួលខុសត្រូវធ្វើភារកិច្ចនីមួយៗ? (លិខិតអញ្ជើញអភិវឌ្ឍសម្ភារៈ រៀបចំប្រដាប់ប្រដារ...)
  ២. តើអ្នកត្រូវរៀបចំអ្វីខ្លះដែលអ្នកត្រូវការសម្រាប់ធ្វើសកម្មភាព? តើមានពេលគ្រប់គ្រាន់ទេ?
  ៣. តើពិធីប្រព្រឹត្តទៅនៅឯណា? តើវេទិកាបានកក់ទុកហើយឬនៅ?
- បន្ទាប់ពីបានទទួលអនុសាសន៍ និងសំណូមពររួចហើយ ក្រុមដែលបានឡើងបង្ហាញផែនការត្រូវពិចារណា និងពិនិត្យផែនការឡើងវិញប្រសិនជាចាំបាច់។

### សកម្មភាពទី៤៖ ការរៀបចំសម្រាប់ការអនុវត្តផែនការ

ការរៀបចំសម្រាប់ការអនុវត្ត អនុញ្ញាតឱ្យសមាជិកក្រុមចាប់ផ្តើមធ្វើការងារលើកិច្ចការរបស់គេ និងធ្វើឱ្យប្រាកដថាបានត្រៀមលក្ខណៈរួចរាល់ហើយសម្រាប់សកម្មភាពផ្សព្វផ្សាយដូចដែលបានគ្រោងទុក។

### ល្បិចបង្រៀន

- កំណត់ពេលវេលាដើម្បីធ្វើកិច្ចការ
- អភិវឌ្ឍសម្ភារៈដែលត្រូវការសម្រាប់ធ្វើសកម្មភាព
- ហ្វឹកហាត់ក្នុងការអនុវត្តផែនការសកម្មភាព
- ផ្តល់ព័ត៌មានដល់ប្រជាជនដែលពាក់ព័ន្ធនឹងសកម្មភាព
- ពេលវេលាសម្រាប់អនុវត្ត។

## VI. ការឆ្លុះបញ្ចាំងលើបំណិនដែលបានអភិវឌ្ឍ

ជាប្រការសំខាន់ណាស់ក្នុងការចំណាយពេលជាមួយសិស្ស ដើម្បីឆ្លុះបញ្ចាំងលើដំណាក់កាលនេះ។ វាជួយអោយសិស្សធ្វើការកត់សម្គាល់លើបទពិសោធ និងអារម្មណ៍របស់គេ ដែលបានចូលរួមគ្រប់សកម្មភាពទាំងអស់ នៅក្នុងដំណាក់កាលនេះ ជាពិសេសកត់សម្គាល់លើបំណិនដែលគេបានអភិវឌ្ឍ។ គ្រូអាចសួរសំណួរងាយៗដូចខាងក្រោមដើម្បីឆ្លុះបញ្ចាំង៖

១. តើការសិក្សានៅពេលនេះប្រព្រឹត្តទៅយ៉ាងដូចម្តេចដែរ?
២. តើប្អូនពេញចិត្តនឹងអន្តរកម្មជាមួយមិត្តរួមថ្នាក់របស់ប្អូនឬទេ? ហេតុអ្វី?
៣. ក្រៅពីខ្លឹមសារមេរៀន តើបំណិនអ្វីខ្លះដែលប្អូនបានអភិវឌ្ឍ? ចូររៀបរាប់ពីដំណើរការនៃការអភិវឌ្ឍបំណិនោះ។
៤. ថ្ងៃក្រោយ តើប្អូនចង់ធ្វើយ៉ាងដូចម្តេច ដើម្បីអភិវឌ្ឍបំណិនដែលប្អូនគិតថាមិនទាន់ស្ទាត់ជំនាញ?

# ដំណាក់កាលទី៥៖ ការអនុវត្តផែនការផ្សព្វផ្សាយនៅតាមសហគមន៍

## I. សេចក្តីផ្តើម

ការអនុវត្តផែនការ អនុញ្ញាតឱ្យសិស្សមានទំនាក់ទំនងជាមួយសហគមន៍ ចូលរួមក្នុងការដោះស្រាយបញ្ហា ដែលអាចជះឥទ្ធិពលដល់ជីវិតរស់នៅរបស់គេ និងដើម្បីជំរុញការយល់ដឹងផងដែរអំពីសារៈសំខាន់នៃការអប់រំ។ វាក៏ផ្តល់ឱកាសឱ្យសិស្សផងដែរក្នុងការធ្វើអន្តរកម្មជាមួយសហគមន៍ ហើយធ្វើឱ្យការរៀនសូត្រកាន់តែមានភាពជាក់ស្តែង និងមានសារៈសំខាន់សម្រាប់ជីវិតរបស់គេ។

## II. គោលបំណង

សិស្សមានសមត្ថភាពអនុវត្តតាមដំណោះស្រាយ ដែលគេជ្រើសរើស ផ្អែកលើទម្រង់សកម្មភាពផ្សព្វផ្សាយ និងចូលរួមដើម្បីដោះស្រាយបញ្ហា ដែលមាននៅតាមមូលដ្ឋាន។

## III. បំណិនចាំបាច់ត្រូវអភិវឌ្ឍ

បំណិនទំនាក់ទំនង បំណិនអន្តរបុគ្គល បំណិនក្នុងការរៀបចំ បំណិនជាក់ស្តែងក្នុងការអនុវត្តផែនការ បំណិនជជែកពិភាក្សា ទំនុកចិត្តលើខ្លួនឯង និងឥរិយាបថវិជ្ជមានក្នុងការដោះស្រាយបញ្ហា។

## IV. ល្បិចបង្រៀន

### សកម្មភាពទី១៖ ការអនុវត្តផែនការផ្សព្វផ្សាយ

ជាប្រការសំខាន់ណាស់ក្នុងការណែនាំដល់អ្នកចូលរួមមុនពេលចាប់ផ្តើមសកម្មភាព។ ការណែនាំរួមមានសមាសភាព អ្នកដែលត្រូវចូលរួម គោលបំណងនៃព្រឹត្តិការណ៍ ប្រធានបទ ដំណើរការ ពេលវេលា។ល។ ការធ្វើបែបនេះ អ្នកចូលរួមនឹងសហការយ៉ាងសកម្មក្នុងសកម្មភាព ហើយទទួលយកដោយពេញចិត្ត។

### ល្បិចបង្រៀន

#### ក. ការចាប់ផ្តើម

- អ្នករៀបចំត្រូវមកកាន់កន្លែងជួបជុំឱ្យបានមុនគេ ហើយរៀបចំអ្វីៗមុនពេលសកម្មភាពចាប់ផ្តើម
- ស្វាគមន៍អ្នកចូលរួមនិងថ្លែងអំណរគុណចំពោះការចំណាយពេលដ៏មានតម្លៃរបស់ពួកគេ
- ណែនាំប្រជាជនទាំងអស់ដែលបានចូលរួមក្នុងព្រឹត្តិការណ៍នេះ
- សង្ខេបពីគោលបំណងនៃសកម្មភាពនិងវាយតម្លៃអ្វីដែលអ្នកចូលរួមបានដឹង។

#### ខ. ការអនុវត្តសកម្មភាព

- ចាប់ផ្តើមការបង្ហាញ និងធ្វើសកម្មភាពទៅតាមផែនការ ដោយផ្អែកលើអ្វីដែលអ្នកចូលរួមបានដឹងហើយបន្សុីទៅនឹងផែនការដែលបានគ្រោងទុក។

### គ. ការផ្ដល់ព័ត៌មានត្រឡប់

សុំយោបល់ពីអ្នកដែលបានចូលរួមលើសកម្មភាពកន្លងមក តាមរយៈការសួរសំណួរដូចខាងក្រោម៖

- តើបទបង្ហាញនិយាយអំពីអ្វី?
- តើនឹងមានអ្វីខ្លះកើតឡើង?
- តើបញ្ហានេះវានឹងជះឥទ្ធិពលដល់ជីវិតរបស់អ្នកយ៉ាងដូចម្ដេច?
- តើអ្នកអាចធ្វើអ្វីបានខ្លះដើម្បីដោះស្រាយវា?

## V. ការឆ្លុះបញ្ចាំងលើបំណិន ដែលបានអភិវឌ្ឍ

ជាប្រការសំខាន់ណាស់ក្នុងការចំណាយពេលជាមួយសិស្ស ដើម្បីឆ្លុះបញ្ចាំងលើដំណាក់កាលនេះ។ វាជួយអោយសិស្សធ្វើការកត់សម្គាល់លើបទពិសោធ និងអារម្មណ៍របស់គេដែលបានចូលរួមគ្រប់សកម្មភាពទាំងអស់ នៅក្នុងដំណាក់កាលនេះ ជាពិសេសកត់សម្គាល់លើបំណិន ដែលគេបានអភិវឌ្ឍ។ គ្រូអាចសួរសំណួរងាយៗដូចខាងក្រោម ដើម្បីឆ្លុះបញ្ចាំង៖

១. តើការសិក្សានៅពេលនេះប្រព្រឹត្តទៅយ៉ាងដូចម្ដេចដែរ?

២. តើប្អូនពេញចិត្តនឹងអន្តរកម្មជាមួយមិត្តរួមថ្នាក់របស់ប្អូនឬទេ? ហេតុអ្វី?

៣.ក្រៅពីខ្លឹមសារមេរៀន តើបំណិនអ្វីខ្លះដែលប្អូនបានអភិវឌ្ឍ? ចូររៀបរាប់ពីដំណើរការនៃការអភិវឌ្ឍបំណិននោះ។

៤. ថ្ងៃក្រោយ តើប្អូនចង់ធ្វើយ៉ាងដូចម្ដេច ដើម្បីអភិវឌ្ឍបំណិន ដែលប្អូនគិតថាមិនទាន់ស្ទាត់ជំនាញ?

# ដំណាក់កាលទី៦៖ ការឆ្លុះបញ្ចាំងលើសកម្មភាពផ្សព្វផ្សាយ

## I. សេចក្ដីផ្ដើម

ការឆ្លុះបញ្ចាំងលើសកម្មភាពផ្សព្វផ្សាយ ផ្ដល់ឱកាសឱ្យសិស្សអង្គុយជាក្រុមពិភាក្សាលើអ្វីដែលគេបានធ្វើនៅក្នុងសហគមន៍ ដើម្បីរៀនសូត្រ និងរិះរកមធ្យោបាយកែលម្អសកម្មភាពឱ្យបានប្រសើរសម្រាប់លើកក្រោយ។ វាជាបំណិនរៀនសូត្រដ៏មានសារៈសំខាន់ ដែលបុគ្គលគ្រប់រូបត្រូវធ្វើការកែលម្អជីវិតរបស់គេឱ្យបានប្រសើរ។

## II. គោលបំណង

លើកទឹកចិត្តសិស្សដើម្បីឆ្លុះបញ្ចាំង និងរៀនពីបទពិសោធក្នុងការអនុវត្តសកម្មភាពតាមមូលដ្ឋាន។

## III. បំណិនចាំបាច់ដែលត្រូវអភិវឌ្ឍ

បំណិនវិភាគ បំណិនគិតដោយល្អិតល្អន់ ការជឿជាក់លើខ្លួនឯង ការស្គាល់ខ្លួនឯង និងឥរិយាបថវិជ្ជមានក្នុងការដោះស្រាយបញ្ហា។

## IV. ល្បិចបង្រៀន

### សកម្មភាពទី១៖ ការឆ្លុះបញ្ចាំងលើសកម្មភាពផ្សព្វផ្សាយ

ការឆ្លុះបញ្ចាំង គឺជាបំណិនរៀនសូត្រដ៏មានសារៈសំខាន់មួយ ដែលជួយឱ្យបុគ្គលគ្រប់រូបត្រូវជៀសវាងកំហុសដដែលៗ។ វាជំរុញឱ្យមានការគិតនិងវិភាគដោយហ្មត់ចត់ ហើយនឹងអាចទាញយកបាននូវគំនិត និងដំណោះស្រាយល្អប្រសើរសម្រាប់ជីវិតរបស់យើង។ សកម្មភាពនេះអាចធ្វើឡើង បន្ទាប់ពីការផ្សព្វផ្សាយភ្លាមៗដោយក្រុមនីមួយៗ (ប្រសិនបើរៀបចំដោយក្រុម) ឬរៀបចំនៅក្នុងថ្នាក់ដោយគ្រូ ដើម្បីឱ្យក្រុមទាំងអស់បានចែករំលែកបទពិសោធរបស់គេ។

### ល្បិចបង្រៀន

ការឆ្លុះបញ្ចាំងឡើងវិញលើសកម្មភាពដែលបានអនុវត្តត្រូវផ្តោតលើសំណួរដូចខាងក្រោម៖

១. លទ្ធផលសម្រេចបាន និងដំណោះស្រាយ

ក. តើការអនុវត្តនេះសម្រេចបានតាមគោលបំណងផែនការដែរឬទេ?

ខ. តើចំណុចខ្លាំង និងឧបសគ្គក្នុងការអនុវត្តផែនការមានអ្វីខ្លះ?

គ. តើបានដោះស្រាយបញ្ហា ដែលប្រឈមក្នុងពេលអនុវត្តសកម្មភាពយ៉ាងដូចម្តេច?

ឃ.តើចំណុចដែលចាំបាច់ត្រូវកែលម្អ សម្រាប់ការផ្សព្វផ្សាយលើកក្រោយមានអ្វីខ្លះ? តើគួរកែលម្អដោយរបៀបណា?

២. ការចូលរួមរបស់សហគមន៍

- ការតាមដានដោយយកចិត្តទុកដាក់លើការបង្ហាញ
- ការសួរសំណួរនៅពេលចប់ការសម្តែង

៣. ការសម្តែង និងការងារក្រុម

- ទំនុកចិត្តនិងការសម្តែងរបស់សមាជិកម្នាក់ៗ
- ការសហការរបស់ក្រុម
- ក្រុមនីមួយៗបង្ហាញលទ្ធផលការងាររបស់គេ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ ដែលបានកំណត់ខាងលើ ហើយសួរក្រុមផ្សេងៗទៀត (បើមាន) នៅចុងបញ្ចប់នៃការបង្ហាញ ដើម្បីឱ្យគេផ្តល់អនុសាសន៍ និងសំណូមពរ។
- ត្រូវកំណត់ចំណុចទាំងឡាយណា ដែលត្រូវកែលម្អក្នុងការធ្វើផែនការរបស់គេក្នុងកម្មវិធីបំណិនជីវិតតាមមូលដ្ឋានពេល ដែលគេរៀបចំការងារក្នុងសហគមន៍ម្តងទៀត។

### សកម្មភាពទី២៖ ការសរសេររបាយការណ៍

ការសរសេររបាយការណ៍ជាទម្រង់មួយនៃការកសាងឯកសារ ដោយកត់ត្រានូវព្រឹត្តិការណ៍សំខាន់ៗនិងអ្វីដែលបានពិភាក្សានៅពេលឆ្លុះបញ្ចាំងក្នុងសកម្មភាពទី១។ របាយការណ៍នឹងប្រើជាឯកសារយោងនៅពេលរៀបចំសកម្មភាពផ្សព្វផ្សាយលើកក្រោយ។

### ល្បិចបង្រៀន

គ្រូអាចណែនាំសិស្សពីទម្រង់ និងខ្លឹមសារគោលក្នុងការសរសេររបាយការណ៍ ដោយផ្តោតយកតាមលំនាំដូចខាងក្រោម៖

### ១. សេចក្តីផ្តើម

រៀបរាប់ការសម្រេចចិត្តក្នុងការជ្រើសរើសសកម្មភាពមកផ្សព្វផ្សាយ និងគោលបំណងដោយផ្អែកលើការយល់ដឹងពីប្រធានបទការយល់ដឹងរបស់សហគមន៍ ការវិភាគដើមឈើបញ្ហា និងដំណោះស្រាយ។

### ២. តួសេចក្តី

រៀបរាប់ពីដំណើរការ និងគំនិតសំខាន់ៗនៃការផ្សព្វផ្សាយដោយ ៖

- វាយតម្លៃពីការអនុវត្តផែនការផ្សព្វផ្សាយ
- វាយតម្លៃពីការចូលរួមរបស់សហគមន៍
- វាយតម្លៃសមត្ថភាពរបស់ក្រុមក្នុងការរៀបចំសកម្មភាព

### ៣. សេចក្តីបញ្ចប់

- ទាញសេចក្តីសន្និដ្ឋានរួម
- អនុសាសន៍

## V. ការឆ្លុះបញ្ចាំងលើបំណិនដែលបានអភិវឌ្ឍ

ជាប្រការសំខាន់ណាស់ក្នុងការចំណាយពេលជាមួយសិស្ស ដើម្បីឆ្លុះបញ្ចាំងលើដំណាក់កាលនេះ។ វាជួយអោយសិស្សធ្វើការកត់សម្គាល់លើបទពិសោធ និងអារម្មណ៍របស់គេ ដែលបានចូលរួមគ្រប់សកម្មភាពទាំងអស់ នៅក្នុងដំណាក់កាលនេះ ជាពិសេសកត់សម្គាល់លើបំណិនដែលគេបានអភិវឌ្ឍ។ គ្រូអាចសួរសំណួរងាយៗដូចខាងក្រោម ដើម្បីឆ្លុះបញ្ចាំង៖

១. តើការសិក្សានៅពេលនេះប្រព្រឹត្តទៅយ៉ាងដូចម្តេចដែរ?

២. តើប្អូនពេញចិត្តនឹងអន្តរកម្មជាមួយមិត្តរួមថ្នាក់របស់ប្អូនឬទេ? ហេតុអ្វី?

៣.ក្រៅពីខ្លឹមសារមេរៀន តើបំណិនអ្វីខ្លះដែលប្អូនបានអភិវឌ្ឍ? ចូររៀបរាប់ពីដំណើរការនៃការអភិវឌ្ឍបំណិននោះ។

៤. ថ្ងៃក្រោយ តើប្អូនចង់ធ្វើយ៉ាងដូចម្តេច ដើម្បីអភិវឌ្ឍបំណិនដែលប្អូនគិតថាមិនទាន់ស្ទាត់ជំនាញ?

## ឧបសម្ព័ន្ធ១៖ រង្វាយតម្លៃផ្លូវការ

### ក. ប័ណ្ណវាយតម្លៃការសិក្សាផ្លូវការរបស់សិស្សម្នាក់ៗ (សម្រាប់សិស្ស/គ្រូប្រើ )

ឈ្មោះសិស្ស ................................. សាលា ..................................ស្រុក.......................................

☹ សមត្ថភាពមិនទាន់សម្រេចបាន 😐 សមត្ថភាពកំពុងទទួលបាន ☺ សមត្ថភាពទទួលបានពេញលេញ

| ល.រ | កិច្ចការទី១ តេស្តលើចំណេះដឹង៖ ការទទួលបាន និងប្រើប្រាស់ចំណេះដឹង | ស្ថានភាព | | |
|---|---|---|---|---|
| ១ | ចំណេះដឹងដែលទទួលបាន | ☹ | 😐 | ☺ |
| ២ | ការប្រើប្រាស់ចំណេះដឹងសម្រាប់ខ្លួនឯង | | | |
| ៣ | ការប្រើប្រាស់ចំណេះដឹងសម្រាប់គ្រួសារ និងសហគមន៍ | | | |
| សរុប | | | | |
| <u>កិច្ចការទី២ ការងារប្រតិបត្តិ៖</u> ចូរអានប្រយោគនីមួយៗក្នុងតារាងខាងក្រោម រួចគូស (✓) ក្នុងប្រអប់ចម្លើយណាមួយ ដែលសមស្របនឹងបំណិនការងារ និងគុណតម្លៃ ដែលសិស្សបានអភិវឌ្ឍ។ | | | | |

| ល.រ | ការអភិវឌ្ឍបំណិនជីវិតរបស់សិស្ស | ស្ថានភាព | | |
|---|---|---|---|---|
| | | ☹ | 😐 | ☺ |
| | បំណិនសង្គម និងការងារ | | | |
| ១ | <u>ការប្រាស្រ័យទាក់ទង៖</u> ខ្ញុំបង្ហាញពីគោលបំណង និងគំនិតច្បាស់លាស់ ហើយបញ្ជាក់ឡើងវិញ។ ខ្ញុំតែងតែស្តាប់ដោយយកចិត្តទុកដាក់ ហើយមិនដែលមានទំនាស់ឡើយ។ | ✓ | | |
| ២ | <u>ការកំណត់គោលដៅ៖</u> ខ្ញុំដឹងច្បាស់ពីអ្វីដែលខ្ញុំត្រូវធ្វើនៅពេលធំឡើង ហើយអំណត់ព្យាយាម ដើម្បីសម្រេចគោលដៅនោះ។ | | | |
| ៣ | <u>ការដោះស្រាយបញ្ហា៖</u> ខ្ញុំអាចកំណត់បានដំណោះស្រាយច្រើនចំពោះបញ្ហាមួយ ហើយរើសយកដំណោះស្រាយសមស្រប ដែលខ្ញុំអាចដោះស្រាយបាន។ | | | |
| ៤ | <u>ការសម្រេចចិត្ត៖</u> ខ្ញុំតែងតែប្រមូលព័ត៌មាន និងភស្តុតាងជាច្រើន ឬពិគ្រោះយោបល់ជាមួយអ្នកមានបទពិសោធ មុននឹងធ្វើការសម្រេចចិត្ត។ | | | |
| ៥ | <u>ការធ្វើផែនការ៖</u> ខ្ញុំដឹងថាត្រូវធ្វើអ្វី? ហេតុអ្វី? ធ្វើពេលណា? ធនធានអ្វី? ធ្វើយ៉ាងដូម្តេច? | | | |
| ៦ | <u>ការគ្រប់គ្រងពេលវេលា៖</u> ខ្ញុំចេះប្រើប្រតិទិន ធ្វើផែនការប្រចាំថ្ងៃ ដើម្បីសម្រេចការងាររបស់ខ្ញុំ។ | | | |
| ៧ | <u>ការគិតបែបពិចារណា៖</u> ខ្ញុំតែងតែសួរខ្លួនឯងថា ប្រសិនបើខ្ញុំធ្វើដូចនេះ អ្វីនឹងកើតឡើង? តើមានជម្រើសផ្សេងទៀតដែលប្រសើរជាងនេះដែរឬទេ? | | | |
| ៨ | <u>ការមានហេតុផល៖</u> ខ្ញុំតែងសួររកហេតុផល អំណះអំណាង និងភស្តុតាងច្បាស់លាស់។ | | | |
| ៩ | <u>ការងារក្រុម៖</u> ខ្ញុំជាសមាជិកសកម្ម ស្តាប់យោបល់អ្នកដទៃ និងជួយនាំក្រុមឲ្យសម្រេចជោគជ័យ។ | | | |
| ១០ | <u>ពិភពការងារ៖</u> ខ្ញុំអាចប្រាប់បានពីប្រភេទការងារ (ទទួលកម្រៃ និងការងារផ្ទាល់ខ្លួន)។ ខ្ញុំដឹងថាប្រភេទការងារនីមួយៗតម្រូវឲ្យមានបំណិន គុណតម្លៃ និងជំនាញអ្វីខ្លះ។ | | | |
| ១១ | សញ្ញាណអាជីវកម្ម៖ ខ្ញុំអាចរៀបរាប់ពីការប្រកបអាជីវកម្ម ជាក់លាក់ណាមួយ ដូចជាការបង្កើត និងគ្រប់គ្រងអាជីវកម្ម ការគ្រប់គ្រងអតិថិជន ទីផ្សារ បុគ្គលិក និងប្រាក់។ល។ | | | |

| | | | | |
|---|---|---|---|---|
| ១២ | សញ្ញាណបច្ចេកទេស៖ ខ្ញុំអាចប្រាប់បានពីបច្ចេកទេសជាក់លាក់ណាមួយ ដូចជា ការចិញ្ចឹមមាន់ ការដាំបន្លែ ការជួសជុលម៉ូតូ ការធ្វើម្ហូប សំអាងការ កាត់សក់។ល។ | | | |
| | គុណតម្លៃ | | | |
| ១៣ | ការឱ្យតម្លៃលើខ្លួនឯង៖ ខ្ញុំគិតវិជ្ជមានពីខ្លួនឯង និងសាទរចំពោះជោគជ័យដែលខ្លួនធ្វើ។ | | | |
| ១៤ | ភាពស្មោះត្រង់៖ ខ្ញុំតែងតែនិយាយពីការពិត ទទួលខុសត្រូវចំពោះអ្វីដែលខ្ញុំបានធ្វើ។ ទន្ទឹមនឹងនេះ ខ្ញុំតែងតែបញ្ចេញទស្សនៈរបស់ខ្ញុំចំពោះការពិតនោះ។ | | | |
| ១៥ | ឥរិយាបថវិជ្ជមាន៖ ខ្ញុំមានចិត្ត និងគំនិតទូលំទូលាយឱ្យតម្លៃអ្នកដទៃ និងទទួលការរិះគន់ដោយរីករាយ។ គំនិតវិជ្ជមាន នាំឲ្យមានទង្វើវិជ្ជមាន នាំឲ្យមានអារម្មណ៍វិជ្ជាមាន។ | | | |
| ១៦ | ការយល់ចិត្តគ្នា៖ ខ្ញុំតែងតែដាក់ខ្លួនខ្ញុំក្នុងស្ថានភាពអ្នកដទៃ ហើយសួរខ្លួនឯងថា ប្រសិនបើខ្ញុំជាគាត់ តើខ្ញុំគួរធ្វើយ៉ាងណា? | | | |
| ១៧ | ការគ្រប់គ្រងកំហឹង៖ ខ្ញុំតែងតែព្យាយាមយល់ពីបញ្ហាឲ្យបានច្បាស់ បន្ទាប់មករាប់ពី ១ ដល់ ១០ មុននឹងឆ្លើយតប។ ខ្ញុំក៏ព្យាយាមបង្ហាញពីហេតុផល ដើម្បីឲ្យដៃគូបានយល់ និងស្ងប់ចិត្ត។ | | | |
| ១៨ | ការទទួលខុសត្រូវ៖ ខ្ញុំទទួលស្គាល់ការពិត និងកែលម្អចំណុចខ្វះខាតរបស់ខ្ញុំ។ | | | |
| សរុប | | | | |

## ខ. បណ្ណវាយតម្លៃការសិក្សាផ្លូវការរបស់សិស្សជាក្រុម

**កិច្ចការទី៣ សមិទ្ធផលសិក្សា៖** សាលាអាចរៀបចំពិព័រណ៍ស្នាដៃសិស្ស ដើម្បីបង្ហាញសមិទ្ធផលសិក្សា រៀងរាល់ឆមាស ឬឆ្នាំទៅតាមលទ្ធភាពជាក់ស្ដែង។ សិស្សអាចត្រៀមជារូបថត សមិទ្ធផល ឬការសម្ដែងតួ ដើម្បីបង្ហាញដល់សហគមន៍ចំពោះដំណើរការ និងសមិទ្ធផល ដែលគេសម្រេចបានតាមរយៈការរៀនបំណិនជីវិត។ ការវាយតម្លៃក្រុមផ្ដោតលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

| ល.រ | ការរៀបចំបង្ហាញពិព័រណ៍ស្នាដៃរបស់សិស្ស | ស្ថានភាព | | |
|---|---|---|---|---|
| ១ | ការរៀបចំចាត់ចែង៖ ក្រុមសិស្សមានផែនការ និងការទទួលខុសត្រូវរបស់សមាជិកម្នាក់ៗ។ សមាជិកម្នាក់ៗ បំពេញទទួលនាទីរបស់ខ្លួនបានត្រឹមត្រូវរួមទាំងទីតាំង កន្លែងអង្គុយ ការអញ្ជើញ និងទទួលភ្ញៀវ កម្មវិធីជាក់លាក់ បរិយាកាសសមស្រប។ | ☹ | 😐 | ☺ |
| ២ | ការតាំងបង្ហាញ៖ ការរៀបចំស្នាដៃតាមប្រភេទ មានឈ្មោះ ងាយមើល និងគួរឱ្យចាប់អារម្មណ៍ ព្រមទាំងមានការពណ៌នាពីស្នាដៃនីមួយៗ។ | | | |
| ៣ | ការធ្វើបទបង្ហាញ៖ សិស្សបង្ហាញជាក្រុម ដោយមានការបែងចែកការទទួលខុសត្រូវក្នុងចំណោមសមាជិកក្រុម មានទំនុកចិត្ត ខ្លឹមសារច្បាស់លាស់ មានចំណាប់អារម្មណ៍ពីទស្សនិកជន។ | | | |
| ៤ | ការសម្ដែងតួ៖ សិស្សសម្ដែងជាក្រុម ដោយមានការបែងចែកការទទួលខុសត្រូវក្នុងចំណោមសមាជិកក្រុម មានទំនុកចិត្ត បញ្ចូលមនោសញ្ចេតនា មានចំណាប់អារម្មណ៍ពីទស្សនិកជន។ លើសពីនេះទៀតមានសារអប់រំច្បាស់លាស់។ | | | |
| ៥ | កិច្ចសហការក្នុងការងារក្រុម៖ សិស្សទាំងអស់មានគោលដៅរួម ហើយម្នាក់ៗរួមចំណែកធ្វើឱ្យក្រុមសម្រេចបានតាមគោលដៅ ដោយមានបរិយាកាសរីករាយ និងមានភាពស្និទ្ធស្នាល។ | | | |
| សរុប | | | | |

## គ. តារាងបូកសរុបរង្វាយតម្លៃការសិក្សារបស់សិស្សប្រចាំថ្នាក់ (គំរូបំណិនជីវិតសង្គម)

ឈ្មោះថ្នាក់ .................................. ភូមិ ..................................ឃុំ.......................................

☹ សមត្ថភាពមិនទាន់សម្រេចបាន 😐 សមត្ថភាពកំពុងទទួលបាន ☺ សមត្ថភាពទទួលបានពេញលេញ

| ល.រ | ឈ្មោះសិស្ស | កិច្ចការទី ១ | | | កិច្ចការទី ២ | | | | | | សមិទ្ធផលរួម | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ចំណេះដឹង | | | បំណិន | | | គុណភាពផ្ទាល់ខ្លួន | | | | | |
| | | ☹ | 😐 | ☺ | ☹ | 😐 | ☺ | ☹ | 😐 | ☺ | ☹ | 😐 | ☺ |
| ១ | | | | | | | | | | | | | |
| ២ | | | | | | | | | | | | | |
| ៣ | | | | | | | | | | | | | |
| ៤ | | | | | | | | | | | | | |
| ៥ | | | | | | | | | | | | | |
| ៦ | | | | | | | | | | | | | |
| ៧ | | | | | | | | | | | | | |
| ៨ | | | | | | | | | | | | | |
| ៩ | | | | | | | | | | | | | |
| ១០ | | | | | | | | | | | | | |
| ១១ | | | | | | | | | | | | | |
| ១២ | | | | | | | | | | | | | |
| ១៣ | | | | | | | | | | | | | |
| ១៤ | | | | | | | | | | | | | |
| ១៥ | | | | | | | | | | | | | |
| ១៦ | | | | | | | | | | | | | |
| ១៧ | | | | | | | | | | | | | |
| ១៨ | | | | | | | | | | | | | |

ថ្ងៃទី ខែ ឆ្នាំ ២០

គ្រូប្រចាំថ្នាក់

## ឃ. តារាងបូកសរុបរង្វាយតម្លៃការសិក្សារបស់សិស្សប្រចាំថ្នាក់ (គំរូបំណិនជីវិតអាជីវកម្ម)

ប្រធានបទ៖.......................................................................................................................

ឈ្មោះថ្នាក់ .................................. ភូមិ ...................................ឃុំ.........................................

☹ សមត្ថភាពមិនទាន់សម្រេចបាន 😐 សមត្ថភាពកំពុងទទួលបាន ☺ សមត្ថភាពទទួលបានពេញលេញ

| ល.រ | ឈ្មោះសិស្ស | កិច្ចការទី ១ | | | កិច្ចការទី ២ | | | | | | សមិទ្ធផលរួម | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | បំណិនមូលដ្ឋាន | | | អាជីវកម្ម/ការងារ | | | ជំនាញបច្ចេកទេស | | | | | |
| | | ☹ | 😐 | ☺ | ☹ | 😐 | ☺ | ☹ | 😐 | ☺ | ☹ | 😐 | ☺ |
| ១ | | | | | | | | | | | | | |
| ២ | | | | | | | | | | | | | |
| ៣ | | | | | | | | | | | | | |
| ៤ | | | | | | | | | | | | | |
| ៥ | | | | | | | | | | | | | |
| ៦ | | | | | | | | | | | | | |
| ៧ | | | | | | | | | | | | | |
| ៨ | | | | | | | | | | | | | |
| ៩ | | | | | | | | | | | | | |
| ១០ | | | | | | | | | | | | | |
| ១១ | | | | | | | | | | | | | |
| ១២ | | | | | | | | | | | | | |
| ១៣ | | | | | | | | | | | | | |
| ១៤ | | | | | | | | | | | | | |
| ១៥ | | | | | | | | | | | | | |
| ១៦ | | | | | | | | | | | | | |
| ១៧ | | | | | | | | | | | | | |
| ១៨ | | | | | | | | | | | | | |

ថ្ងៃទី ខែ ឆ្នាំ ២០

គ្រូប្រចាំថ្នាក់

## ឧបសម្ព័ន្ធទី២៖ វាយតម្លៃក្រៅផ្លូវការ

### ក. ការវាយតម្លៃលើឥរិយាបថរបស់សមាជិកក្រុម

សិស្សគូររង្វង់រូបមុខមនុស្ស ដែលតំណាងឱ្យអារម្មណ៍របស់គេពីសមាជិកនៅក្នុងក្រុមដែលគេធ្វើការជាមួយ។

| | | |
|---|---|---|
| ខ្ញុំលើកទឹកចិត្តសមាជិកដទៃទៀតនៅក្នុងក្រុម។ | ☺ | ☹ |
| ខ្ញុំផ្តល់គំនិត និងព័ត៌មានទៅឱ្យសមាជិកផ្សេងទៀត។ | ☺ | ☹ |
| សមាជិកផ្សេងទៀតនៅក្នុងក្រុមរបស់ខ្ញុំបានលើកទឹកចិត្តខ្ញុំ។ | ☺ | ☹ |
| សមាជិកផ្សេងទៀតបានផ្តល់ គំនិត និងព័ត៌មានដល់ខ្ញុំ។ | ☺ | ☹ |

### ខ. ការវាយតម្លៃការងារក្រុមពីចំណុចចូលចិត្ត

<u>ការវាយតម្លៃការងារពីចំណុចចូលចិត្ត និងចំណុចកែលម្អ</u>

អ្វីដែលយើងចូលចិត្ត អ្វីដែលយើងចង់កែលម្អ៖

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

គំនិតសម្រាប់ពេលក្រោយនៅពេលដែលយើងធ្វើការក្នុងក្រុមសហការ៖

..........................................................................................................

..........................................................................................................

..........................................................................................................

..........................................................................................................

## គ. ការគិតរបស់ក្រុមខ្ញុំ

### ការគិតអំពីក្រុមរបស់ខ្ញុំ

១. តើអ្នកបានធ្វើអ្វីខ្លះ នៅក្នុងក្រុម ដើម្បីធ្វើឱ្យក្រុមរបស់អ្នកមានដំណើរការល្អ?

................................................................................................................................

................................................................................................................................

................................................................................................................................

................................................................................................................................

................................................................................................................................

២. តើអ្នកបានមើលឃើញអ្វីកើតឡើង ដែលបណ្តាលឱ្យមានបញ្ហានៅក្នុងក្រុមរបស់អ្នក?

................................................................................................................................

................................................................................................................................

................................................................................................................................

................................................................................................................................

៣. តើក្រុមរបស់អ្នកអាចធ្វើអ្វីលើកក្រោយ ដើម្បីឱ្យការធ្វើការរបស់អ្នកបានល្អជាមួយគ្នា?

................................................................................................................................

................................................................................................................................

................................................................................................................................

................................................................................................................................

## ឃ. តារាងពិនិត្យតាមដានក្រុម

ចូរគូសរង្វង់ត្រង់ចម្លើយណាមួយ ដែលអ្នកពេញចិត្ត សូមបញ្ជាក់ថាអ្នកមិនអាចគូសយកចម្លើយលើសពីមួយបានឡើយ។

ឧទាហរណ៍:

១. យើងបានផ្តល់ឱកាសឱ្យសមាជិកក្រុមបញ្ចេញយោបល់បានគ្រប់ៗគ្នា។

ជានិច្ចកាល　　ម្តងម្កាល　　មិនដែលសោះ

២. យើងបានត្រួតពិនិត្យដើម្បីប្រាកដថាយើងបានយល់ពីការណែនាំ ។

ជានិច្ចកាល　　ម្តងម្កាល　　មិនដែលសោះ

៣. យើងបានចែករំលែកសម្ភារៈរបស់យើង និង ប្តូរវេនគ្នាដើម្បីប្រើប្រាស់សម្ភារៈទាំងនោះ ។

ជានិច្ចកាល　　ម្តងម្កាល　　មិនដែលសោះ

៤. យើងបានជួយគ្នាទៅវិញទៅមក ។

ជានិច្ចកាល　　ម្តងម្កាល　　មិនដែលសោះ

៥. យើងបានលើកសរសើរគ្នាទៅវិញទៅមក ។

ជានិច្ចកាល　　ម្តងម្កាល　　មិនដែលសោះ

៦. យើងបានស្តាប់ដោយគ្មានការរំខាន ។

ជានិច្ចកាល　　ម្តងម្កាល　　មិនដែលសោះ

៧. យើងអាចធ្វើបានប្រសើរលើ បំណិនសហប្រតិបត្តិការ

ជានិច្ចកាល　　ម្តងម្កាល　　មិនដែលសោះ

គាំទ្រដោយយូនីសេហ្វ

unicef

for every child